ជំពូក១៧

## ស្នេហាពិតលេចឡើងពេលមានឧបសគ្គ

......ម៉ោងមួយរំលងអធ្រាត្រ....ជាម៉ោងដែលមនុស្សម្នាដេកលក់ស្ងាត់សូន្យ ឈឹង...គេបែរជាឃើញនារីម្នាក់ជិះម៉ូតូឌុបរុំមុខជិតឈឹងឆ្ពោះទៅ មុំផ្សារទួលគោកហើយចូលតាមផ្លូវចង្អៀតមួយស្ងាត់ជ្រងំនិង ងងឹតស្លុប....

«បង! អូនមកដល់ហើយ! បើកទ្វារ!»
ភ្លើងត្រូវបានចុចបំភ្លឺមកខាងក្រៅផ្ទះ។ នេះគឺសំឡេងបុស្បាដែលលាក់ក្នុងកន្សែងទទូរជុំជិតមិនចង់ឲ្យមានគេ ចំណាំនាងបាន។ នាងជិះម៉ូតូឌុបនិងស្លៀកពាក់ខុសទម្លាប់ក៏ដើម្បីឈានឲ្យផុតរនាំង យាមកាមតាមឃ្លាំរបស់ពូនាងហើយនាងចេញមករក ប៉ែន ពេជ្រប្រាថ្នា ដោយមិនអាចអត់ធ្មត់រង់ចាំដល់ពេលភ្លឺឡើយ។
«ផ្ទះកខ្វក់ម៉េះ? អូខេ! ចាំអូនបោសជូតវា!»
«អូនមកពីណា? ស្លៀកពាក់ពិបាកភ្នែកម៉េះ? មើល៍ពាក់កន្សែងនេះធ្វើអី? ដូចជនជាតិអញ្ចឹងដោះចេញទៅ»
«អូនគេចភ្នែកពួកអ្នកតាមដាន!»នារីតបទាំងស្រងូត។
«អាណាគេ? យុត្តនា? ពៅបញ្ញា?...ដល់ក្នុងផ្ទះហើយតើ! តោះដោះចេញទៅ?មានពីណាឃើញទៀត?»
កាយវិការគេគឺនឹកនាងណាស់ ហើយនាងតែម្នាក់គត់ដែលគេអាចមករកបាននៅពេលដែលគេយល់ថាចង់គេច ឲ្យបាត់ពីពិភពលោកនេះ។ ម្ចាស់សាជីវកម្ម K-P-I ស្រែករ៉ាសពេលគេទាញកន្សែងនាងរបូតអស់៖
«មុខអូនឯងកើតអី? ពីណាធ្វើអ្ហះបុស្បា?»
នារីយំជំនួសចម្លើយ។ ប្រាថ្នាគ្រានាងឲ្យអង្គុយលើសាឡុង ទាំងក្តុកក្តួលចិត្ត៖
«អាណាធ្វើ?»គេខាំធ្មេញនៅពេលនាងសម្លឹងមកទាំងទឹកភ្នែក។ នាងមិននិយាយតែចិត្តកំពុងគិត។ តើសម្តីយុត្តនាពិតឬអ្វី ? បុរសព្រាននេះពិតជាស្រលាញ់យើងនៅទីបំផុតមែនអត់???បើមិនអញ្ចឹងម៉េចក៏ពេលគេគេចមុខពីគ្រប់គ្នា ពីម្តាយគេនិងពីប្អូនស្រីគេ គេមករកយើងហើយជឿថាយើងមិនទុរយសចំពោះគេ។ នាងផ្អែកទៅលើដើមទ្រូងនាយ ហើយបិទភ្នែកបណ្តោយឲ្យទឹកភ្នែកស្រក់។សំឡេងគេលាន់មកតិចៗ៖

«បងធ្វើបាបអូន! បងសុំទោស!»
នាងឮហើយកាន់តែយំ។
នាងដឹងគេខ្វល់ពីសម្រស់នាងដែលជាតារាម្នាក់។ អំណើះតទៅនាងត្រូវចប់អាជីពនេះបើសិនជាមុខនេះកែមិនឡើងទេនោះ។ ប៉ុន្តែនាងវិញលែងគិតរឿងនេះហើយបន្ទាប់ពីនាងសម្រេចចិត្តមករកគេ ក្នុងពេលនេះ។

នាងនឹកដល់សម្ដីយុត្តនា តើគេពិតជានិយាយត្រូវមែនឬ? ភាពត្រេកត្រអាលរបស់នាងចំពោះគេព្រោះតែចិត្តចង់ឈ្នះនិងការញុះញង់ ពីមនុស្សចាស់ដែលសម្បូរល្បិច ចំណែកចិត្តស្រលាញ់ពិតនាងគួរតែមានជាមួយបុរសនេះ ប៉ុន្តែនាងគិតថាគ្មានព្រោះនាងខឹងគេដែលជាមនុស្សសម្បូរស្នេហ៍ ហើយទៅចោលនាងយូរពេក។
ស្រីស្អាតវាចាតិចៗក្បែរទ្រូងគេ៖
«មុននេះអូនសម្លាប់ខ្លួន!»
ប្រាថ្នាភ្ញាក់ក្រញាង គេទាញនាងមកវិញហើយសម្លឹងនាង៖
«ហេតុអី??? អ្នកណាបង្ខំអូនអ្ហះ? ឆ្កួតទេអ្ហេស៎?»
នាងនៅតែមិននិយាយជាមួយខ្សែភ្នែកល្ហល្ហេវនឹងនជាសញ្ញានៃមនុស្ស មានទុក្ខពេញហៀរមួយជីវិតមកហើយ។ គេឱបនាងជាប់ដើមទ្រូងសាជាថ្មីទាំងឈឺចិត្ត។ សំឡេងបុស្បាលាន់មកបន្តខ្សាវៗ៖
«សម្រាប់មនុស្សស្រីកំព្រីកំព្រាម្នាក់ដែលគ្មានអ្នកណាទាំងអស់! អ្វីៗសុទ្ធតែក្លែងក្លាយ!!! តើអូនមានអីជាកម្លាំងចិត្តនិងស៊ូតទៅទៀត?»
ប្រាថ្នាមិនមាត់អ្វីចេញមួយម៉ាត់គិតពីឱបនាងណែនជាងមុន បុស្បានិយាយបន្ត៖
«ខ្សែសូត្រនោះស្ដើងពេកអត់មានមាំទេបានជាអូនដាច់ធ្លាក់មកវិញ....»
អ្នកប្រុសប្រញាប់ទាញនាងចេញពីទ្រូងហើយលាត់មើលកនាងឃើញស្នាម ក្រហមមួយពិតមែន គេខាំមាត់ដែលញ័រ ហើយឱបនាងសាជាថ្មី។ ស្រីស្អាតនិយាយបន្ថែមទៀតទាំងល្ងើយ៖
«ពេលធ្លាក់មកវិញអូនក៏នឹកឃើញរឿងមួយ! យ៉ាងហោចណាស់អូនគួរជួបបង សួរបងប៉ុន្មានម៉ាត់សិនដែរបើបំណាច់នឹងទៅ!»
ទឹកភ្នែកក្ដៅឧណ្ហរបស់អ្នកប្រុសធ្លាក់លើថ្ពាល់នាង៖
«អូនឯងឆ្កួតហើយ! បើអូនឯងទៅបាត់បងមានអ្នកណាទៀត?»

បុស្បាងើបមុខភ្លែត នាងមិនមែនចាប់អារម្មណ៍នឹងសម្ដីគេខ្លាំងពេកទេ តែគឺតំណក់ទឹកភ្នែកគេ។

«អគ្គនាយកK-P-Iលោកពិតជាយំដោយសារស្រីគ្មានន័យម្នាក់ខ្ញុំមែន?»នាង គិតទាំងក្តុកក្តួលចិត្ត។សម្ដីយុត្តនាលាន់មកជាថ្មីក្នុងចិត្តនាង៖

«ខ្ញុំចង់និយាយពី ប៉ែន ពេជ្រប្រាថ្នា! គេស្រលាញ់នាងបានជាពេលពិបាកបំផុត គេមិនអាចទៅណាហើយទៅរកនាង! សម្រាប់មនុស្សដែលស្រលាញ់យើង នាងគួរជួយគេឲ្យរកឃើញផ្លូវត្រូវប្រសើរជាងទុកឲ្យគេនៅហេងហាង មិនដឹងត្រូវធ្វើយ៉ាងណា!»

ឃើញនាងនៅស្ងៀមគេរឹតតែជ្រួញមុខយំ។ ចរិតលក្ខណៈជាអ្នករកស៊ីធំរបស់គេលុបទៅណាបាត់ជំនួសមកវិញនូវបុរស ទន់ជ្រាយម្នាក់។ ដៃគេឱបនាងកាន់តែមាំហាក់ខ្លាចនាងស្ទុះរត់ទៅចោលគេ។គឺយ៉ាងនេះ ហើយបានជាគេមិនដឹងធ្វើយ៉ាងណា នៅពេលគេបានធ្វើខុសចំពោះមនុស្សដែលខំស្រលាញ់គេ តួយ៉ាងដូចជា ហួត ស៊ីវ។

សំឡេងគេលាន់មកខ្សឹកខ្សួល៖

«ឈប់ធ្វើឡប់ៗទៅ ទោះអូនអាក្រក់ ទោះអូនក្លាយទៅជាអ្វីក៏បងស្រលាញ់អូនដែរបុស្បា! កុំធ្វើអញ្ចឹងទៀតណ៎ា! អូខេ! យើង....យើង....រកកន្លែងមួយ ចុះអេតាស៊ីវិលរៀបការទៅ!»

នារីភ្ញាក់ព្រើត នាងងើបមុខសម្លឹងនាយទាំងសួរខ្លួនឯងដូចផ្លេកបន្ទោរ«នាយក K-P-I មានប្រាក់រាប់លាននេះឬដែលមកសុំយើងរៀបការ?»

នាងសម្លឹងមុខនាយជាមួយសំណួរខ្លីខ្សាវៗ៖

«ពិតមែន?»

គេងក់ក្បាល ហើយបន្តប្រយោគ៖

«ក្នុងចំណោមស្រីទាំងអស់ដែលបងជួប បងបានស្រលាញ់អូនទៅហើយ! គឺនៅពេលបងដឹងថាបងពិបាកភ្លេចអូនបាន បងបានព្យាយាមគេចចេញ! គ្រួសារបងមិនអាចទទួលយកអូនបានទេ!នោះគឺជំទាវម៉ាក់! តែពេលនេះបងលែងខ្វល់ហើយ! បងជាកូនអត់បានការទេបងសម្លាប់ប៉ាបង្កើតខ្លួនឯង!បងមិនហ៊ាន ទាំងចេញឃើញពន្លឺថ្ងៃ បើអូនស្រលាញ់បង យើងរកកន្លែងស៊ីញ៉េរៀបការទៅ មិនបាច់ខ្វល់ពីអ្នកណាទេ ហើយបើស្លាប់យើងស្លាប់ជាមួយគ្នា!»

នាងនៅស្ងៀមតែដៃនាងឱបគេវិញតឹងញ៉ឹះ។ គឺនេះហើយជាស្នេហាដែលនាងទើបតែគិតយល់។ពេលខ្លះកាលៈទេសៈខ្លះ មនុស្សស្រលាញ់គ្នាសឹងថាមិនអាចទទួលស្គាល់ស្នេហារបស់

ខ្លួនបានទេ ដោយសារគំនាបផ្សេងៗនិងការរកវិធីដោះស្រាយតាមសមត្ថភាពយល់ដឹងរបស់គាត់ម្នាក់ៗ។
«បងទៅផ្ទះវិញទៅ!»នាងនិយាយតិចៗទាំងស្រពោន។
«ក្រែងពីមុនអូនឲ្យបងលាក់ខ្លួន?»
«តែបងត្រូវជួយយុត្តនា! អ្នកផងយល់ថាគេជាអ្នកច្រានលោកអគ្គ»
«អូនស្រលាញ់គេ?»
«អត់ទេគឺស្រលាញ់បង បានជាចង់ឲ្យបងជួយគេ ដូចជាជួយប៉ាបង ហួត ស៊ីវ! បងនៅមានពេលវែងដើម្បីធ្វើរឿងល្អលាងកំហុស! តាមពិតពូអូនគឺលេខាប៉េង......»
នាងនិយាយពីគម្រោងផែនការនិងអាថ៌កំបាំងទារគំនុំទាំងអស់របស់លេខាប៉េងប្រាប់គេ។
————–

ជំពូក១៨

គេនៅចាំទេពធីតាក្នុងព្រៃជ្រៅដែរ?

«ថ្ងៃនេះខ្ញុំចេញពីពេទ្យហើយ!»
សក្ខណានិយាយដោយទឹកមុខស្ងួត ហើយសម្លឹងពៅបញ្ញាពីក្រោមដល់លើព្រោះអាណិតភាពស្គមស្លេកស្លាំងរបស់នាង។
«ខ្ញុំមកនេះមកមើលឯងមុនពេលឯងចេញទៅផ្ទះ!»មេធាវីបាត់សិទ្ធិ បញ្ឈប់ត្រង់នេះ ព្រោះមិនចង់បន្តថាពេលសក្ខណាទៅដល់ផ្ទះនាងពិបាកក្នុងការទៅជួប សួរសុខទុក្ខ។ តែនឹកឃើញដល់រឿងមួយនាងនិយាយបន្ថែម៖
«យ៉ាងណាក៏ដោយ ខ្ញុំនៅតែព្យាយាម ខ្ញុំចង់ជួបម៉ាក់ធំពន្យល់គាត់! ខ្ញុំត្រូវជួយយុត្តនា ព្រោះជំនួយការវិទ្ធិយល់ខុសថាយុត្តនាធ្វើបាប ហួត ស៊ីវ គេកំពុងចាញ់បញ្ឆោតប៉េង បើបណ្តោយតែអញ្ចឹងគេនឹងវិនាសព្រោះតាប៉ិនោះ! ទោះបងប្រាថ្នាមិននៅ តែម៉ាក់ធំដឹងច្បាស់ថាគាត់ជាអ្នកធ្វើឲ្យ ហួត ស៊ីវ ដួល គាត់គួរតែនិយាយប្រាប់ភាគហ៊ុនអស់នោះពីរឿងនេះ!»
សក្ខណាងាកមកវិញរឹង៖
«ជំនួយការវិទ្ធិហ្នឹង?....ក្រែង....ក្រែងគេជាប់ក្នុងដៃជនពាលនៅឡើយ! ហើយ....ហើយ....គេមកវិញពីអង្កាល់?»
ពៅបញ្ញាដកដង្ហើមធំ នាងនៅចងចិញ្ចើមបន្តិចទម្រាំនិយាយចេញ៖

«គេនោះ តាមពិតជាកូនធម៌ទីពីររបស់អគ្គទេសាភិបាល ហួត ស៊ីវ! គេនិងយុត្តនាលាក់យើងរហូតមក! គេមកវិញពីពេលណាយើងមិនដឹងទេ តែឥឡូវដឹងតែគេនោះព្យាយាមដណ្ដើមតំណែងរបស់យុត្តនា ព្រោះចាញ់បញ្ឆោតលេខាប៉េងដែលនៅពីក្រោយភាគហ៊ុនទាំងអស់ឲ្យពីរនាក់ គេត្រៀមគម្រោងប្រកួតគ្នាអាទិត្យក្រោយនេះ រឿងដែលសំខាន់នោះគឺគេមានសមត្ថភាពជាងបងគេ គេមុខជាឈ្នះចិត្តភាគហ៊ុនទាំងនោះ ប៉ុន្តែពេលតំណែងនោះដល់ដៃគេអ្វីៗនិងរលាយព្រោះលេខាប៉េងនៅពី ក្រោយគម្រោងការអស់នោះ ហើយគេមិនដឹងទេ! បងប្អូនគេឈ្លោះគ្នា! ពេលគេមកវិញលើកនេះតែខ្ញុំក៏គេមិនគោរពដែរ គេផ្លាស់ប្ដូរចរិតទៅជាកោងកាចនិយាយគ្មានហេតុផលហើយមានៈលោភលន់!គេ មានស្នាមរបួសខ្លះនៅលើខ្លួននិងមុខមិនដឹងថាទារុណកម្មក្នុងព្រៃ នោះពាក់ព័ន្ធដល់សរសៃប្រសាទគេដែរឬយ៉ាងណាទេ!?

សក្ខណាមិនមាត់សូម្បីតែមួយម៉ាត់ តែនាងនឹកឃើញដល់ទិដ្ឋភាពចុងក្រោយមុនពេលនាងចាកចេញពីភ្នំពេញ។ គឺនាងបានសង្ស័យហើយបើកឡានតាមគេដល់ទីលានកូនគោល គេបានលួចជួប ហួត ស៊ីវ ហើយឲ្យរបស់ម្យ៉ាងទៅគាត់តាមពិតគេគឺជាឪពុកនិងកូនមែន។

«ចុះបើគេជាកូនផ្ទះនោះ ជាអ្នកប្រុសធនាគារហើយគេមកធ្វើជំនួយការត្រុកៗធ្វើអី?»

«គេចង់បានអ្វីម្យ៉ាងក្នុងដៃប៉ាយើងទៅឲ្យប៉ាគេ!»នាងនិយាយទាំងស្រងូត។

«ស្អីទៅ? ឡប់មែនហើយ!»សក្ខណាសួរទាំងមុខខឹង។ នាងបន្ថែមៈ

«កោតតែប៉ានិងឯងទុកចិត្តគេយ៉ាងនេះ!»

«ការពិតគេមកនៅយូរហើយ! មានអ្នកណាដឹងថាគោលដៅគេគឺ Projectរតនៈសោភ័ណនោះទៅ?»

សក្ខណានឹកដល់ភាពរហ័សរហួននិងឆ្លៀវឆ្លាតរបស់គេ ប្រសិនបើគេពិតជាមានបេសកកម្មបែបនេះមែនក៏មិនងាយឲ្យអ្នកណា សង្ស័យបានដែរ។

«យើងជាស្រីៗពិតជាទន់ខ្សោយហើយល្ងីតល្ងង់ពេកហើយ! ហេតុអ្វីឆាប់ទុកចិត្តមនុស្សដូចគេ?តាមពិតគេជាមនុស្សអាក្រក់ដល់ ថ្នាក់សុខចិត្តធ្វើជនបង្កប់ដ៏មានពុត! គេជាមនុស្សពូកែពុតស្រាប់ហើយ!ទាំងនៅភូមិជនជាតិគេចេះធ្វើពុតជា ស្រវឹងនិងនិយាយកុហកក៏មិនព្រិចភ្នែក! យើងតាមគេមិនទាន់ទេ!»

ដោយទុក្ខសោកធីតាក៏នឹកឃើញដល់អក្សរគេលើកញ្ចក់បន្ទប់ទឹក។ នាងសួរខ្លួនឯងស្ងាត់ៗ«តើគេខឹងយើងពេកទើបក្លាយជាអញ្ចឹងឬមួយ ក៏គេត្រូវថ្នាំញ៉ូវញាក់នោះធ្វើបាប?»

នារីងាកមករកប្អូនស្រីហើយពោលៈ
«ពៅបញ្ញាឯងជួយរកក្រដាសស្អិតមកខ្លះឲ្យខ្ញុំបានទេ?»

ពេលពៅបញ្ញាចេញផុតម្ដាយនិងបងស្រីនាងបានមកទទួលនាងចាកចេញពី ពេទ្យ។ ស្រីតូចសរសេរក្រដាសតូចៗបិទលើកញ្ចក់បន្ទប់ទឹកមុនពេលនាងចាកចេញ« ខ្ញុំមិនបានក្បត់សន្យាទេ ប៉ុន្តែពួកគេពិតជាមិនឲ្យខ្ញុំទៅរកលោកមែន! រយៈពេលនេះ ខ្ញុំក៏មិនដែលបានសប្បាយចិត្តដូចគ្នា!»
នាងវិលមកផ្ទះវិញហើយសំងំក្នុងបន្ទប់តែចិត្តនាងហោះហើរនឹកទៅដល់ បុរសនោះ។ នារីអង្គុយលើគ្រែ ដៃស្ទាបប្រអប់ជើងដែលធ្លាប់ត្រូវបានដៃគេរឹតប្រេងថ្នាក់ថ្នមនាង រហូតដល់ជាសះស្បើយ។នាងនឹកដល់ខ្លួនប្រាណគេដែលអៀវនាងរត់កាត់ព្រៃ ស្វាត់ ពន្លឺភ្នែកបង្កប់នែអាថ៌កំបាំង ដែលធ្លាប់សម្លឹងគ្នាចង់ឲ្យបំភ្លេចវាមិនមែនជារឿងងាយៗឡើយ តែបើគេពិតជាបំភ្លេចនាងបានមែនចិត្តគេគឺរឹងមាំពេកហើយ ។
ស្រីតូចនឹកដល់សន្លឹករូបថត ពៅបញ្ញាដែលជ្រុះចេញពីអាវគេ នាងតម្អូញក្នុងបេះដូងតែម្នាក់ឯង «គេស្រលាញ់ពៅបញ្ញាយ៉ាងនេះ គេគង់តែហ៊ានមិនគោរពនាងតើគេជាមនុស្សអី ត្រលប់មកវិញមានបញ្ហាអីបានជាក្លាយជាដូច្នេះ?»
នាងទាញភួយមកដណ្ដប់ ហើយផ្អែកខ្នងល្វិតល្វៃទៅលើសាឡុងទល់មុខគ្រែដំណេក។ កន្ទុយភ្នែកបែរជាឃើញអ្វីមួយគួរឲ្យភ្ញាក់ផ្អើល....នាងងាកភ្លែតទៅ រកប្រភពនោះ....អ្នកណាម្នាក់កំពុងអង្គុយគងជើងធ្វើហីហើយដៃបើក ប្រអប់បញ្ញាទូរទស្សន៍ចុចមើលមិនខ្វីទាំងខ្វល់ប្រតិកម្មរបស់ម្ចាស់ បន្ទប់.....
នារីស្ទុះក្រោកឈរទៅហើយ នាយនៅតែអង្គុយធ្វើមិនដឹង មិនបែរមក តែស្នាមញញឹមលេចចេញលើបបូរមាត់ និងថ្ពាល់ខាងស្ដាំដែលនៅសេសសល់ស្លាកស្នាមរបួសខ្លះនៅឡើយ....
....សក្ខណានិយាយអីមិនចេញ គឺនាងឈរទ្រឹងសម្លឹងគេ....ព្រោះមិនដឹងថាគេចូលមកទីនេះបានដោយ របៀបណា ពីថ្មើរណា ហើយតើអាងអ្វី បានជាប្រើប្រាស់ទូរទស្សន៍របស់នាងតាមចិត្ត?
តែនាងនៅតែនិយាយមិនចេញមានតែ បើកភ្នែកមូលក្លុំសម្លឹងគេ រហូតដល់គេដាក់ប្រអប់បញ្ញាចុះ ហើយក្រោកដើរមករកនាង។
អ្នកប្រុសទីពីរបង្ហាញខ្លួនដោយឥតព្រាងទុក ហើយសម្លឹងនាងដោយទឹកមុខឌឺដង។

«បែកគ្នាប៉ុន្មានថ្ងៃ មុខអីក៏ស្លក់លឿនម៉េះ?»
គេសួរច្បាស់ៗតែស្រាលៗ។ សម្ដីកំបុតៗគ្មានងារគ្មានការខ្លាចចិត្ត តែខ្សែភ្នែកនៅតែស្រទន់។
ស្រស់ស្រីនៅតែឈរទ្រឹងសម្លឹងគេមិនដាក់ភ្នែក....គ្មានចម្លើយតប....រិទ្ធិពោលបន្ត៖
«អម្បាញ់មិញនេះនឹកពីណាគេ?»
ស្រីតូចចេញចំហាយអៀនខ្មាសតាមស្បែកមុខក្រហមរលោងរបស់នាង នាងងាកមុខទៅទីផ្សេងតែរកពាក្យនិយាយតបមិនទាន់បាន ស្រាប់តែដៃគេលូកមកស្រាក់ចង្កេះនាងធ្វើឲ្យសក្ខណាភ្ញាក់ព្រើត បម្រះចេញមួយទំហឹង។ ខាងប្រុសទ្រេតទ្រោតទៅម្ខាងព្រោះមិននឹកស្មានថានាងមានប្រតិកម្ម អវិជ្ជមានដល់ថ្នាក់នេះ គេបើកភ្នែកគ្រលួងសម្លឹងមកនាងដោយងឿងឆ្ងល់ ស្រីតូចពោលឡើងទាំងទឹកមុខច្របូកច្របល់៖
«លោកជាអ្នកណា? ហើយលបចូលមកបន្ទប់នេះ ដោយរបៀបណា?»
រិទ្ធិសម្លឹងនាង ទឹកមុខគេប្ដូរមកជាញញឹមសន្សឹមៗហើយសាជាថ្មីដើរចូលមករកស្រីតូច ធ្វើឲ្យនាងថយក្រោយក្រាករហូតទើរនឹងសាឡុង។ អ្នកប្រុសទីពីរច្រត់ដៃទាំងទ្វេសងខាងបង្អែកសាឡុងរុំព័ទ្ធរាងកាយ នាងឲ្យនៅក្នុងការឃុំគ្រងរបស់អ្នកហើយប្រើភ្នែកទាំងគូសម្លឹង មុខនាងនិងបបូរមាត់ដែលខាំស្មើរដាច់។ នាងសម្លក់គេយ៉ាងណា តែស្នេហារបស់នាងនៅតែបង្កប់មកក្នុងប្រស្រីភ្នែកភ្លឺដូចនិល ថ្មៃ។
«កន្លែងណាក៏ដោយ ឲ្យតែមាននាង ខ្ញុំទៅដល់បានជានិច្ច ប៉ែន ពេជ្រសក្ខណា!»
គេនិយាយខ្សាវៗបញ្ឈឺនាង ហើយលើស្នាមញញឹមលើបបូរមាត់នាយ ធ្វើឲ្យស្រីតូចមិនអាចទប់ថាមិនតបតឡើយ៖
«ហើយលោករកខ្ញុំធ្វើអី? យើងមានការអីជាមួយគ្នា?»
គេក្រឡេកមករកកែវភ្នែកនាងទាំងសងខាង ៖
«មែនអ្ហេស៎?»
ស្រីតូចខំសម្លឹងគេត្លែជាសញ្ញាថា នាងមិនចាញ់សម្ដុតនាយ ហើយនាងនៅតែជាអ្នកនាងធំដូចកាលពីមុន ប៉ុន្តែដោយខ្សែភ្នែកនាយទន់ពេក មមីពេក នាងទៅជាឆ្លេឆ្លាក្នុងចិត្ត។ នាងក្ដាប់មាត់ងាកមុខចេញហើយនិយាយខ្លីៗ៖
«អាទិត្យក្រោយនេះខ្ញុំនឹងឡើងយន្តហោះទៅអាមេរិកវិញ! ចាំមើលតើលោកសុខចិត្តចោលគម្រោងការ បន្លំខ្លួន គម្រោងការដណ្ដើមតំណែងគ្នា គម្រោងការចង់បានរបស់អ្នកដទៃ

ហើយទៅតាមរកខ្ញុំដល់ទីនោះដែរ?»
«សាកមើលសិនទៅ ថាទៅបាន មិនបាន?»គេនិយាយទាំងញញឹមត្រជាក់ស្រេបដាក់ស្រី ស្អាតដែលមានផ្ទៃ មុខឃ្លាតគ្នាមិនដល់មួយចំអាមផង។ ការនៅជិតគ្នាកាន់តែកៀក កាលគ្រា កម្សត់កម្រក្បែរគ្នាទាំងប៉ុន្មានកាលពីនៅក្នុងព្រៃ ភ្នំក្រមថ្ម ហាក់ត្រូវបានរំលឹកមកវិញនាំឲ្យស ង្វាក់បេះដូងនាងលេចឡើងនូវសញ្ញា រំជើបរំជួល តែសមាសភាពពិតរបស់នាយក្នុងនាមជា អ្នកប្រុសទីពីររបស់ ហួត ស៊ីវ ធ្វើឲ្យបេះដូងបរិសុទ្ធទៀងត្រង់របស់នាងត្រូវឈឺផ្សា។ នារីនិយាយទាំងតូចចិត្ត៖
«លោកដឹងហើយ មនុស្សខ្ញុំ និយាយគឺធ្វើ! ខ្ញុំថាទៅ គឺទៅ!»
គេសម្លឹងផែនថ្ពាល់រលោងម៉ត់ទាំងសងខាងរបស់នាងក៏នឹកដល់ពេលដែល នាងខឹងហើយ ចាកចេញពីខ្ទមឆ្ពោះទៅកន្លែងហាមឃាត់របស់ពួកកុលសម្ព័ន្ធ ទាំងយប់។ បងប្អូនគេនេះកើត មកឆ្នាសៗហើយចិត្តរឹងមួយបេនដូចគ្នា គ្រាន់តែថាពៅបញ្ញាមានហេតុផលជាង នាងគួរឲ្យ មនុស្សប្រុសគោរពខ្លាចចិត្ត ចំណែកស្រីម្នាក់នេះគ្មានហេតុផលតែគួរឲ្យក្នាញ់ សម្រាប់ឲ្យ មនុស្សប្រុសតាមស្រលាញ់។
គេនិយាយតបវិញស្រាលៗ៖
«តែស្ដាយណាស់! នាងបានជ្រុលជាស្រលាញ់ខ្ញុំទៅហើយអ្នកនាងតូច!» គេនិយាយទាំងញ ញឹម។
«អត់ទេ!» នាងខាំមាត់។
«ខំកុហកគេអញ្ចឹងស្មានថាបានការអីទៅ?»
«ព្រោះខ្ញុំអញ្ចឹងស្រាប់ហើយ! ថ្ងៃមុនស្រលាញ់ ថ្ងៃនេះក៏ដូរមកជាស្អប់បាន កុំថាឡើយមនុស្ស អាក្រក់ដូចលោក មនុស្សមានល្បិច!»
នាងគេចមុខចេញតែគេទាញមកវិញ ដូច្នេះនារីរើមិនបាន ក៏វាចាបន្តតាមទំហំចិត្តខឹង៖
«ខ្ញុំមិនចង់រញ៉េរញ៉ៃទេ!!! ទុកថាខ្ញុំអត់ឃើញលោកទៅចុះ! ឆាប់ចេញទៅវិញទៅ!
«ស្ដាយត្រង់ថា ខ្ញុំនេះកើតមកមិនចេះធ្វើតាមបញ្ជាអ្នកណាផ្ដាសទេ ពិសេសមនុស្សស្រី ដែល ជាប្រពន្ធខ្ញុំ!»
តរុណីអភិជនគេចភ្នែកចេញពីខ្សែភ្នែកនរៈ ប៉ុន្តែបេះដូងនាងឈឺឆៀបនឹកឃើញដល់គ្រាមួយ ក្នុងព្រៃជ្រៅកណ្ដាល ពរជ័យរបស់អ្នកភូមិ ពួកគេបានសែនព្រេនជាគូជីវិតទៅតាមប្រពៃណី ចម្លែកៗនៅទីនោះ។ កាលណោះបេះដូងនាងបានចុះចាញ់ក្រោមកាយវិការស្និទ្ធស្នាលយក

ចិត្ត ទុកដាក់របស់នាយទៅហើយដឹងអីទីបំផុតគេក្លាយជាមនុស្សអាក្រក់ ដែលចិញ្ចឹមចិត្ត បំផ្លាញប៉ានាងទៅវិញ។ អ្វីៗគឺក្លែងក្លាយស្រាប់ហើយសម្រាប់បុរសនេះ នាងដឹងថាគេអាចធ្វើពើបានល្អគ្រប់រឿងរហូតដល់ម្នាក់ៗសុទ្ធតែ ហួសចិត្ត។ នាងកោតតែគេរំលឹកពាក្យប្រពន្ធមកវិញ ដោយមិនមានអៀនអន់ បានជាធីតាសើចខឹកទាំងរកកលរលើងរលោងរុញដៃគេរបូតចេញពីសាឡុង ហើយដើរទៅរកបង្អួច។

សំឡេងនាងលាន់តិចៗមកកាន់អ្នកប្រុសទីពីរដែលឈរពីក្រោយ៖

«ហួត ខេមរិទ្ធិ អ្នកប្រុសទីពីរ! បន្តិចទៀត លោកក្លាយជានាយកធនាគារហើយ ស្រីៗមានច្រើនណាស់នៅរង់ចាំតោងលោក! រឿងរៀបការព្រៃភ្នំហ្នឹង លោកប្រឹងយកមកចងកខ្លួនឯងធ្វើអី បើខាងស្រីគេមិនទាំងស្តាយផងហ្នឹង?»

គេដើរចូលមកនាង ហើយទាញនាងឲ្យបែរមកវិញ នារីក៏មិនគេចចេញព្រោះចង់បង្ហាញថានាងគ្មានចិត្តទន់ហើយក៏គ្មាន អ្វីខ្លាចនាយដែរ។ បុរសញញឹមទៅរកខ្សែភ្នែកមុតថ្លារបស់ស្រីតូច គេនិយាយមួយៗ៖

«អ្នកនាងៗនៅផ្ទះឱកញ៉ា ប៉ែន ពេជ្រ កាចៗណាស់ហ្ន៎ សម្តីមួយម៉ាត់ៗ សម្បើមៗហ្មង!»

សក្ខណាញញឹមចុងបបូរមាត់ ជាសញ្ញាថានាងមិនទាន់អស់ចិត្តក្នុងការឌឺដងបញ្ឆេះគេនោះដែរ៖

«អត់ត្រឹមតែប៉ុណ្ណឹងទេអ្នកប្រុសទីពីរ! ខ្ញុំប៉ែន ពេជ្រសក្ខណា ក្រៅពីកាចឆ្នាសសម្បើម នៅថៃមមួយរឿងទៀត !»

គេញាក់ចិញ្ចើមសួរវិញទាំងញញឹមស្រាយ៖

«ស្អីទៅ?»

នារីខាំមាត់សើចហើយសម្លឹងគេចំ រួចទើបវាចាស្រាលៗ៖

«ខ្ញុំក៏សាវ៉ាសម្បើមដែរ!»

នៅពេលគេស្ងាត់មាត់ដូចត្រូវកន្សែងចុក ហើយបន្តញញឹមស្ងួតសម្លឹងមុខឌឺរបស់នាង តរុណីស្តីបន្ត៖

«នៅអាមេរិក ខ្ញុំមានសង្សារច្រើនណាស់! ហើយខ្ញុំពូកែភ្លេចបំផុត អ្វីក៏ដោយឲ្យតែមិនល្អ ខ្ញុំចាំវាអត់យូរទេ! សូម្បីរបស់របរទិញមកពីផ្សារ ឲ្យតែអន់ៗគឺខ្ញុំបោះវាចោលទៅក្នុងធុងសំរាមភ្លាម កុំថាឡើយ មនុស្សដែល.....»

នាងចង់បញ្ចប់ប្រយោគនេះ ប៉ុន្តែអ្វីមួយឲ្យនាងទប់មកវិញ ព្រោះមិនចង់បង្អើយឲ្យវាអសុរោះជាងនេះ។ នារីក្តាប់មាត់សម្លក់គេហើយយោងកាយតូចស្គមស្តើងដើរវាងចេញ តែដៃនាយលូកមកក្រៀកចង្កេះជាប់។ ទឹកមុខគេងងើលហើយភ្នែកគេគឺល្ហល្ហេវរហូតដល់នាងដឹងថាពេលនេះនាង ត្រូវតែប្រញាប់ចេញឆ្ងាយពីម្នាក់នេះ ប៉ុន្តែកម្លាំងដៃគេដែលក្រៀកចង្កេះនាងធ្វើឲ្យនាងយល់ថាវាហួសពេលទៅហើយ ។

ម្រាមនាងទាំងដប់ខំចាប់ទាញដៃគេសូម្បីតែមួយចំហៀងនេះឲ្យលែង ចេញពីចង្កេះក៏មិនទាំងរបេះផង កុំថាមកជួយថ្ពាល់ខ្លួនឯងដែលត្រូវម្រាមដៃនាយមួយចំហៀងទៀត លូកមកស្ទាបអង្អែល។

នារីបើកភ្នែកធំៗក្នុងពេលកែវភ្នែកអ្នកប្រុសទៅជាក្រហមបណ្តើរៗ ហើយសញ្ញារបស់គេគឺចង់លេបនាងទុកក្នុងបេះដូងទៅហើយ។

«លែងភ្លាម! ខ្ញុំស្រែកមែនណា!»

នាងសម្លុតគេតែប្រាណនាងចាប់ផ្តើមញ័រក្រោមពន្លឺភ្នែកបុរសម្នាក់ នេះ។ នាងគឺកូនចៀមក្នុងដៃនាយដែលមិនអាចចែកដាច់ថា នាងនៅស្រលាញ់នាយដែលជួយយកអាសានាងស្ទើរអស់ជីវិតឬស្អប់នាយដែល ចូលមកបោកប្រាស់គ្រួសារនាងច្រើនឆ្នាំមកនេះឡើយ។

បបូរមាត់នាយឱនមកជាមួយវាចាខ្សឹបៗ ហើយដង្ហើមនាយក៏ផុតៗដោយសារលង់ទៅក្នុងកាមារម្មណ៍៖

«នាងមានប៉ុន្មានវិនាទីសម្រាប់ស្រែក!....ស្រែកទៅ??? បើអត់ទេដល់វេនខ្ញុំម្តង ប៉ែន ពេជ្រសក្ខណា!»

នាងនៅបើកភ្នែកមូលក្លុំព្រោះរន្ធត់នឹងអាកប្បកិរិយានាយ នាងស្រែកមិនកើតនិយាយមិនចេញ ហើយបបូរមាត់អ្នកប្រុសទីពីរលោមក ក៏នាងមិនគេចចេញ ....នាងដឹងថា នាងមិនបានចាញ់សម្លុតគេទេ ប៉ុន្តែបេះដូងនាងពិតជាត្រូវការស្នេហានេះ ហើយដៃគេដែលស្រាក់មកក្នុងម្រាមដៃនាងនិងទប់ចង្កេះនាង បាននាំរុញឲ្យរាងកាយនាងផ្តួលទាំងស្រុងទៅលើគេ ចំណែកអតីតកាលដ៏ផ្អែមល្ហែតបានវិលមកវិញដូចនៅថ្មីៗ។

អ្វីជុំវិញនេះបានក្លាយជាខ្ទមតូចកណ្តាលព្រៃដែលមានតែក្លិន បុប្ផានិងសន្សើមរាត្រីត្រជាក់ដល់ឆ្អឹងគ្មានអ្នកណាដឹងនិងអ្នក ណាបានឃើញពីការចែករំលែកដ៏អាថ៌កំបាំងរបស់ប្រុសស្រីទាំងទ្វេ ឡើយ។

នៅពេលដែលភាគីខាងបុរសបញ្ចេញដង្ហើមរោលរាលដូចអគ្គី១០០អង្សារគឺ ភាគីខាងស្រី

ដែលត្រូវភិតភ័យតក្កមា....សេចក្ដីស្នេហារបស់នាងនិងការ នឹករលឹកចំពោះនាយ ពីក្រោយស្រមោល អនុស្សាវរីយទាំងឡាយនោះ មិនអាចលោតរំលងការទទួលខុសត្រូវក្នុងនាមជាធីតា មកពីគ្រួសារដ៏តឹងរ៉ឹងមួយនេះឡើយ នាងប្រឹងណាស់ក្នុងការរុញគេចេញវិញក្នុងពេលបុរសនៅតែ ព្យាយាមរក្សាភាពជាប់ស្អិតដូចមិនចង់សូម្បីតែបណ្ដោយឲ្យនាង ដកដង្ហើមបានសេរីដោយគ្មានសង្វាក់បេះដូងគេលោតមកជាមួយគ្នា។
នាងច្រានគេចេញខ្លាំងបីបួនដង ទើបគេព្រមរង្គើហើយដាច់ចិត្តដកបបូរមាត់ចេញទៅវិញ តែក្រឡេកមកប៉ះភ្នែកនារីកាលណា អ្នកនឹកឃើញសូម្បីតែពេលជួបគ្នាដំបូងដែលនាងច្រត់ចង្កេះស្រែកថា ឲ្យអ្នកក្ដែងៗនៅដងផ្លូវសាធារណៈ ហើយរាត្រីត្រជាក់ល្ហឹមដែលនាងមកគេងលើគ្រែអ្នកហើយលូកដៃមកគង អ្នក តែត្រូវទទួល វិញមួយជើងកូនប្រុសធ្លាក់ទៅលើកម្រាលព្រំ ចុងក្រោយគឺកែវភ្នែកដែលសម្លឹងមកនាយមុនពេលសម្រេចចិត្តឱនទៅក្រេប ស្រាជនជាតិជាមួយគ្នា។
ស្រីនេះឆ្នាសឆ្មើមសម្បើមឫកសម្ដីខ្ពស់ហួសមេឃគួរឲ្យចង់បង្ក្រាប ពេកហើយ....អ្នកប្រុសមិនអាចដកចិត្តចាកចោលក្លិនបុប្ផាក្រពុំដែលនៅ ដិតដាមលើរាងកាយនាងតូចម្នាក់នេះបានទេ ដូច្នេះហើយបានជាគេនៅតែលោច្រមុះតម្រង់ទៅវាតទីលើស្មានាង ធ្វើឲ្យនាងឆ្លេឆ្លាពោលឃាត់៖
«ឈប់ភ្លាម ណា៎!»
អ្នកប្រុសទីពីរមិនសូវចេះនិយាយស្ដី តែចិត្តក៏មិនងាយទន់ដូចអ្នកប្រុសទីមួយ ហ្វួត យុត្តនាឡើយប៉ះពេលនេះដង្ហើមនាងដ៏សិចស៊ីកំពុងពង្វក់បេះដូងគេពេញទំហឹង ចង់ឲ្យលែងនាងចេញពីដើមទ្រូងក៏ប្រហែលមានតែយកកាំភ្លើងមកភ្ជង់ ដូច្នេះហើយគេនៅតែចចេសគ្រប់គ្រងរាងកាយស្រីស្រស់រហូតដល់នាងទាល់ តម្រិះនិយាយទាំងអណ្ដឺតអណ្ដក៖
«ហ្វួត ខេមរិទ្ធិ លែងខ្ញុំភ្លាម! ខ្ញុំស្រែកយំអាឡូវហើយ! ឮអត់!»
នាងគំរាមថានាងយំឥឡូវមែន ប៉ុន្ដែតាមពិតគឺនាងយំគគ្រូកជាស្រេចនៅចំពោះមុខនាយ។ គេលាដៃសន្សឹមៗ នៅពេលទឹកភ្នែកនាងប្រឡាក់ប្រឡូសច្រមុះនិងថ្ពាល់អ្នក។ អ្នកប្រុសទីពីរដឹងថា ការហាត់ក្បាច់វាយតប់តាំងពីតូចបានធ្វើឲ្យអ្នកក្លាយជាបុរសដែល គ្មានភាពទន់ភ្លន់ហើយកាយវិការអម្បាញ់មិញប្រាកដជាធ្ងន់ដៃដល់នាងតូចឈឺហើយ បានជានាងយំសស្រាក់បែបនេះ។
គេងើបមុខដែលប្រឹងទប់កំសួលស្នេហ៍ សម្លឹងនាងយឺតៗ ក្នុងពេលទឹកមុខនារីក្រហមដោយ

អៀននិងភ័យ។ ដៃនាយទាំងសងខាងនៅលើស្មានាងនៅឡើយ ដូច្នេះគេលាមកសន្សឹមៗតែមិនលែងទាំងស្រុងឡើយ៖
«បងនឹកអូនខ្លាំងណាស់!»
គេនិយាយតិចៗ ទាំងមិនដកភ្នែកពីនាង លុះឃើញនាងហាក់រំជួលចិត្តពេក ភ័យពេក គេនិយាយបន្ថែម៖
«បងស្រលាញ់អូន! សក្ខណា!»
គេទាញនាងមកឱបសាជាថ្មីក្បែរលង្វែកទ្រូង ក៏ជាពេលដែលភាគីខាងស្រីលែងបម្រះចេញទៅណាព្រោះលង់នឹងភាសាដែល បង្ហើរចេញពីបេះដូងនាយ។
«នៅថ្ងៃនោះ! ថ្ងៃដែលអូនចេញទៅជាមួយពួកវា បងគិតថា បងលែងមានឱកាសនិយាយពាក្យនេះប្រាប់អូនទៅហើយ! ទីបំផុតបានឱបអូនមែនហើយបាននិយាយពាក្យនេះឲ្យអូនស្តាប់!»
«មនុស្សកុហក....លោកកុហករហូតមក ខ្ញុំមិនជឿលោកទៀតទេ ខ្ញុំមិនជឿ!»
នាងនិយាយទាំងអណ្តឹតអណ្តក។ បុរសស្រងាកចិត្ត ....ភាពទុក្ខព្រួយលេចឡើងក្នុងពន្លឺភ្នែកគេក្នុងពេលគេទាញនាងឲ្យ មកប្រឈមមុខគ្នា។ គេសម្លឹងនាងដោយតូចចិត្ត។ តរុណីនិយាយបន្ថែមដោយសម្លឹងគេចំ៖
«បើមែន! លោកឈប់ទៅ! លោកធ្វើជាជំនួយការរិទ្ធិ ដែលស្លូតបូតដូចដើម! លោកធ្វើឲ្យគ្រប់គ្នា ឈប់គិតថាលើលោកនេះមានអ្នកប្រុសទីពីររបស់ ហួត ស៊ីវ ទៅ! លោកធ្វើបានអត់?»
គេនៅស្ងៀមទ្រឹងចំពោះមុខនាង ហើយទម្លាក់ដៃចេញពីស្មានាងសន្សឹមៗមុនពេលបែរខ្នងមកជំនួស។ សំឡេងគេលាន់មកតិចៗ៖
«ស្នេហារបស់នាងត្រូវតែមានលក្ខខណ្ឌ អ្នកនាងសក្ខណា?»
នារីមិនមាត់តែនាងជ្រួញចិញ្ចើមព្រោះតឹងតែងចិត្ត។ សំឡេងគេលាន់មកបន្ថែម ៖
«ខ្ញុំក៏មិនដែលទាមទារអីពីនាងទាំងអស់! បើស្រលាញ់គ្នាក៏ស្រលាញ់ទៅ ចាំបាច់អីមានលក្ខខណ្ឌមកជាមួយ?»
«តែលោកធ្វើមិនត្រូវ! លោកធ្វើខុស បានជា....»
នាងឈប់និយាយកណ្តាលទីព្រោះគេបានបែរមុខមកវិញ....អ្នកប្រុសទីពីរនិយាយយឺតៗ៖
«មនុស្សប្រុសគេមានការងាររបស់គេដែលមនុស្សស្រីមិនត្រូវមកលូកដៃ ទេ! ទោះនាងជាអ្នកនាងធំ ផ្ទះធំ កូនស្រីឧកញ៉ាក៏ដោយ នាងនៅតែជាប្រពន្ធដែលមិនគួរមកលូកលាន់កិច្ចការ

មនុស្សប្រុស នេះបើនាងចេះធ្វើជាមនុស្សស្រី»
«ហួសសម័យហើយ!»ស្រីតូចនិយាយកាត់។
គេសម្លឹងមកនាងដោយទឹកមុខស្មើ វាជាចរិតធម្មជាតិនៃបុរសម្នាក់ដែលស្រលាញ់នារីឋានៈខ្ពស់ម្នាក់ ហើយក៏រមែងតែមានចិត្តមានះចង់ឲ្យនាងទម្លាក់ចោលឲ្យអស់នូវឋានៈ សង្គមនិងភាពជាអ្នកនាង របស់នាង។
គេទម្លាក់អ្វីមួយទៅលើសាឡុងនាងហើយនិយាយៈ
«នេះកន្លែងខ្ញុំនៅ!! ហើយសោ ខ្ញុំទុកឲ្យនាង! ខ្ញុំរង់ចាំនាងជានិច្ច បើនាងយល់ថាត្រូវការស្នេហាមួយនេះ ...អ្នកនាងធំ!»
គេបែរខ្លួនទៅរករានហាលខាងមុខហើយបើកកញ្ចក់ដើរចេញទៅក្រៅ។ នាងដឹងហើយថាគេប្រាកដជាឡើងមកតាមទីនោះ....នាងរភ្នែកទាំងពិបាក ចិត្ត ហើយគោលដៅចុងក្រោយដែលនាងសម្លឹងក្នុងពេលបន្ទាប់គឺសន្លឹក អាសយដ្ឋាននិងសោដែលគេបានទម្លាក់ទុកឲ្យលើសាឡុង។

**ជំពូក១៩**

គម្រោងការអច្ចរិយៈ

រាត្រីវិលមកវិញ....ម៉ោង៨យប់ហើយ.....យុត្តនានៅក្នុងមន្ទីរពេទ្យដែល ស្ងាត់សូន្យមានតែស្នូរដង្ហើមតឹងតែងរបស់ឪពុកធម៌។ អ្នកប្រុសទីមួយអង្គុយសម្លឹងមុខ ហួត ស៊ីវ ដែលបិទភ្នែកជិតឈឹង....ថ្ងៃស្អែកជាការវិលមកវិញនៃបរិយាកាសប្រឈម មុខ រវាងនាយនិងពួកម្ចាស់ហ៊ុននៅធនាគារ....ដូច្នេះអ្នកដឹងថាយប់នេះ ប្រាកដជាគេងមិនលក់ទេ...ដែលត្រូវគិតនោះ គឺមិនមែនបារម្ភពីការបាត់បង់តំណែងទៅក្នុងដៃប្អូនប្រុសខ្លួនឡើយ ប៉ុន្តែគឺកាលដែលមនុស្សអាក្រក់នៅពីក្រោយរឿងនេះហើយគ្រប់គ្រង អ្វីៗបានដោយភាពទុច្ចរិតរបស់គេ។

«ប៉ា! លើកនេះគួរកូនអរគុណអាប៊ុលេខាប៉េងដែរទេ! បើអត់មានវាទេ កូនមិនដឹងខ្លួនឯងថាកូនប្រុសច្បងរបស់ប៉ាជាមនុស្សគ្មានបានការយ៉ាងនេះដែរឬ! កូនដើរលេងចោលប៉ាឲ្យនៅទទួលការងារម្នាក់ឯងធ្ងន់យ៉ាងនេះច្រើន យ៉ាងនេះជាយូរឆ្នាំមកហើយ ពេលនេះប៉ាសម្រាន្តបានប៉ុន្មានថ្ងៃ កូនធ្វើឲ្យអ្វីៗទៅជាផ្តេសផ្តាស! ប៉ាតែងគាំទ្រកូនរហូតមក ប៉ាជួយកូនហើយរៀបចំអ្វីៗឲ្យកូនកូនសុំប៉ាមួយបានទេ....ព្រឹកស្អែក នេះ ប៉ាគាំទ្រកម្លាំងចិត្តកូនម្តងទៀតទៅ

បានទេ! កូននឹងតស៊ូជាមួយឧបសគ្គនេះ ដល់ទីបំផុត ហើយប៉ាជឿទេថាកូនអាចបកអាក្រាត អាម្នាក់នោះបាន?»
នរៈសង្ហានិយាយតិចៗទាំងប្រើភ្នែកលួចល្ហៃសម្លឹងទៅលោកឪពុកដែលនៅ តែបន្តធ្មេចជិត ឈឹង។ គាត់រឹងមាំរាប់សិបឆ្នាំ ជាបុរសដ៏ជោគជ័យរាប់សិបឆ្នាំមកហើយ គ្រាន់តែគាត់ដួល គ្រេង កូនៗចាប់ផ្តើមមានបញ្ហា ហើយអ្នកផងដាក់ខ្សែភ្នែកសង្ស័យមកក្នុងក្រុមគ្រួសារនេះ។ នេះជាអ្វីដែលធ្វើឲ្យយុត្តនាឈឺចាប់បំផុតក្នុងនាមជាកូនប្រុស ច្បងម្នាក់។
គេវេភ្នែកសម្លឹងកាតាបធ្វើការរបស់ ហួត ស៊ីវ នៅលើតុក្បែរនោះ។ យប់នេះអ្នកប្រុសយកឯក សារការងាររបស់គាត់ដែលជាវត្ថុជិតស្និទ្ធពី មុនមកតែងនៅជាមួយគាត់គ្រប់ពេល មកដាក់ ក្បែរគាត់វិញក្នុងរាត្រីនេះព្រោះចង់រំលឹកមកវិញនូវ ទឹកចិត្តដ៏មោះមុតនិងស្វាហាប់ សម្រាប់ តស៊ូនឹងស្ថានភាពជំងឺរបស់គាត់។s

«យប់នេះកូនប្រុសប៉ាទំនេរណាស់ព្រោះប្រាកដជាគេងមិនលក់ទេ! អីចេះទៅ កូនអានរបាយ ការណ៍ជូនលោកប៉ាស្តាប់ស្ថានភាពទូទៅនៅធនាគារយើង កុំឲ្យលោកប៉ាអផ្សុកហើយធ្វើឲ្យ លោកប៉ាមានអារម្មណ៍ថាកំពុងបំពេញ ការងារដដែលដូចមុន! កូនដឹងថាប៉ាស្រលាញ់ការងារ ជាងជីវិតទៀត!!»
ហួត យុត្តនា ដែលពិបាកចិត្តយ៉ាងណាទឹកមុខនៅតែឱដងញញឹមស្រស់ស្រាយ ពេលនេះ ចាប់ឱនបើកកាតាបឪពុកហើយរើយកសំណុំឯកសារទាំងឡាយចេញមក។ របស់ដែលនាយ ចង់រកបែរជាមិនឃើញ ប៉ុន្តែក្នុងដៃបែរជាចាប់ប៉ះតែសំណុំសីមីមួយក្រាស់ហើយរឹង។ ម្តងហើយម្តងទៀតនាយតាំងចិត្តថាមិនរវល់នឹងវា តែមិនដឹងយ៉ាងម៉េចគេក៏នឹកឃើញបើកវា មកមើល។
«ស៊ីគេអ៊ីចេះ? គួរតែដឹងដែរថាមុនមានរឿង លោកប៉ាអាចថាមានគម្រោងការអ្វីថ្មីដឹង?»
គេស្រាយសីមីនោះមួយៗហើយលូករាវរកអ្វីៗពីខាងក្នុងនោះមកមើល។ វាមានតែក្រដាស ប៉ុន្មានសន្លឹកដែលល្អខ្លះទក់ខ្លះហើយគ្មានអ្វី រៀបរយឲ្យសមជាឯកសារផ្លូវការសំខាន់ឡើយ។
«គិតទៅមនុស្សចាស់ នៅតែមិនទាន់សម័យកាលសោះទោះគាត់ឋានៈធំដល់ម្លឹងនៅតែសរ សេរអ្វីៗ ដោយដៃ មិនវាយកុំព្យូទ័រ? តើអ្នកណាឃើញហើយជឿថាវាជាស្នាដៃរបស់ ហួត ស៊ីវ អគ្គទេសាភិបាលដ៏ល្បីនោះទៅ?»
គេគិតហើយសម្លឹងវាម្តងមួយសន្លឹកៗទាំងហួសចិត្ត។ អ្នកប្រុសគ្រវីក្បាលមួយៗ ក្នុងពេល

ដែលអ្នកមើលអ្វីលើនោះក៏មិនយល់ ព្រោះអក្សរមហាខ្មៀកហើយសរសេរដោយខ្មៅដៃទៀត។

«ឬមួយនេះជាអាថ៌កំបាំងរបស់អ្នកមានប្រាក់ទាំងឡាយ???? ឯកសារសរសេរខ្ចីខ្ចារបៀបនេះ ប៉ុន្តែលទ្ធផលការងារក្នុងសង្គមបែរជាលំដាប់កំពូល? ហើយបើសិនថាវាមិនមែនជាឯកសារអ្វីសំខាន់ចុះម៉េចក៏លោកប៉ាយកវា ជាប់ខ្លួនស្រោបសីមីត្រឹមត្រូវចងទុកម៉ត់ចត់ម្ល៉ឹងៗ»

អ្វីមួយបានទាក់ភ្នែកនាយហើយទាញអារម្មណ៍យុត្តនាដែលបាចសាចជាមួយ សំណួរផ្តេសផ្តាសវិលមកវិញដោយផ្តោតលើទិសដៅតូចមួយចំពីមុខខ្លួន។ នោះគឺជាផ្នែកមួយនៃសន្លឹកទីបួនដែលបង្ហាញនូវទម្រង់គំនូរអ្វី មួយព្រាលៗតែមានរូបរាងច្បាស់។

«អស្ចារ្យហើយលោកប៉ាចេះគូររូបទៀត?»

គេគិតទាំងធូរស្រាលក្នុងចិត្តហើយដៀងភ្នែកសម្លឹងឪពុកកម្សត់ដែលនៅ សំងំស្ងៀមមិនរវល់នឹងពិភពលោកនេះ។ មិនដឹងយ៉ាងម៉េចគេស្រាប់តែចងចិញ្ចើមសួរខ្លួនឯង៖

«មិនសមថាចុងក្រោយនេះ លោកប៉ាមានបំណងចង់ធ្វើវិនិយោគខាងសំណង់?»

គេងាកយ៉ាងរហ័សមករកសន្លឹកគំនូរដែលនៅលើដៃ ភ្នែកគេកាន់តែភ្លឺ គ្រាប់ភ្នែកក្រឡេកចុះឡើងពាសពេញនោះហើយចិញ្ចើមទាំងគូចងចូលគ្នា។

«មិនមែនទេ! តែរូបនេះដូចជាអ្វីមួយដែលយើងទើបតែបានឃើញ???»

យុត្តនាដាក់ភ្នែកទៅរក ចំណុចតូចមួយដែលមានសណ្ឋានរាវស្ទួចនៅពីលើរូបភាពក្នុងក្រដាស។នោះ ជាអ្វីដែលមានប្រសិទ្ធភាពឲ្យអ្នកនឹកឃើញមកវិញសន្សឹមៗ ពីកំពូលនៃសំណង់បុរាណមួយដែលមានរចនាបថជាខ្សែឆ្នូតៗ ត្រួតលើគ្នាហើយជួរនីមួយៗ បង្កប់ដោយរ៉ែថ្ម រាងមូលទ្រវែងតែថ្លាដូចកែវមានពណ៌ទឹកតែជួនភ្លឺជួនស្រអាប់។

គេរវៃភ្នែកគិតម្នាក់ឯង៖

«នឹកឃើញហើយ! នេះជារូបភាពចេតិយដែលសក្ខណាឲ្យយើងចូលទៅរករិទ្ធិ! កន្លែងនោះច្បាស់លាស់ យើងចំណាំវាបាន!»

សំណួរជាច្រើនលេចមកជាបន្តបន្ទាប់៖

«ហេតុអ្វីលោកប៉ាស្គាល់ចេតិយនោះហើយគូរវាចេញមកបាន? ឬមួយគាត់ធ្លាប់ទៅកាន់ទីនោះ?ចរិតគាត់មិនមែនមនុស្សស្រលាញ់ បុរាណវត្ថុទេ តើគាត់គូរវាទុកធ្វើអ្វី? ហេតុអ្វីគំនូរនេះត្រូវបានគេបង្កប់ទុកក្នុងសំណុំឯកសារនេះម៉ត់ចត់ ម្ល៉េះ?»

គេបញ្ចប់ភាពរាយមាយនៃចម្ងល់ហើយផ្តោតអារម្មណ៍ស្វែងរកតម្រុយ បន្ថែម។ អ្នកប្រុស

ទាញសន្លឹកទីប្រាំមកពិនិត្យប្រទះអក្សរជាច្រើនជួរតូចៗ ហើយញឹកស្មេររឹតតែមើលគឺរឹតតែទាញភ្នែកឲ្យព្រិល។
«អត់មែនជាអក្សរខ្មែរដាច់ខាត!! គេនិយាយយ៉ាងញាប់ហើយបើករកសន្លឹកបន្ត ប៉ុន្តែនោះជាសន្លឹកចុងក្រោយទៅហើយ។ អ្នកប្រុសក៏ពន្លាត់វា ហើយប្រទះឃើញជួរអក្សរតូចមួយនៅចុងបំផុតនៃទំព័រ។
«រតនៈសោភ័ណ»
គេបុកពោះភឹប បើកភ្នែកធំៗ ហើយរអ៊ូតិចៗម្នាក់ឯង៖
«ស្អីគេ???? គម្រោងការសំរៃរតនៈសោភ័ណនេះអ្វី?»
គិតអញ្ចឹងមែនប៉ុន្តែ គេចាប់ផ្តើមទាញទំព័រមុនៗត្រលប់មកមើលវិញ យ៉ាងញាប់គឺលើកមើលទៅមកៗរហូតដល់ស្នាមគូរទាំងឡាយដែលធ្លាប់តែ ក្រវេមក្រវាមបានប្រែរូបរាងទៅជាសណ្ឋានរូបភាពជាច្រើនក្នុងកែវភ្នែកនាយ។ ព្រៃរបោះ ភ្នំ ខ្ពង់រាប ដីវាលក្រឡាសេះ បានអណ្តែតមកជាបន្តបន្ទាប់ ស្របពេលដែលថ្វាសអ្នកជិតដាមមកដោយតំណក់ញើស។ មាត់គេរអ៊ូតិចៗ៖
«អស្ចារ្យណាស់! រតនៈសោភ័ណ!»
គេដាក់គូទប៉ុកទៅលើកៅអីអង្គុយសម្លឹងមើលយ៉ាងជក់ចិត្ត ហើយវង្វេងវង្វាន់រហូតដល់ពេលវេលាកន្លងទៅយូរប៉ុណ្ណាមិនដឹង ទើបគេងើបមុខសម្លឹងមករក ហួត ស៊ីវ។
អ្នកប្រុសទីមួយ ស្រវាចាប់ដៃឪពុកជាមួយវាចាប្រាប់ដ៏រំភើប៖
«ប៉ា! មុនពេលប៉ាឈឺ ប៉ាបានរបស់នេះមកមែនទេ? រតនៈសោភ័ណ! ប៉ាបានវាហើយ ប៉ាគិតវាយល់ហើយឬនៅប៉ា? កូនគិតយល់ហើយ កូនដឹងថាវាជាអ្វី !!! ហើយគម្រោងការនេះ អ្នកដែលសរសេរចង់ធ្វើវាដោយរបៀបណា កូនទើបតែយល់ គឺកូនយល់អស់ហើយប៉ា!»
នេះជាលើកទីមួយដែលអ្នកប្រុសរំភើបដល់ម្លឹង។ គេគឺមិនលោភលន់មិនខ្វល់ខ្វាយរឿងរកស៊ីអ្វីស្រាប់ហើយរឹតតែមិន ទទួលស្គាល់ពីភាពសំខាន់និងល្បីឈ្មោះរបស់គម្រោងការរតនៈសោភ័ណនេះ ដែរ។
រហូតដល់ចុងក្រោយ ហួត ស៊ីវ បានទទួលក្រដាសប៉ុន្មានសន្លឹកនេះពីកូនប្រុសទីពីរ ក៏គេមិនបានដឹងប៉ុន្តែរូបភាពដែលអ្នកផងយល់ថាក្រវេមក្រវាម ប៉ុន្មានសន្លឹកនេះត្រូវបានយុត្តនាមើលឃើញពីភាពមិនមែនជាគំនូរ ប្រក្រតីរបស់វា ។

តើលោករាជ ម្នាក់ក្នុងចំណោមមិត្តទាំងបីរបស់ ហួត ស៊ីវ ពិតជាបានខូចស្មារតីនៅមុនពេលសរសេរគម្រោងការនេះចប់ដូចការ សន្និដ្ឋានរបស់ប្ដីប្រពន្ធ ប៉ែន ពេជ្របុប្ផា មួយក៏អាចកំបាំងពិតរបស់គម្រោងអច្ឆរិយនេះត្រូវបានការពារ ដោយប្រាជ្ញារបស់អ្នកបង្កើតវា??? មនុស្សបរិសុទ្ធគ្មានស្រមោលពាណិជ្ជកម្ម គ្មានភាពលោភលន់តែមានស្មារតីវាងវៃរហ័សរហួនដូចអ្នកប្រុសទីមួយទេ ដឹង ដែលអាចបំបែកវិញ្ញាសារបស់លោករាជបាន?

គេនិយាយបន្ថែមទាំងក្ដាប់ដៃឪពុកណែនជាងមុនៈ

«ប៉ា! វាមិនមែនជា Projectស្រែៗដូចកូនបានគិតទេ! កូនគិតយល់ហើយ! វាពិតជាអស្ចារ្យណាស់! ប៉ាក្រោកឡើងប៉ា!!! ក្រោកមក!!! កូននឹងពន្យល់ពីអ្វីដែលម្ចាស់វាចង់ធ្វើ!!! ប៉ាក្រោកឡើងមក!»

គេខ្សឹបខ្សៀវស្រែកហៅឪពុកអស់ចិត្តអស់ចង់ទៅតាមភាពរំភើបរបស់ ខ្លួន....ហួត ស៊ីវ ក៏នៅតែគ្មានសញ្ញាទទួលដឹងនូវអំណររបស់កូនប្រុសឡើយ។ យុត្តនាដកដៃចេញពីគាត់សន្សឹមៗ ព្រោះគេនឹកឃើញដល់មនុស្សមួយចំនួនដែលបានទៅដល់ចេតិយនោះដូចគ្នា។

អ្នកប្រុសដើរទៅរកបង្អួចហើយលើកដៃចុចទូរសព្ទៈ

«អាឡូ!........»

ទ្រូងនាយលោតញាប់ក្នុងពេលគេកំពុងទាក់ទងទៅរកមនុស្សម្នាក់ទៀត នេះ....តែបើគេងាកមកក្រោយវិញគេប្រហែលជាត្រូវលោតញាប់ជាងនេះ ព្រោះថានៅឯណោះ ហួត ស៊ីវ ចាប់ផ្ដើមកម្រើកចិញ្ចើម....កន្ត្រាក់បបូរមាត់...ហើយបន្ទាប់មកគឺចុងដៃ គាត់....មុននេះគេបានចម្លងដោយជោគជ័យនូវជំនឿចិត្តនិងសុទិដ្ឋិនិយម របស់គេទៅឲ្យគាត់....គេគិតមិនដល់តែគេបាន ធ្វើវាដោយប្រយោល ទៅហើយ....លោកនេះពិតជាមានអព្ភូតហេតុ ហើយភាគច្រើនអព្ភូតហេតុល្អៗទាំងនោះបានរត់រកមនុស្សល្អៗក្នុងវិនាទីដែលគេ លំបាកបំផុត....ដូចយ៉ាងគម្រោងការរតនៈសោភ័ណជាវត្ថុដែលគាត់តាមរកពេញ មួយជីវិតមកហើយ....ដោយសារពេលវេលាកន្លងមកយូរពេក មនុស្សខ្លះបានបំភ្លេចវា មនុស្សខ្លះ មិនជឿវា តែ ហួត ស៊ីវ នៅតែយល់ថាមិត្ត ដែលគាត់គោរពជាងគេពិតជាមានសមត្ថភាពក្នុងការបង្កើតគម្រោង ពាណិជ្ជកម្មមហាសាលនេះ។

យុត្តនាមិនបានដឹងទេថា គ្មានឱសថអ្វីឲ្យសក្ដិសិទ្ធិសម្រាប់ ហួត ស៊ីវ ដែលកំពុងដេកស្ដាប់នាយ ស្មើនឹងភាពទាក់ទាញដ៏មហិមារបស់វត្ថុនេះទៀតឡើយ។

«ត្រូវហើយ គឺខ្ញុំ!....ស្តាប់ឲ្យច្បាស់ខ្ញុំចង់និយាយពីចេតិយក្នុងព្រៃនោះ គឺកន្លែងហាមឃាត់របស់កុលសម្ព័ន្ធ.....»
មិនដឹងគេនិយាយជាមួយអ្នកណាទេ ប៉ុន្តែប្រាកដជាមនុស្សដែលធ្លាប់បានទៅដល់កន្លែងនោះ នឹងជាមនុស្ស ដែលគេអាចទុកចិត្តបាន....ពៅបញ្ញា? សក្ខណា? ប្អូនប្រុស ហួត ខេមរិទ្ធិ?

———————————-

ពន្លឺហ្វាឡានចាំងឆ្វាចកាត់ស្បៃរាត្រី...ឈប់ស្ងៀមនឹងបន្ទាប់ពីរេចុះឡើងបានមួយស្របក់....បន្ទាប់មកពន្លឺរលត់ទៅបន្សល់នូវរាងកាយស្គមស្តើងនៃនារីម្នាក់ ដែលទម្លាក់សក់វែងក្រាលគ្របខ្នងនាង។
នេះជាកន្លែងស្នាក់នៅថ្មីរបស់អ្នកប្រុសទីពីរ ហួត ខេមរិទ្ធិ បន្ទាប់ពីគេបានបាត់ខ្លួនហើយវិលមកវិញដោយអាថ៌កំបាំង....។
ស្រីតូចសក្ខណាបង្ហាញខ្លួនទាំងកណ្តាលរាត្រីនៅទីនេះដោយទឹកមុខ ស្រពោន។....នេះជាសង្កាត់ស្ងប់ស្ងាត់នៅក្រៅក្រុងមួយ ប៉ុន្តែភាគច្រើនជាគោលដៅនៃក្រុមអ្នកមានទ្រព្យសម្បត្តិប៉ុណ្ណោះ។
ដោយមានសោដែលគេទុកឲ្យ ដូច្នេះការចូលទៅក្នុងផ្ទះដោយមិនចាំបាច់ឲ្យដំណឹងម្ចាស់ ជាអ្វីដែលនាងកំពុងធ្វើ.....
ស្រីតូចចុចភ្លើងបំភ្លឺគេហដ្ឋានដែលតូចច្រឡឹងតែស្រស់ប្រណីត....អ្នក ប្រុសទីពីររបស់ ហួត ស៊ីវ ពិតជាមានការរស់នៅយ៉ាងស៊ីវិល័យ ខុសពីភាពបិទបាំងរបស់គេក្នុងនាមជាជំនួយការម្នាក់កាលពីមុន។....នឹក ដល់ចំណុចនេះចិត្តនាងកាន់តែខ្វេចខ្វី....ណាមួយជាតិក្រអូបដែលបុរស តែងតែមានជាប់ខ្លួនហើយនាងនៅចំណាំបាន បានធ្វើឲ្យនារីនឹកឃើញដល់ពេលមួយដែលនាងច្រឡំបន្ទប់ទៅផ្តេក ខ្លួនលើគ្រែរបស់គេ ហើយត្រូវគេពន្លែងមួយជើងប៉ើងមកលើឥដ្ឋ....
នាងឱបដៃបន្ថែមសេចក្តីក្លាហានឲ្យខ្លួនឯងហើយរេភ្នែកសម្លឹងជុំវិញ ទីនេះ....នាឡិកាលើជញ្ជាំងបង្ហាញម៉ោង៧យប់ជាពេលដែលនាងយល់ថា នាងមានពេលច្រើនក្នុងការធ្វើអ្វីមួយនៅទីនេះ។
«អ្នកប្រុស ខេមរិទ្ធិ ទើបតែចេញទៅ! គាត់ទៀងពេលណាស់!!! រាល់យប់គាត់ត្រលប់មកវិញម៉ោង៩!អ្នកនាងចូលទៅទាល់តែចាំយូរបន្តិច ហើយ!»

នេះជាអ្វីដែលនាងបានទទួលពីសន្តិសុខនៅខាងក្រៅ។
«ខ្ញុំរកវាឃើញមុនពេលលោកវិលមកវិញ!»
នាងប្រាប់ខ្លួនឯងហើយរវៃភ្នែកមើលអ្វីៗជុំវិញខ្លួនយ៉ាងរហ័ស។ ក្រៅពីទូរទស្សន៍និងគ្រឿងសង្ហារិមបន្តិចបន្តួច នាងរកមិនឃើញកុំព្យូទ័ររបស់គេទេ។ នាងអន្ទះសាហើយអើតរកមើលទ្វារទៅកាន់បន្ទប់មួយផ្សេង។
នៅទីនោះមានទ្វារបន្ទប់ពីរមួយបិទជិតនិងមួយទៀតទ្វារមិនបានបិទ ទាំងស្រុងទេ ដូច្នេះនាងអាចសម្លឹងទៅឃើញតុធ្វើការមួយនៅទីនោះម្ល៉េះហើយនាង ដាច់ចិត្តឈានទៅ....
កុំព្យូទ័រពិតជានៅទីនោះ ពេលនាងបើកភ្លើងឡើង។
កុំព្យូទ័រមិនបានដោតភ្លើង ប៉ុន្តែវាមានលក្ខណៈដូចទើបតែត្រូវបានប្រើប្រាស់រួច ដែលម្ចាស់វាមិនបានរៀបរយទុក....ស្រីតូចបែរក្រោយមួយជុំដើម្បីឲ្យ ប្រាកដថាទីនេះគ្មានមនុស្សណាម្នាក់។
នាងបែរមកវិញហើយស្ទុះចូលកៅអីធ្វើការរបស់គេដោយចាប់ផ្ដើមបើកប្រើកុំព្យូទ័រគេ....
....បេះដូងនាងលោតញាប់ហើយងើបមុខសម្លឹងទៅសួនខាងក្រៅតាម បង្អួច....សួនច្បារងងឹតហើយគ្មានសូម្បីតែស្រមោលមនុស្សម្នាក់....នាងងើប ដើរទៅបន្ទប់ធំខាងក្រៅហើយចុចភ្លើងបិទវិញដូចដើម....មុនពេលត្រលប់ មកដល់តុ នាងក៏បិទភ្លើងបន្ទប់នេះវិញដូចគ្នា។
....កុំព្យូទ័រល្មមដល់ពេលប្រើប្រាស់បានហើយ...ប៉ុន្តែដូចនាងស្មានគឺគេបានចងលេខសម្ងាត់ការពារវាជាស្រេចទៅហើយ....
ម្រាមដៃរាវស្គមរបស់កូនស្រីឧកញ៉ា ប៉ែន ពេជ្រ ដាក់ទៅលើ Keyboard ហើយនាងចាប់ផ្ដើមសាកល្បងលេខសម្ងាត់មួយចំនួនតាមដែលនាងនឹកឃើញ។ ស្រីស្អាតរអ៊ូតិចៗភិតភ័យអន្ទះសា៖
«អត់បានការទេ! គ្មានផ្លូវឡើយ! យើងធ្វើអីគេមិនបានទាំងអស់!»
នាងលើកដៃចុចទូរសព្ទហើយនិយាយ៖
«ពៅបញ្ញា! រកនឹកឲ្យលឿនបន្តិចមក!!! ខ្ញុំចង់ដឹងអ្វីៗទាំងអស់ឲ្យតែជាតួលេខដែលទាក់ទងនឹងនាយរិទ្ធិ! គឺ.....របៀបជា...ថ្ងៃខែណាមួយដែលពិសេសរបស់គេ! លេខទូរសព្ទគេ! ថ្ងៃកំណើតគេ ម៉ាក់គេ ក៏បាន! អ្នកណាម្នាក់! ឯងមានចាំលេខ អីហៅមកឲ្យខ្ញុំទាំងអស់មក!»
«ឯងឡប់ហើយ! មកសួរច្រើនយ៉ាងនេះ? ហើយខ្ញុំទៅរកពីណាមកឲ្យឯង? ហើយឯងយកធ្វើអីសក្ខណា?»

«ខ្ញុំត្រូវការ Log in ចូល Computerគេ! ឥឡូវនេះ គេមិននៅផ្ទះទេ តែខ្ញុំកំពុងនៅផ្ទះគេ! ខ្ញុំត្រូវការមើល Project ដែលគេនឹងយកទៅឆ្លងភាគហ៊ុនព្រឹកស្អែក! ខ្ញុំនឹងcopyវាឲ្យបងប្រុសគេ ខ្ញុំត្រូវការឲ្យគេចាញ់! ខ្ញុំមិនចង់ឲ្យគេចាញ់បោកលេខាប៉េងនោះទេ!»
ពៅបញ្ញា តបមកវិញដោយតក់ស្លុត៖
«ឯងឆ្កួតមែនហើយ! ឯងនៅឯណាឥឡូវនេះ? ផ្ទះគេមួយណា? ចុះបើគេមកទាន់អ្ហា?! ស្តាប់!! ឯងឈប់ភ្លាម!!!! ហើយចេញមកវិញមក!»
«ទេ ខ្ញុំជ្រុលជាមកដល់ហើយខ្ញុំត្រូវធ្វើអ្វីម្យ៉ាង ហើយបើអត់ទេ ខ្ញុំនឹងធ្វើឲ្យគេទៅប្រជុំអត់បានស្អែកនេះ!»

ពៅបញ្ញាសែនហួសចិត្តនាងដឹងថាសក្ខណាគឺឆោតហើយត្រង់ពេកហើយ បានជាគិតឃើញវិធីគ្មានបានការនេះ។ នាងនិយាយឃាត់បន្ថែមជាបន្ទាន់៖
«សក្ខណា! ខ្ញុំត្រូវការឲ្យឯងចេញមកវិញ ឮអត់? បងរិទ្ធិមិនមែនជាមនុស្សដូចយើងគិតទេ យើងមិនស្គាល់គេទេ ឯងកុំប្រថុយរបៀបនេះប្រយ័ត្ន.....»
ហ្វារថយន្តចាំងឆ្វាចមកពីខាងក្រៅបង្អួចធ្វើឲ្យស្រីតូចសក្ខណា ស្រវាទាញបិទចន្លោះវាំងននដែលហើបនោះវិញស្ទើរមិនចង់ទាន់....សន្ទឹករថយន្តនៅខាងក្រៅសឹងថា លាន់រំពងឆ្លងដល់ពៅបញ្ញាដែលនៅពីចម្ងាយ....សក្ខណារអ៊ូតិចៗទាំង បេះដូងសឹងឈប់គាំង៖
«ហួសពេលហើយ! ....»
«នែ៎! ឯងនិយាយស្អី? ចេញមកវិញមក....ឮអត់? ប្រយ័ត្នគេទាន់សក្ខណា!»
«....គេមកវិញហើយ!....បានហើយ! ខ្ញុំរកកន្លែងពួនសិន!»
នាងបិទទូរសព្ទ ស្របពេលរថយន្តគេពន្លត់ ហើយស្នូរជើងរបស់គេលាន់មកកាន់តែកៀក។ នាងកម្រើកខ្លួនស្ទើរមិនកើត ព្រោះតែភ័យពេក។ កុំព្យូទ័រគេត្រូវតែបិទទៅវិញឲ្យបានមុនពេលបុរសម្នាក់នេះចូល មកឃើញ ដូច្នេះនាងស្ទុះទៅក្បែរតុហើយចុចវាបិទវិញយ៉ាងបន្ទាន់។ មុនពេលនាងរំលៀកខ្លួនចេញពីទីនោះ ស្នូរទ្វារខាងក្រៅត្រូវបានបើកស្រេចទៅហើយ។
....ស្រមោលពន្លឺអគ្គិសនីគ្របដណ្តប់ឆ្វាចពេញបន្ទប់ខាងក្រៅ....ហើយ តាមរយៈប្រលោះទ្វារដែលស្ទើរបើកស្ទើរបិទ នារីមើលឃើញស្នា គេក្នុងពេលនាយកំពុងអង្គុយដោះស្បែកជើង។

នាងវេភ្នែកចុះឡើងក៏ប្រទះឃើញ កូនសោដែលគេឲ្យនាង ត្រូវបាននាងទុកចោល នៅលើកូនតុនៃសាឡុងដែលគេកំពុងអង្គុយ។ សក្ខណាទទួលអារម្មណ៍ដូចត្រូវគេចាប់បោះទៅក្នុងស

មុទ្រនាងលើកដៃមក ផ្ទប់ទ្រូង ទប់ការលោតញាប់នៃខ្យល់ដង្ហើម ហើយរិះរកវិធី.....។
....គេក្រោកដើរមកហើយ....គឺមិនខុសទេ គេដើរសំដៅមកបន្ទប់នេះ....ជាបន្ទប់ធ្វើការរបស់គេដែលមានក្លិន មនុស្សស្រីគួរឲ្យត្រជាក់ចិត្ត....
តូចតន់ឈរវត្ថុប ព្រោះមិនដឹងធ្វើយ៉ាងណា ពួនក៏មិនពួន ទៅណាក៏មិនទៅព្រោះគេពិតជាបានឃើញសោនោះហើយដឹងថានាងនៅក្នុង នេះ។
ហើយពន្លឺភ្លើងពណ៌ពងមាន់ត្រូវបានបើកមកបំភ្លឺ...
....នាងសម្លឹងកម្រាលឥដ្ឋ មិនចង់រវល់នឹងការឈានចូលមកដល់របស់បុរសនេះ តែនាងនៅតែមើលឃើញជើងទាំងគូរបស់គេ..រហូតដល់គេមកឈប់នៅពីមុខ នាង....
«Romanticម៉េះ? ម៉េចមិនបើកភ្លើង?»
គេនិយាយធ្វើហីហើយសន្សឹមៗនារីងើបមុខសម្លឹងឃើញស្នាមញញឹមលើ បបូរមាត់គេ។ ទោះអញ្ចឹងមែន គេក៏មិនមែនរីករាយប៉ុន្មានទេ ព្រោះនាងឃើញគេរវៃភ្នែកទៅរកកុំព្យូទ័រ។ បុរសនេះមិនមែនងាយទប់ទល់ឡើយ ហើយភ្លាមៗនាងក៏គ្មានរកឃើញអ្វីសម្រាប់ដោះស្រាយជាមួយគេទាំងអស់ ។
ពេលគេងាកមកវិញនាងភ័យពេកក៏ធ្វើជានិយាយ៖
«មិនចង់ឲ្យមកក៏បាន!»
ថាហើយនាងប្រឹងជម្នះចិត្តដែលក្តុកក្តាក់ដើរត្រលប់ចេញក្រៅវិញ ហើយរឹតតែដើរញាប់ជាងមុននៅពេលដឹងថាគេមិនបានតាមមកទេ។
មកដល់បន្ទប់សាឡុង នាងបន់ឲ្យតែបានចេញដល់ឡាននិងអាលដាក់មេផាយ ប៉ុន្តែនាងទើបតែដឹងថាខ្លួនឯងយល់ខុសនៅពេលដែលលូកដៃដល់ទ្វារ ហើយទាញយ៉ាងណាក៏មិនរបើក។ នាងអង្រួនទ្វារ អស់ចិត្តហើយបែរក្រោយសម្លឹងទៅគេដែលនៅបន្ទប់នោះនៅឡើយ។ គេកំពុងឱនសម្លឹងអេក្រង់កុំព្យូទ័រដោយទឹកមុខស្មើហើយនាងដឹងថាលេខ សម្ងាត់ដែលនាងវាយស្មានៗទាំងអស់កំពុងត្រូវគេមើលឃើញស្លាកស្នាម ។
សក្ខណាដកដង្ហើមយូរខឹងខ្លួនឯង។
.....នាងតាមសម្លឹងប្រតិកម្មបុរសនោះ និងមុខស្មើធេងរបស់គេដែលងើបចេញពីកុំព្យូទ័រ គេមិនមើលនាងទេ តែដើរហួសទៅរកទូទឹកកកហើយបើករកភេសជ្ជៈ។ នាងឆ្លៀតពេលនេះងាកមកបើកទ្វារសាជាថ្មីក៏នៅតែបើកមិនចេញ រហូតដល់ថ្នាក់ស្នូរជើងគេដើរមកក្បែរនាងជាមួយស្នូរដង្ហើមដែលនាង ចំណាំបាន។

នាងដឹងថាគេមកដល់ពីក្រោយខ្នងនាងហើយគ្រាន់តែគេមិននិយាយអ្វី ដូច្នេះនារីកាត់ភាពសៅហ្មងបែរមកវិញសន្សឹមៗ។
....បុរសនេះធ្វើមុខស្មើគួរឲ្យពិបាកចិត្ត....ភ្នែកគេសម្លឹងនាងជា សញ្ញាថាគេរង់ចាំឲ្យនាងនិយាយដោះសាតែនាងមិនដឹងថាត្រូវនិយាយ យ៉ាងណាមានតែធ្វើមុខក្រញូវខឹងតបវិញ....ស្រាប់តែគេហុចទឹកមួយកែវមក....
នាងធុញណាស់មិនចង់រវល់នឹងគេទេ តែមិនទទួលក៏មិនបាន ច្នេះមានតែលូកដៃញ័រៗទៅទទួលមកកាន់ហើយក្រេបបន្តិចឲ្យរួច កិច្ច....
គេនៅតែសម្លឹងនាងដូចសម្លឹងអ្នកទោសម្នាក់ ធ្វើឲ្យនាងកាន់តែមានអារម្មណ៍ថាទើសទាល់...មិនដឹងត្រូវធ្វើម៉េច ឥឡូវនាងក៏ដាក់កែវទឹកទៅលើដៃនាយវិញ ទាំងនិយាយទន្ទឹងទិសៈ
«ខ្ញុំទៅវិញបានហើយនៅ!?»
«ប្រញាប់ម៉េះ? ក្រែងចង់រកPasswordsអ្ហេស៎?»
គេញញឹមស្ងួរឌី ឯនាងក្របួចមាត់ខឹង.....
«លែងចង់បានហើយ!»
«អញ្ចឹង??? ចិត្តសាវាដល់ហើយហ្ន៎!?»
ស្រីតូចសក្ខណាឃើញបុរសម្ចាស់ផ្ទះនិយាយហើយរវេភ្នែកសម្លឹងនាងពីលើ ចុះក្រោម។ នាងដឹងថាគេនេះប្រុងធ្វើអ្វី ហើយនាងក៏កំពុងភ័យ ដូច្នេះនាងនិយាយឡើងភ្លាមៈ
«លោកក៏ធ្លាប់លួចចូលបន្ទប់ខ្ញុំគ្មានការអនុញ្ញាតដូចតែគ្នា!»
«ខុសគ្នា!»
«ខុសស្អីទៅ? លួចគឺលួចហើយ! ឥឡូវនេះទុកថារួចគ្នា! បានអត់?»
គេសើចសម្លឹងនាងដែលនៅកៀកបង្កើយ ហើយឈោងទុកកែវទឹកទៅលើទូស្បែកជើងដោយមាត់និយាយមួយៗៈ
«ខ្ញុំចូលបន្ទប់កូនស្រីគេ ខ្ញុំថើបគេ ឱបគេពេញដៃ ពេលគេលួចចូលមកផ្ទះខ្ញុំវិញ គឺមកឆែកកុំព្យូទ័រខ្ញុំ»
ស្រីតូចច្រានទ្រូងគេចេញ នៅពេលដែលគេកាន់តែលោចូលមកជិតនាង។
តែរាល់ពេលដែលនាងច្រានគេគឺដូចដុតចិត្តគេ ឲ្យគេលូកដៃមកស្រោក់នាងជាប់។ នាងនិយាយទាំងសៅហ្មងនឹងភាពងងើលរបស់គេៈ
«លោកក៏អត់ស្មោះត្រង់ដែរ! លោកលេងល្បិចរួមដៃជាមួយសន្តិសុខបោកប្រាស់ខ្ញុំឲ្យចូល

មក!»
គេមិននិយាយហើយឱនមកបីត្រកងនាងឡើងផុតជើងពីកម្រាលឥដ្ឋ។ ស្រីតូចភ័យតក្កមា ប្រញាប់វាចាបន្ថែមភ្លាម៖
«ដាក់ខ្ញុំចុះនាយរិទ្ធិ! លោកមានសិទ្ធិអីមកធ្វើអញ្ចឹង?»
បុរសមិនរវល់តមាត់ គិតតែពីបីនាងដើរត្រលប់ចូលទៅផ្ទះវិញ។ នាងរើយ៉ាងណាក៏មិនរបូតពីដៃនាយរហូតដល់រាងកាយត្រូវផ្តេកមកលើ កម្រាលពូក។ នាងស្ទុះក្រោករឹងតែត្រូវគេច្រានផ្តួលដូចដើមដោយប្រើតែបាតដៃ មួយ។ នាងស្អប់ភាពមិនមាត់មិនកតែមិនគោរពមនុស្សស្រីរបៀបនេះណាស់បាន ជាស្រែកបន្តដោយមុខក្រហម៖
«ហួត ខេមរិទ្ធិ! លោកកុំចចេសធ្វើឲ្យខ្ញុំស្អប់លោកជាងនេះណ៎ា!»

គេនៅតែមិនមាត់ហើយញញឹមច្រត់ដៃទ្រោបមកសម្លឹងនាង។ ធីតាប្រឹងក្រោកទៀត តែគេក៏ប្រើតែដៃមួយរុញទៅវិញដូចដើម។ គេកាន់តែធ្វើអញ្ចឹង ចិត្តនាងកាន់តែតូចចិត្តផង ខឹងផង នាងនិយាយញាប់ស្មេរ៖
«លោកកុំចង់ក្លាយជាមនុស្សកំសាក មនុស្សអាងកម្លាំង មនុស្សសម្លុតស្រី......»
«មនុស្សស្អីក៏ដោយ....!!! អ្នកនាងធំគេចពីមនុស្សនេះអត់រួចដដែលហ្នឹង!»គេនិយាយកាត់ដោយ សូរសម្លេងមួយៗហើយផ្តោតភ្នែកសម្លឹងនាង។ នាងមិនដឹងទេថាខ្លួនឯងកំពុងស្ថិតនៅក្នុងស្ថានភាពបែបណា ដែលដេកដួលនៅក្រោមទ្រូងនាយជិតគ្នាថ្នាក់នេះ តែពន្លឺភ្នែកនាយដែលមើលមក គឺប្រៀបដូចគេកំពុងជក់ចិត្តនឹងអ្វីម្យ៉ាងដែលគាប់ចិត្តគេជា ខ្លាំង។ គឺអាវបើកករបស់នាងរំលេចសាច់សផូរផង់រលោងទន់ដូចត្របកឈូក កំពុងធ្វើឲ្យនាយឆ្កួតចិត្តហើយម្រាមដៃនាយចាប់រេទៅរកទីនោះ ទាំងមិនដឹងខ្លួន។
ស្រីស្អាតរេខ្លួនគេច មាត់និយាយពញ្ញាក់អារម្មណ៍អ្នកប្រុសមកវិញ៖
«អត់ទេណ៎ា! ខ្ញុំថាអត់ទេ លោកឮអត់?!!»
ដៃគេនៅតែងងើលទៅប៉ះស្បែកស្រីស្អាតដែលត្រូវដៃបុរសកាលណាប្រែ ពណ៌ទៅជាក្រហមសព្វទីកន្លែង មាត់នាយនិយាយតបក្នុងពេលអំណាចស្នេហ៍កំពុងគ្របសង្កត់៖
«ចង់បានPasswordម៉េចមិនប្រាប់? គេបំពេញកាតព្វកិច្ចជាប្តីឲ្យប្រពន្ធបានតើ! តែយើងត្រូវធ្វើជាប្រពន្ធល្អមុនសិន!»
«ខ្ញុំមិនមែនជាប្រពន្ធលោកទេ!» នាងនិយាយស្រួយស្រែសហើយរុញទ្រូងនាយចេញអស់មួយ

ទំហឹង។ ទោះកម្លាំងនាងមិនអាចឲ្យរបូតពីដៃនាយ ក៏ល្មមអាចឲ្យនាយពិបាកឱនមក គ្រប់គ្រងនាងដែរ។

បុរសញញឹមតែមិនព្រមចាញ់ គេស្រាក់ម្រាមដៃនាងទាំងពីរហើយសង្កត់ផុតទៅលើធ្វើឲ្យនាង ក្លាយ ជាចំណាប់ខ្មាំងអស់អ្វីតតាំងបាន។ ឯមាត់អ្នកក៏និយាយបញ្ឈឺចិត្ត៖

«ក្រែងមានសង្សារច្រើនណាស់អ្វីកាលនៅអាមេរិក! ភ័យធ្វើអីអញ្ចឹង?»

ទ្រូងនាងដង្ហក់ព្រោះឃើញនាយឱនមកថើបថ្ពាក់ថ្មម។ នាងគ្មានផ្លូវគេចខាងរាងកាយ មានតែ បិទភ្នែកគេចពីសម្ពាធផ្លូវចិត្ត។ តែមាត់នៅតែចប្រែច៖

«ហើយខ្ញុំនឹងសម្លាប់ខ្លួន!....ហើយលោកនឹងស្តាយក្រោយ!!! មនុស្សអាក្រក់!!!»

បុរសចង់បន្តបង្ហាញតម្រេករបស់ខ្លួនទៅនឹងស្រីតូចចំពោះមុខ តែសម្តីនាងធ្វើឲ្យគេទៅជាអស់ សំណើចហើយងើបមុខមកវិញ៖

«ស្អីគេអ្ហះ? គ្រាន់តែអញ្ចឹងទៅសម្លាប់ខ្លួនអញ្ចឹងម៉្ងៃៗស្រីៗស្លាប់អស់ប៉ុន្មាននាក់ទៅ?»

គេសើចសម្លឹងនាង ហើយរេភ្នែកមករកដើមទ្រូងរបស់នាង ធ្វើឲ្យនាងកាន់តែចងចិញ្ចើម ស្រែកបន្តដាក់ត្រចៀកនាយ៖

« ខ្ញុំស្បថ ខ្ញុំនឹងឈប់ស្រលាញ់លោក ខ្ញុំនឹងស្អប់លោក ហួត ខេមរិទ្ធិ!»

សម្តីនាងគឺមានន័យថានាងកំពុងស្រលាញ់គេ តែនាងល្ងង់ផងឆោតផងបានជានិយាយវា ចេញមក។នាយដឹងថានាងឆោតដល់ ថ្នាក់មិនដឹងថាអ្វីៗទាំងនេះ គឺគេធ្វើព្រោះភ្ញាញ់នាង តែ មិនមែនជាការចាប់បង្ខំនាងដើម្បីកាមតណ្ហាឡើយ។ ចរិតនាងគឺឆាប់ភ័យតែក៏ស្លុយ។ ដូច កាលនៅព្រៃអ្វីបន្តិចក៏ខ្លាច តែឲ្យតែខឹង ខ្លាចយ៉ាងណាក៏ទៅ។

គេផ្ងារខ្លួនច្រងាងដេកក្បែរនាងធ្វើឲ្យនាងបានឱកាសប្រមៀលខ្លួន រកក្រោក ប៉ុន្តែគេឱបចង្កេះ នាងទាញមកវិញដដែលជាដដែល។

នាងបែរខ្នងគេចមុខ តែអ្នកប្រុសទីពីរនៅតែមានរាងកាយនាងពេញក្នុងរង្វង់ដៃ។ គេផ្ទឹបបបូរ មាត់មករកគល់កស្រីតូចធ្វើឲ្យនាងព្រឺសម្បុរហើយរេ គេចចេញរហូតដល់បបូរមាត់នាយដាក់ មកក្បែរត្រចៀកនាងជាមួយប្រយោគ ស្រាលៗ៖

« ស្រលាញ់គ្នាម្ល៉ឹងៗ អូនដាច់ចិត្តក្បត់ប្តីខ្លួនឯងយកឯកសារទៅឲ្យអ្នកដទៃអ្ហះ?»

នារីរេភ្នែកគិត ម៉េចក៏សម្តីគេគួរអាណិតយ៉ាងនេះ? តែនាងនៅតែច្បាស់លាស់ចំពោះអ្វីដែល នាងកំពុងធ្វើ។ ម្រាមដៃនាងទាញដៃគេចេញពីចង្កេះ ព្រោះថារាងកាយអ្នកទាំងពីរគឺស្អិទ្ធគ្នា ពេញមួយទំហឹងពេក។

....នាងកាន់តែទាញគេកាន់តែរឹត។ នាងនិយាយទាំងបែរខ្នង៖
«មិនមែនធ្វើបាបលោកទេ! តែមិនចង់ឲ្យលោកចាញ់បោកគេ!»
«ហើយយើងហ្នឹងឆ្លាតប៉ុណ្ណាទៅបានដឹងអ្នកណាចាញ់បោកអ្នកណា?»
«ទោះយ៉ាងណាក៏មិនងាកមកឈ្លោះបងប្អូនឯងដូចអ្នកខ្លះដែរ!»

គេនៅសំងំស្ងៀម នាងនិយាយបន្តភ្លាម៖
«លោកច្បាស់ជាមានបញ្ហា លោកប្រហែលត្រូវពួកនោះវាយខ្លាំងពេក មានបញ្ហាក្បាលក៏មិនដឹង លោកត្រូវទៅពិនិត្យរកគេព្យាបាលត្រឹមត្រូវទៅ!»
អ្នកប្រុសទីពីរសើចយ៉ាងវែងក្បែរត្រចៀកនាង នាងទទួលអារម្មណ៍ថារង្វង់ដៃគេដែលក្រសោបនាងគឺពោរពេញទៅដោយក្តី ស្រលាញ់ហើយខ្លាចនាងចាកចេញ។
«បើបងឆ្កួតមែន! មានគេយកបងធ្វើប្តីទៀតអត់? ព្រមទៅភូមិនោះលេបស្រាជាមួយគ្នាទៀតដែរ?»
នាងនៅសំងំស្ងៀម ប៉ុន្តែគឺកំពុងស្លុងចិត្តនឹងរឿងរ៉ាវអស់នោះ។ នាងនឹកដល់រឿងជាច្រើនហើយចុងក្រោយគឺគ្រាដ៏កម្សត់មុនពេលនាងចាកចោលគេ គឺកគេដែលត្រូវជាន់ផ្ទប់ដី។
មិនដឹងយ៉ាងម៉េចទេ នាងដាក់ម្រាមដៃទៅលើបាតដៃនាយ ហើយចាប់ដៃគេចេញពីចង្កេះថ្មមៗដោយបែរកាយមកសម្លឹងនរៈយើង។
គេប្រហែលមានញាណពិសេសដឹងពីអារម្មណ៍ នាងដឹងថានាងមិនរត់គេចទៀត ដឹងថានាងកំពុងគិតពីអ្វី បានជាគេព្រមលែងដៃនោះចេញសន្សឹមៗឲ្យនាងមានសេរីភាពក្នុងការបែរ មកបាន។
ជាមួយខ្សែភ្នែកអាណោចអាធ័ម នាងរេសម្លឹងកគេ បន្ទាប់មកគឺទ្រូងគេដែលលាក់ក្នុងអាវយឺតស ហើយនាងក៏នឹកឃើញដល់កម្លាំងជើងពួកជនពាលដែលរុករានទន្រ្ទានរាងកាយ គេបន្ទាប់មក គឺលោហិតនាយដែលហូរស្រក់ទៅលើដី។
សក្ខណារលីងរលោងហើយចាប់ស្រក់ទឹកភ្នែកយកតែម្តង...អ្វីៗវិលមកវិញ ច្បាស់ដូចថ្ងៃ ទាំងចិត្តអាណិត ទាំងការស្រលាញ់ ដែលក្លាយជាការរំជួលចិត្ត ....
«ថ្ងៃនោះ ថៅហ្វាយខេត្តជាមិត្តភ័ក្តិរបស់ជំទាវម៉ាក់បាននាំគ្នាព័ទ្ធចាប់ ពួកអស់នោះហើយបងខ្ញុំនាំខ្ញុំមកពេទ្យ! ខ្ញុំចង់ត្រលប់ទៅរកលោកខ្លាំងណាស់តែពៅបញ្ញាសន្យាថា យុត្តនានឹងនាំលោកមកវិញ គឺគេសន្យាជាមួយខ្ញុំច្បាស់ៗ តែទីបំផុតគេធ្វើអត់បានទេ! លោកត្រូវពួកមនុស្ស

ពាលអស់ហ្នឹងធ្វើបាបណាស់មែនទេ? និយាយមក! គេវាយលោករហូតដល់លោកក្លាយជាយ៉ាងនេះមែនអត់?»
អ្នកប្រុសញញឹមនៅពីមុខទឹកភ្នែកស្រីតូច តែចិត្តអ្នកកំពុងត្រូវនាងទាក់យកព្រោះតំណក់ទឹកភ្នែកនិងភាព បរិសុទ្ធចិត្តកាយរបស់នាង។ ដៃនាយដាក់លើចង្កេះនាងជាមួយវាចាតបៈ
«ក្លាយជាយ៉ាងម៉េច?»
«គឺលោកក្លាយជាមនុស្សកាច! លោកដូរចរិត! ហើយលោក...និយាយរួមគឺច្រើនរឿងណាស់! លោកមិនដូចមុនទេ! ខ្ញុំសួរពេទ្យរួចហើយ គេថាមនុស្សដែលឆ្លងកាត់ទារុណកម្មហួសហេតុគឺអញ្ចឹងហើយ លោកត្រូវតែព្យាបាល!»

គេរំភ្នែកសម្លឹងទុក្ខសោករបស់នាង ហើយដាក់បបូរមាត់ទៅលើថ្ងាសនាង ពេលនាងយំគគ្រូក។ គេនិយាយតិចៗ៖
«ស្រីល្ងង់! ដូរចរិតអីទៅ? ដូរកន្លែងណាខ្លះអូនៈ? យំធ្វើអី?»
នាងលែងឆ្លើយព្រោះរវល់យំអណ្ដឺតអណ្ដក តែនាងប្រហែលជាមិនដឹងទេថាកាយវិការនាងបានធ្វើឲ្យនាយឆ្កួត វង្វេង។ អ្នកប្រុសទីពីរ ឱបនាងពេញរង្វង់ដៃហើយខ្សឹបខ្សៀវពន្យល់៖
«គេក្នាញ់យើងពេកបានជារៀនឌឺលេងទៅ! មកពីយើង បានជាគេដូរចរិតគ្មានមកពីអ្នកណាទេ!!! ឮហើយនៅ! មនុស្សប្រុសម្នាក់គេអាចបញ្ចេញធាតុពិតតែជាមួយមនុស្សស្រីដែលគេស្រលាញ់ម្នាក់ទេ គឺធាតុពិត ដែលគ្មានប្រុសណាម្នាក់សុភាពរម្យទម ជាមួយស្រីដែលគេស្រលាញ់ទេដឹងអត់? ពិសេសពេលនៅតែពីរនាក់អញ្ចឹងៗ ឲ្យសុភាពកើតដែរ? គ្រាន់តែអញ្ចឹងគិតថាគេសរសៃប្រសាទទៅហើយ? ចុះបើយើងញ៉ិកញ៉ក់ម្ដុំងៗឲ្យគេទ្រាំមិនលេងយើងវិញខ្លះទេ?»
«ចុះលោកជឿលេខាប៉េងនោះធ្វើអី អូនៈ? ទោះគាត់នោះជាអ្នកចូលព្រៃទៅជួយលោកក៏ដោយក៏...»
«វាមិនបានទៅជួយបងទេ!»គេនិយាយកាត់ធ្វើឲ្យនាងទៅជាបើកភ្នែក មូលក្លុំ។ បបូរមាត់គេដែលនៅកៀកនឹងបបូរមាត់នាង ចាប់កម្រើកភាសាខ្សឹបខ្សៀវបន្ត៖
«វាមិនបានជួយបងទេ! គឺបងទៅរកវា! ហើយស្ម័គ្រចិត្តឲ្យវាយកបងទៅប្រើ!»
នាងកាន់តែបើកភ្នែកធំៗ។
«ចុះម៉េចលោកចេញពីព្រៃនោះមកបាន?»

«បងប្រុសបង! ហួត យុត្តនា! គឺគេទៅជួយបងចេញមក! តាំងពីយប់នោះមក គឺយប់ដែលអូនឯងចេញមកភ្នំពេញមុន!»
នារីបើកភ្នែកមូលក្លំរឹតតែបង្ហាញក្តីទៀងត្រង់និងឆោតល្ងង់របស់នាង។ គេនិយាយបន្ត៖
«តាំងពីពេលនោះ! នៅចេតិយនោះ បងនិងបងប្រុសបងបានរកវិធីនេះដើម្បីបញ្ចប់ផ្លូវលេខាប៉េង!»
នាងទើបតែយល់តែមិនទាំងស្រុងទេ គឺខ្លះៗប៉ុណ្ណោះ។
ទោះយ៉ាងណាក្តី កែវភ្នែកគេនិងក្តីស្រលាញ់ដែលបញ្ជូនមកតាមរង្វង់ដៃគេ ធ្វើឲ្យនាងជឿជាក់។
«ចុះស្នែកនេះ....» នាងសួរតិចៗ ។
គេមិនទាន់បានឆ្លើយព្រោះទូរសព្ទគេរោទ៍។ អ្នកប្រុសទីពីរលូកពីហោប៉ៅលើកមកចុច....
សំឡេងស្រីម្នាក់ដែលសក្ខណា ស្គាល់ច្បាស់ លាន់មកប្រែតកណ្តាលភាពស្ងប់ស្ងាត់នៃរាត្រីកាល៖
«ហួត ខេមរិទ្ធិ! បើកទ្វារ! ហើយឲ្យសក្ខណាចេញមកវិញភ្លាម! មិនអញ្ចឹង កុំថាខ្ញុំមិនបានប្រាប់!»
សក្ខណាដកដង្ហើមយូរ....នាងដឹងថាពៅបញ្ញាប្អូននាងមកដល់ខាងក្រៅហើយ... គឺដោយសារតែការបារម្ភ...
នាងតូចងាកមករៀបរយសំលៀកបំពាក់ ហើយក៏ច្រត់ដៃក្រោក។ រិទ្ធិមិនខ្វីឆ្លើយតបនិងពៅបញ្ញាតែគេឱនមកឱបសក្ខណាពីក្រោយខ្នង ដោយខឹដងបន្ត៖
«ហើយបងប្អូនគេកើតមកកាចៗម៉េះហ្ន៎!»
សក្ខណា ក្តាប់មាត់ងរង៉ក់នាងមិនងាកមុខតែមាត់តបវិញ៖
«អញ្ចឹងហើយ! ព្រោះពីរនាក់បងប្អូនមកពីផ្ទះអគ្គទេសាភិបាលនោះ សុទ្ធតែចរិតយ៉ាប់ៗ»
នាងប្រុងក្រោកទៅតាមឃ្លាបញ្ចប់នេះ ប៉ុន្តែគេនៅតែមិនដាច់ចិត្តត្រដរទាញនាងមកវិញឲ្យដួលទៅលើគ្រែ ទន់ល្មើយសាជាថ្មី បុរសទ្រោបទៅលើនាងទោះបីមិនទាំងស្រុងតែអាចឲ្យនាងក្រោកឡើងមិន បាន។ គេខ្សឹបតិចដាក់កែវភ្នែកថ្លាឆ្វង់របស់នាង៖
«ប្រាប់មេធាវីនោះទៅកុំឲ្យមកសម្លុតខ្ញុំទៀត ខ្ញុំក៏មានបងដែរ! ប្រយ័ត្នតែប្រាប់បងខ្ញុំឲ្យសងសឹក!»
ស្រីតូចក្តាប់មាត់សម្លក់នាយ។ នាងមិននិយាយ ស្របពេលសន្ទឹកគោះទ្វារលាន់មក ទើបនាង

វាចាប្រាប់គេ៖
«ឈប់លេងទៅ! ប្រយ័ត្នមេឃរលំមកមែនណ៎ា!!»

ជំពូក២០

ក្រឡាអុកចុងក្រោយ សម្រាប់លេខាប៉េង

…ការជួបជុំបង្ហាញគម្រោងយុទ្ធសាស្ត្រថ្មីគឺជាព្រឹត្តិការណ៍ ប្រវត្តិសាស្ត្រមិនធ្លាប់មានសម្រាប់ការជ្រើសរើសអគ្គនាយកធនាគារ។
វាក៏ជាវិធីដ៏ប្លែកតែអាចជាឱកាសមាសដែលភាគហ៊ុនទាំងឡាយដឹងថា ហួត ស៊ីវ ចិញ្ចឹមកូនមកដោយរបៀបណាហើយហេតុអ្វីគាត់មានមោទនភាពចំពោះពួកគេ។
…..តាមឋានានុក្រម លេខាប៉េងមិនត្រូវបានអនុញ្ញាតឲ្យចូលទេ ដូច្នេះគេត្រូវនៅរង់ចាំអន្ទះសាខាងក្រៅ។
…..ពេលវេលារំលងទៅយូរណាស់ សម្រាប់តាចាស់មានល្បិចនេះ ទោះបីគាត់មានជំនឿចិត្តលើអ្នកប្រុសទីពីរ ប៉ុន្តែភាពស្ងិតស្ងាញនិងថេរវេលាដែលចេះតែអូសបន្លាយធ្វើឲ្យគាត់ កាន់តែសង្ស័យថាតើ យុត្តនាពិតជាមិនងាយចុះចាញ់មែនឬអ្វី?
….ស្នូរជើងធ្ងន់ៗចេញមកពីបន្ទប់ប្រជុំ…លេខាប៉េងភ្ញាក់ផ្អើលហើយ រំលៀកខ្លួនគេចទៅម្ខាងប្រើវាំងននធំក្រាស់អូសហៀរដល់ដីនៅឯបង្អួចអមបណ្តោយអគារដើម្បី បិទបាំងវត្តមានគាត់។ យ៉ាងណាមិញ គាត់អាចមើលឃើញអ្វីៗបានដោយស្រួល ព្រោះបានត្រៀមរួចហើយ….ម្ចាស់ស្នូរជើងគឺអ្នកប្រុសទីពីរដែលចេញ មកទាំងមុខក្រញូវ។
ហើយនៅពីក្រោយគេប៉ុន្មានជំហាន គឺយុត្តនាដែលប្រកបដោយភាពរីករាយលើផ្ទៃមុខ។
ស្ថានភាពនេះបានធ្វើឲ្យប៉េងច្របូកច្របល់ចិត្ត ។
«ឯងគ្រាន់បើ!»សំឡេងអ្នកប្រុសទីពីរឌឺដង នៅពេលបងប្រុសដើរមកតាមពីក្រោយ។
សម្តីនេះអាចជួយឲ្យប៉េងស្មានដឹងបានខ្លះៗទៅហើយថាអ្វីខ្លះបាន កើតឡើងនៅខាងក្នុងចំណែកស្ថានភាពពិតគឺគ្រាប់អុកគាត់ទំនងជាបុកមិនឈ្នះ គ្រាប់អុករបស់ ហួត ស៊ីវ ទៅហើយ។ តែគាត់នៅប្រឹងធ្វើក្រឡឹតក្រឡាប់ផ្ទៀងត្រចៀកស្តាប់។
«តែខ្ញុំដឹងថាឯងគ្មានសមត្ថភាពធ្វើគម្រោងការល្អយ៉ាងនេះទេ យុត្តនា! ច្បាស់ជាមានអ្នកណាជួយឯងពីក្រោយជាសម្ងាត់!»
រិទ្ធិបន្ថែមវាចាដោយច្រត់ចង្កេះឈប់ដំណើរង៉ក់កណ្តាលអគារធ្វើឲ្យអ្នកប្រុសទីមួយបញ្ឈប់

ជើងក្បែរនោះដែរ។
យុត្តនានិយាយតបវិញយឺតៗក្រោមពន្លឺភ្នែកក្តៅគគុករបស់ប៉េង៖
«វាជាផ្នែកមួយនៃគម្រោងការរតនៈសោភ័ណ!»
រិទ្ធិបែរក្រោយវឹងតែអ្នកដែលញ័រដៃគឺប៉េងឯណោះ។
«ឯងប្រហែលមិនជឿ?»យុត្តនានិយាយទាំងញញឹមហើយគេពោលបន្តភ្លែត៖
«តែវាជាការពិតរិទ្ធិ! អញ្ចឹងហើយឯងក៏ឃើញស្រាប់ថា តើវាអស្ចារ្យកម្រិតណា!»
ប៉េងកាន់តែឆ្លេឆ្លា ហើយតណ្ហានៃការចង់បានរបស់គាត់ពេលនេះ បានធ្វើឲ្យគេកាន់តែដកដង្ហើមដង្ហក់ហើយអារម្មណ៍បែកខ្ញែករិលរល់។ ត្រចៀកឮសូរអ្នកប្រុសទីពីរសួរមកបន្ថែម៖
«ពៅបញ្ញាប្រគល់វាមកឯង?»
យុត្តនាមិនមាត់គេដើរហួសទៅបាត់បន្សល់នូវអ្នកប្រុសដែលនៅឈររេរាមួយសន្ទុះក៏ចេញទៅតាមផ្លូវផ្សេង។
ប៉េងដកដង្ហើមយូរសម្រួលរាងកាយដែលខំទប់ការញាប់ញ័រកាលពីមុននេះ។ គេរវេភ្នែកទៅរកទ្វារបន្ទប់ប្រជុំដែលមិនទាន់ឃើញភាគហ៊ុនណាម្នាក់ ចេញមកវិញនៅឡើយ សំណួរជាច្រើនត្រូវបានគេបង្កើតឡើងមកភ្ញោចអារម្មណ៍ខ្លួនឯង....
«គម្រោងការនោះ ល្អដល់ថ្នាក់គ្មានអ្នកណាម្នាក់ព្រមងើបចេញមកវិញ?»
«តាមពិតរបស់នោះពិតជានៅនឹងដៃអាកញ្ចាស់ ប៉ែន ពេជ្រ និងកូនពៅវាមែន?»
«អត់ទេ! បើទោះជាស្លាប់ក៏យើងត្រូវតែបានរបស់នោះយកទៅឋាននរកឲ្យអាហ៊ាយើងដែរ!»
គេគិតចប់ចាកចោលទីពួនបំបាំងកាយនោះហើយដើរឆ្ពោះទៅកាន់បន្ទប់ ភេសជ្ជៈ ដែលគេដឹងថាអ្នកប្រុសទីមួយបានដើរតម្រង់ទៅកាលពីមុននេះបន្តិច។
អ្នកប្រុសទីមួយក្នុងសំលៀកបំពាក់អាវធំដ៏ស្រស់សង្ហានិងមានអំណាច កំពុងឈរបែរខ្នងក្បែរម៉ាស៊ីនចុចទឹក។ ប៉េងដើរចូលមកដល់ហើយក៏អ្នកប្រុសនៅធ្វើមិនដឹង។
លេខាមានល្បិចនោះប្រញាប់ប្រញាល់ ក្រឡេកមើលជុំវិញ....
គ្មានអ្នកណានៅទីនេះទេ...វាគឺជាឱកាសសម្រាប់គាត់.....ដូច្នេះបុរស ចិនបានច្រានទ្វារបន្ទប់បិទដោយទាញព្យួរស្លាកមួយថា«សំអាត»ហើយ គាត់បែរមករកអ្នកប្រុសទីមួយដែលឈរសម្លឹងតបមកគាត់វិញយ៉ាងសង្ហា ....ទឹកមុខប្រកបដោយភាពជោគជ័យរបស់គេមិនបានធ្វើឲ្យលេខាប៉េង ឈឺចាប់ចំពោះបរាជ័យក្នុងការទម្លាក់គេចេញពីតំណែងកំពូលនៅទីនោះទេ ព្រោះបេះដូងគាត់បានផ្តោតទៅលើគម្រោងការអច្ឆរិយតែមួយមុខប៉ុណ្ណោះ។

«ឯងឲ្យគម្រោងការនោះមកខ្ញុំ! ខ្ញុំនឹងធាក់អ្នកប្រុសទីពីរចេញឲ្យផុតពីទីនេះ គឺដកបន្លាពីភ្នែកឯង!»
យុត្តនាមិនភ្ញាក់ផ្អើលអ្វីនឹងសំណើត្រង់ៗនេះទេ គេសើចចុងមាត់បង្អួតស្នាមខួចជ្រៅ៖
«លោករួសរាយណាស់លេខាប៉េង! ហាភ្លាមនិយាយតម្លៃច្បាស់ៗហ្មង! តែគម្រោងការធំយ៉ាងនេះ ឯងជួយខ្ញុំតិចតួចប៉ុណ្ណឹងម៉េចសមទៅ? មានអីថែមទៀតទេ?»
«ខ្ញុំបញ្ជូន ប៉ែន ពេជ្រប្រាថ្នា ឲ្យចេញមុខមកវិញ លាងទោសឲ្យឯងបានទេ? ក្រែងគេកំពុងយល់ថាឯងច្រានលោកអគ្គ តាមពិតគឺ ប៉ែន ពេជ្រប្រាថ្នា ដែលចូលមកពីក្រោយឯងទេ! រឿងនេះយើងដឹង!»
«ពូទៅរកគេពីណាមក បើគេមិនដឹងទៅដល់ទីណាហើយផងហ្នឹង?»
«គេស្រលាញ់បុស្បា! ក្មួយស្រីយើងពីតូចមក ឲ្យតែយើងថាឆ្វេងគឺឆ្វេង ឲ្យវាតាមរកអាប្រុសនោះមិនទៅណាឆ្ងាយទេ!»
«ពូ ពូកែមែន!»
«សម្រេចថាអញ្ចឹងទៅ! ឯណារបស់នោះ?»
«របស់អី?»
«Project របស់អារាជ!»
«ពូល្ងង់ម្ល៉ឹងៗចង់បានរតនៈសោភ័ណយកទៅធ្វើអី?»
«យើងយកវាទៅសែនអាហ៊ាយើង!»
«ទុកចិត្តពូឯងកើតដែរ បើបានរបស់ហើយពូនៅតែពង្វក់អ្នកប្រុសទីពីរមកខាំខ្ញុំទៀត គិតម៉េចទៅ?»
«ទេ យើងគ្រាន់តែចង់ឲ្យ ហួត ស៊ីវ វេទនា តែឯងនិងយើងគ្មានគំនុំទេ ឯងគ្រាន់តែជាកូនធម៌វាប៉ុណ្ណោះ!»
«តែពូបានយកឧកញ៉ា ប៉ែន ពេជ្រ និង ប៉ាខ្ញុំ ហួត ស៊ីវ ទៅសម្លាប់នោះនៅ Javaនោះ ឯងនៅមិនទាន់អស់ចិត្តទៀត?»
«ព្រោះវិញ្ញាណក្ខន្ធបងប្រុសយើងនៅមិនស្ងប់! គាត់មិនបានទៅចាប់ជាតិទេ! បានពេលនេះយើងអាចលែងរវល់ជាមួយអាកញ្ចាស់ពីរនាក់នោះ តែរតនៈសោភ័ណឯងត្រូវតែឲ្យមកយើង!»
យុត្តនាសើចគេលែងមាត់តែដៃគេចង្អុលទៅជញ្ជាំងពីមុខលេខាប៉េង ដែលក្រាលគ្របដោយ

វាំងននពណ៌មាសឆ្អិន។
«បាន! នៅនុះហើយ! ឯងចូលទៅយកទៅលេខាប៉េង!»
បុរសមានពុតក្រឡេកទៅរកវាំងននដែលរបើកទៅខាងសន្សឹមៗ។ វត្ថុអ្វីមួយចាំងភ្លឺបភ្លែត លោតឡើងចុះពីមុខគាត់ ហើយដែលត្រឹមពីរវិនាទីប៉ុណ្ណោះគាត់មើលស្គាល់ ថាវាអ្វីទៅហើយ....
.....នោះគឺកាណុងកាមេរ៉ាតូចមួយ...ដែលងាយស្រួលយល់បំផុតគឺថាការ សន្ទនាទាំងអស់អម្បាញ់មិញត្រូវបានភ្ជាប់ទៅឲ្យភាគហ៊ុនទាំងឡាយមើល ឃើញច្បាស់ដូចថ្ងៃតាមរយៈឧបករណ៍នេះ....
សម្តីយុត្តនាកាលពីប៉ុន្មានថ្ងៃមុនលាន់មកសាជាថ្មីក្នុងត្រចៀកគាត់ទាំងសងខាង...
«អាណិតលោកណាស់លេខាប៉េង!» »
ទម្រាំគាត់ដឹងខ្លួនមកវិញ អ្វីៗហួសអស់ទៅហើយ។
ដោយសារតែចិត្តរំភើបនឹងគម្រោងការនោះ បុរសចំណាស់បានបាត់បង់ស្មារតីភ្លៀវភ្លាហើយសារភាពដោយខ្លួនឯងនូវ ការពិតនៃឧក្រិដ្ឋកម្មទាំងឡាយ តើគាត់មានអ្វីសម្រាប់លោតទៀត។ គាត់ស្ទុះរឹងចេញពីទីនោះ ហើយក្រឡេកទៅកាន់បន្ទប់ប្រជុំដើម្បីឲ្យប្រាកដចិត្តថាអ្វីដែលទើប បាននិយាយអំបាញ់មិញបានបញ្ជូនដល់ទីនោះមែនឬយ៉ាងណា.....តែគាត់រឹតតែ លស់ព្រលឹងព្រោះ មនុស្សជាច្រើនបានបើកទ្វារធំនោះចេញមក....នាំមុខគេដោយអ្នកប្រុស ទីពីរ ហួត ខេមរិទ្ធិ ដែលដៃទាំងទ្វេរុញរទេះមួយ... ម្នាក់ដែលនៅលើរទេះនោះ...គ្មានអ្នកណាក្រៅពីបុរសមានអំណាចបំផុតនៃ គ្រឹះស្ថានហិរញ្ញវត្ថុនេះ ដែលគេច្រឡំថាថ្មើរណោះកំពុងដេកចាំទទួលមច្ចុរាជនៅឯមន្ទីរពេទ្យ នៅឡើយនោះ....
«ហួត ស៊ីវ???»
ប៉េងភ្លាត់មាត់ទាំងធ្លាក់ថ្លើមក្អក។
ពន្លឺភ្នែកបុរសចំណាស់ដ៏មានអំណាចបានផ្តោតមករកប៉េងហើយបបូរមាត់ គាត់ ដែលស្មើផេងនោះបានបញ្ជាក់ស្រេចហើយថាគាត់គ្មានថ្ងៃលើកលែងឲ្យ ម្នាក់នេះទេ។
ហួត ស៊ីវ និយាយមួយៗតែសូរស័ព្ទក្រអួនក្រអៅរបស់គាត់នៅតែពេញដោយអំណាចនិងភាពខ្ចីដង៖
«លេខាចំណាប់! ឯងធ្វើការឲ្យគេយ៉ាងម៉េចមិនដឹងសូម្បីតែចៅហ្វាយខ្លួនត្រូវមកចូលរួមប្រជុំ!?»

ប៉េងនៅចំកណ្ដាលអគារវែងដែលនៅចុងបំផុតនៃអគារអ្នកណាៗដែលឈរពី ក្រោយ ហួត ស៊ីវ សុទ្ធតែសម្លឹងមកគាត់ក្នុងរបៀបជាអ្នកទោស។
ប្រការនេះធ្វើឲ្យគាត់ដឹងថាការដកថយទើបជាយុទ្ធសាស្ត្រអាទិភាព ក្នុងពេលនេះ។ ដោយមិនរវល់ពីអ្នកប្រុសទីមួយដែលនៅពីក្រោយខ្នងនៅឡើយ លេខាកំហូច រីយ៉េរបេរក្រោយប្រុងរត់ ប៉ុន្តែប៉ូលិសមួយក្រុម បានបង្ហាញខ្លួនយ៉ាងស្វាហាប់នៅមិនដល់៣០ម៉ែត្រពីមុខគាត់ ដូច្នេះគាត់គ្មានទាំងផ្លូវរុលទៅមុខនិងគ្មានទាំងផ្លូវសម្រាប់បក ក្រោយឡើយ។
បុរសទាល់ច្រកនៅស្ងៀមកណ្ដាលអគារ។ គាត់ចាប់ផ្ដើមសម្លក់មនុស្សគ្រប់គ្នាជាមួយពាក្យកម្លាក្នុងចិត្តខ្លួនឯង៖
«អាហ៊ា! ពួកវាចង់ឲ្យអ្យូរជាប់គុក! តែឯងកុំសង្ឃឹមពួកអាចង្រៃ! បងប្អូនអញពីរនាក់អត់ដែលខ្លាចពួកឯងទេ! »
គាត់ងើបមុខសម្លឹងទៅបង្អួចដែលបើកចំហស្រាប់....គឺនៅចម្ងាយមិនដល់ពីរម៉ែត្រពីគាត់ផង....
ទីនេះជាកន្លែងដែលគាត់បានបើកកញ្ចក់ចំហទុកក្រែងអាចឈរដោយរីករាយ សម្លឹងឃើញអ្នកប្រុសទីមួយត្រូវគេបណ្ដេញចេញពីធនាគារនេះ តែពេលនេះគាត់នៅតែមិនខាតកម្លាំងចោលទេ ព្រោះអាចទុកប្រើសម្រាប់ខ្លួនឯងដែរ...

រហ័សដូចផ្លេកបន្ទោរ ប៉េងហក់ទៅកាន់ទីនោះ ហើយឈរបេរក្រោយទម្លាក់ខ្លួនគាត់ ចុះទៅក្រោម មួយដំណើរតាមកម្លាំងខ្យល់.....
...សមត្ថកិច្ចនិងអ្នកប្រុសទាំងទ្វេគឺនៅឆ្ងាយជាងបើធៀបនឹងចម្ងាយ ពីកន្លែងប៉េងទៅកាន់បង្អួចនោះដូច្នេះគ្មានអ្នកណាអាចហាមឃាត់ ប៉េង ពីជម្រើសចុងក្រោយនៃជីវិតគាត់បានទេ....
.....ផាំង...ប្រាវ....
....លោហិតក្រហមច្រាលនិងរូបរាងតូចស្គមនៃបុរសដែលរស់នៅជាមួយគំនុំ ពេញមួយជីវិតរហូតមកនេះ បានបញ្ចប់វិនាទីចុងក្រោយរបស់គាត់លើរថយន្តទំនើបមួយដែលទើបតែបោលចូលមកដល់
....នៅក្នុងរថនោះ ស្រីស្អាតដូចផ្កា ដែលគាត់បានចិញ្ចឹមមកដើម្បីតែមហិច្ឆតាទុច្ចរិតគឺតារាម៉ូដែល បុស្បានារី កំពុងបើកភ្នែកគ្រលួងដោយតក់ស្លុតសម្លឹងសពលោកមាគ្មានមនោស

ញោតនា របស់នាង ហើយសន្សឹមៗនាងបិទភ្នែកទន់កាយរងៀកបាត់បង់ស្មារតី.....
....ប៉ែន ពេជ្រប្រាថ្នា ខំពង្រឹងចិត្តចុះចេញពីរថយន្តហើយស្ទុះមកបើកទ្វារគ្រានាងចេញ....ឯលេខាប៉េងដេកស្លាប់ច្រងាងនៅលើក្បាលរថយន្តនោះហូរឈាមក្រហមច្រាល តាមច្រមុះនិងមាត់.....

ជំពូក២១

គ្រួសារតែមួយ

....ហួត ស៊ីវ លូកដៃមិនដល់កែវទឹកដែលនៅប្របេះនឹងកូនតុក្បែរគ្រែ ធ្វើឲ្យជ្រុះខ្ទាយទៅលើកម្រាលតដ្ឋ។
ស្នូរជើងមនុស្សម្នាក់រត់ចូលមកដល់ទាំងរលះរលាំង ....មិនមែន ហួត យុត្តនា កូនច្បងរបស់គាត់ទេប៉ុន្តែគឺជាសុភាពបុរសសម្បូរស្នេហ៍ ដែលគាត់ស្រលាញ់ពេញបេះដូងរហូតមក....ប៉ែន ពេជ្រប្រាថ្នា។
....គេឈ្ងោកចាក់ទឹកហើយលើកមកឲ្យឪពុកដោយមិនចេញស្តី។ គេជ្រប់មុខមិនហ៊ានទាំងសម្លឹងគាត់ដែលកំពុងមើលមករកនាយ។
«កូនឯងមកលឺបលនៅខាងក្រៅយូរអញ្ចឹងមិនហត់ទេ? ម៉េចមិនចូលមក?»
ប្រាថ្នាឈ្ងោកមុខសឹងដល់ដី ព្រោះខ្មាសអៀននឹងគាត់។
«ហើយឯណាម្នាក់ទៀត?»
ទ្វាររបើក គាត់រេភ្នែកទៅឃើញសំពត់ផ្កាមួយឈានចូលមកសន្សឹមៗពីក្រោយខ្នងកូន ប្រុសខ្លួន។ នាងគឺក្មេងស្រីដែលគាត់តែងតែជួបបន្លែងជាមួយតាំងពីតូចក្រូចឆ្មា មក។ ដែលគាត់សប្បាយចិត្តនៅពេលនេះគឺពួកគេសុទ្ធតែដឹងថាគាត់ជាឪពុក ហើយម្នាក់ៗបារម្ភពីគាត់មកលឺបលនៅខាងក្រៅបន្ទប់យូរណាស់មកហើយ ក៏មិនហ៊ានចូលមកខាងក្នុង។
អគ្គទេសាភិបាលច្រត់ដៃក្រោកហើយកូនប្រុសគាត់ខិនមកជួយគ្រាឲ្យគាត់ អង្គុយ។ កាយវិការគេគឺស្តាយក្រោយដែលគេបានធ្វើខុសទៅលើគាត់ព្រោះតែចាញ់ ការចាក់ដោតរបស់លេខាប៉េង ប៉ុន្តែគេមិនអាចនិយាយពាក្យសុំទោសចេញមកបាន ចេ្នះមានតែទ្រាំក្រៀមក្រំខ្លួនឯង។
«ម្តាយពួកឯងនៅឯណា?»
អមរាតបនៅពេលបងប្រុសភ្លោះរបស់នាងនិយាយមិនចេញ៖

«ជំទាវម៉ាក់នៅផ្ទះ! ហើយប្រើពួកខ្ញុំឲ្យមកសុំទោសអ៊ំ!!!! ពិ...សេស...មកអរគុណដែល.... ដែលអ៊ំផ្ទេរសិទ្ធិភាគហ៊ុនមកឲ្យពួកខ្ញុំដែល អកតញ្ញូ! ព្រឹកមិញមេធាវីបានឲ្យដំណឹងមកហើយ ....ហើយពួកខ្ញុំភ្ញាក់ផ្អើលណាស់!»

ហួត ស៊ីវ សើចស្ងួត គាត់និយាយម្តង៖

«ខ្ញុំឈឺហើយ! ទៅធ្វើការបានមែន! តែត្រូវអង្គុយលើរទេះដូច្នេះរហូត មិនដឹងពេលណាដើរបានវិញទេ! ដូច្នេះមានតែកាត់ចិត្តដើរចេញសម្រាកម្តង ទុកឲ្យពួកក្មេងធ្វើការម្តងវិញ។ កូនខ្ញុំទាំងបួនស្រីមួយប្រុសបី មានភាគហ៊ុនស្មើគ្នា។ ចំណែករបស់ខ្ញុំនៅធនាគារគឺនៅលើដៃពួកឯងទាំងបួន បើពួកឯងបែកបាក់គ្នានាំតែអ្នកផ្សេងគេឆ្លៀតបាន ត្រូវចាំថាគ្មានអ្នកក្រៅឯណាគេមកល្អ មកត្រង់នឹងយើងជាងគ្រួសារយើងទេ! ខ្ញុំធ្វើចំណែកតាមច្បាប់នេះក៏ដើម្បីម្នាក់ៗមានសិទ្ធិចូលប្រជុំ ក្រុមប្រឹក្សាភិបាលធនាគារ ហើយជួយដល់យុត្តនា!»

អមរានៅស្ងៀម ប្រាថ្នានិយាយមួយៗដោយឈ្ងោកមុខ៖

«អ៊ំស្រលាញ់ពួកខ្ញុំ ខ្ញុំដឹងហើយ ! តែអ៊ំត្រូវថែខ្លួនផង ព្រោះខ្ញុំប្រហែលត្រូវទៅឆ្ងាយ មិនបាននៅក្បែរៗនេះហើយឧស្សាហ៍មកលេងទេ ! »

«ឯងគិតទៅណា?»

ប្រាថ្នាងើបមុខសម្លឹងបុរសដែលប្រៀបដូចជាឪពុកម្នាក់របស់គេ តាំងពីដើមរៀងមក ទោះបីមិនធ្លាប់នឹកស្មានថាឈាមដែលរត់ពេញដើមទ្រូងគឺជារបស់គាត់ ក៏ដោយ។ នាយនិយាយដោយស្រងូត៖

«តាមថា ខ្ញុំត្រូវនៅថែទាំបម្រើអ៊ំព្រោះខ្ញុំជាអ្នកធ្វើឲ្យអ៊ំដួល! តែ....ខ្ញុំត្រូវទទួលខុសត្រូវលើស្រីម្នាក់! គេគ្មានអ្នកណាក្រៅពីខ្ញុំទេ!....ខ្ញុំចាំបាច់....»

«ក្មេងស្រីហ្នឹងជាអ្នកណា?»ហួត ស៊ីវ សួរកាត់ភ្លាម។

ឯគេគិតពីឈ្ងោកមុខមិនហើបមាត់។ បេះដូងគេនឹកដល់នារីកំព្រាបុស្បានារីដែលត្រៀមលក្ខណៈលះបង់ជីវិត លើវិថីសិល្បៈរបស់នាងទៅតាមនាយដើម្បីសាកល្បងស្នេហ៍ស្មោះដែលនាយ បានអះអាង។នាយនិយាយមិនចេញព្រោះតែដឹងថាគ្មានអ្នកណាម្នាក់ទទួលយក នាងបានទេ ព្រោះនាងមានប្រវត្តិទាក់ទាមនឹងលេខាប៉េងដែលបង្ករឿងឈឺចាប់ច្រើន មកហើយ។ គេមិននិយាយកើត អមរាក៏និយាយជំនួសព្រោះនាងមិនចង់លាក់លៀមអ្វីនឹងឪពុកកម្សត់ម្នាក់នេះទៀតឡើយ៖

«បុស្បានារី!»

ហួត ស៊ីវ ងៀងភ្នែកមើលមកកូនស្រី។ ទឹកមុខគាត់នៅតែស្មើ មិនអាចសម្គាល់ថាគាត់ខឹងឬស្អប់នារីតារានោះទេ។ គាត់លាន់មាត់សួរវិញ៖

«កូនខ្លាចជំទាវកុសុមាប្រកាន់ប្រវត្តិនាង?»

ប្រាថ្នាងក់ក្បាលយឺតៗ ឯអមរានិយាយបន្ត៖

«អ្នកម៉ាក់គ្មានផ្លូវព្រមដាច់ខាត!»

ប្រាថ្នាបន្តទាំងស្រងូត៖

«ហើយខ្ញុំក៏មិនអាចរស់នៅបែកពីគេដែរ!»

«ចាំប៉ាពន្យល់ជំទាវឫកធំនោះឲ្យ!»

បុរសនិយាយមួយៗតែមិនដឹងយ៉ាងម៉េចពួកគេហាក់មានជំនឿលើសម្ដីគាត់ ពិសេសពាក្យថាប៉ាដែលគាត់បានប្រើ គឺវាត្រូវពេលវេលាណាស់សម្រាប់យុវវ័យដែលរស់ក្នុងភាពឯកោនិងមាន ម្ដាយដែលស្រលាញ់កិត្តិយសហួសពីសុភមង្គលកូន។

គេមិនហាមាត់តែ ហួត ស៊ីវ ឃើញក្ដីសង្ឃឹមលេចចេញលើផ្ទៃមុខកូនភ្លោះទាំងទ្វេ។ គាត់ងាកទៅរកអមរា៖

«អមរា! ជាម្ចាស់ហ៊ុនសំខាន់ម្នាក់ កូនគាំទ្រយុត្តនា ឲ្យបន្តតួនាទីអគ្គនាយកទេ?»

អមរាគិតបន្តិច ទើបស្រដីមួយៗ៖

«បើឲ្យទុកចិត្តគេ គឺមិនអាចទេពេលនេះ ព្រោះគេមិនទាន់ឃើញមានអីច្បាស់លាស់! តែពួកខ្ញុំទុកចិត្តអ៊ំ! អ៊ំថាគេ គឺគេហើយ! ណាមួយ...ណាមួយគេនឹងពៅបញ្ញា....ថ្ងៃក្រោយពៅបញ្ញាក៏ជាជំនួយការល្អរបស់ គេដែរ! »

ហួត ស៊ីវ ងក់ក្បាលផ្ងក់ៗ គាត់ងាកមករកប្រាថ្នា៖

«បើប៉ាដោះស្រាយរឿងឯងនិងនាងម៉ូដែលនោះបាន ឯងកុំទៅណ៎ា! ត្រូវនៅទីនេះ! បើពៅបញ្ញាមកជួយការងារខាងណេះ ការងារជទៃនៅផ្ទះអាពេជ្រ គឺធ្លាក់លើស្មាកូនដែលជាកូនប្រុសធំទាំងអស់!ក្លាយជាបុរសមាន ប្រពន្ធ កូនត្រូវកែចរិតហើយម៉ឺងម៉ាត់ តើចំពោះការងារជាងមុន ទើបស្រីៗគេមិនមើលងាយ! »

គេងក់ក្បាលផ្ងក់ៗ ហួត ស៊ីវ ញញឹមហើយបន្ត៖

«ប៉ាចង់ជជែកតែពីរនាក់អាពេជ្រ! ជូនប៉ាទៅបានទេ?»

អមរាសម្លឹងមុខបងប្រុសដោយស្រងូត។

ឪពុកនាង....ប៉ែន ពេជ្រ ដែលនាងប្រើត្រកូលគាត់រហូតមក ពេលនេះគឺមិនទាន់ដឹងខ្លួននៅ

ឡើយ ។ហេតុអ្វី ហួត ស៊ីវ ជាឪពុកបង្កើតខ្លួនប្រញាប់ចង់ជួបគាត់ម្លេះ?
ទោះគិតយ៉ាងនេះក្តី នាងនៅតែងក់ក្បាលស្របៈ
«ចាំ!»

ជំពូក២២

ចំណងដែលអ្នកចងត្រូវតែស្រាយដោយខ្លួនឯង

....ហួត ស៊ីវ អង្គុយលើរទេះក្បែរគ្រែរបស់ឱកញ៉ា ប៉ែន ពេជ្រ....ប្រាកដណាស់គម្រោងការអច្ឆរិយ នោះ គឺជាប្រធានបទដែលអាចផ្តល់ជីវិតទីពីរឲ្យអគ្គទេសាភិបាលនេះរស់ ឡើងវិញ ដូច្នេះបន្ទាប់ពីពេលនោះមក គ្រប់ចង្វាក់ដង្ហើមរបស់គាត់គឺនិយាយពីរឿងនេះ....
ស្ថានភាពស្ងប់ស្ងាត់របស់មន្ទីរពេទ្យបានញ៉ាំងឲ្យ ហួត ស៊ីវ រឹតតែលង់ទៅក្នុងចំណងរឹតរួត ដោយគម្រោងពាណិជ្ជកម្មនោះ....
«អាពេជ្រ! រតនៈសោភ័ណគឺជាគម្រោងការពិត....យើងប្រាប់ឯង!»
ប៉ែន ពេជ្រ នៅតែបិទភ្នែកជិតឈឹងទៅតាមស្ថានភាពទន់ខ្សោយរបស់គាត់ដែលកំពុង ប្រឹងប្រែងប្រឆាំងទៅនឹងជំងឺព្រមទាំងមុខរបួស។
ហួត ស៊ីវ និយាយបន្តៈ
«ឯងខ្សោយណាស់ដែលយល់ថាបងរាជបានសរសេរផ្តេសផ្តាស ប៉ុន្តែកូនប្រុសយើងរកឃើញការពិត ពីគំនូររបស់បងរាជ! មុនពេលគាត់ស្លាប់គឺគាត់បានគិតគូរច្បាស់លាស់ពីពាណិជ្ជកម្ម រ៉ែ ត្បូងនោះ ហើយគាត់បានធ្វើការជាមួយជនជាតិភាគតិចពីរនាក់! ក្រដាស៥សន្លឹកដែលឯងមានវាមិនមែនគម្រោងការរតនៈសោភ័ណពិតទេ ប៉ុន្តែមនុស្សដែលកសាងផ្ទះបុរាណមួយនោះជាមួយគាត់បានរក្សាទុកនូវ ឯកសារជាច្រើនដែលគាត់ធ្វើបានពាក់កណ្តាលមកហើយ! យុត្តនាបានគិតយល់ពីអាថ៌កំបាំងនេះ ព្រោះគេបានទៅរកប្អូនគេដល់ទីនោះ! គេចូលទៅក្នុងតំបន់ហាមឃាត់ដែលព្រឹទ្ធាចារ្យកុលសម្ព័ន្ធនោះបាន រក្សាទុកដោយសារតែបណ្តាំរបស់បងរាជ! ឯងប្រាកដជាចាស់ហើយឈឺច្រើនទៀត ឯងគិតមិនយល់ទេ តែយើងមានពេលច្រើនដែរ យើងទំនេរអាចអង្គុយពន្យល់ឯងរាល់យប់ឲ្យឯងអស់ចិត្ត! ពីដំបូងបងរាជអាចថាចង់រកស៊ីទាក់ទងនឹងការទាញយកធនធានរ៉ែ នោះដើម្បីក្លាយជាអ្នកមាន  ប៉ុន្តែគាត់បានជួបជនជាតិអស់នោះនៅឆ្នាំ១៩៩១ ហើយស្នាក់នៅជាមួយពួកគេដើម្បីសិក្សាពីស្ថានភាពភូមិសាស្ត្រនិងលក្ខណៈសម្បត្តិនៃទំនៀមទម្លាប់របស់ពួកគេ ទីបំផុតគម្រោងការរបស់គាត់បានក្លាយទៅជា

គម្រោងការដែលអាចបង្កើន លទ្ធភាពនិងនិរន្តរភាពនៃធនធាននោះទៅវិញ! ពួកគេប្រហែលជាបាននិយាយត្រូវគ្នាហើយបានកសាង ទីកន្លែងមួយសម្រាប់រក្សាទុកនូវឯកសារទាំងឡាយរបស់គេ ប៉ុន្តែកន្លែងនោះមានលក្ខណៈបុរាណហើយប្រពៃណីពេក បានជាក្មេងៗយល់ថាវាជាចេតិយមួយទៅវិញ!»

ប៉ែន ពេជ្រ នៅរក្សាការស្ងាត់ស្ងៀម ឯ ហួត ស៊ីវ នៅតែនិយាយបន្តៈ
«យើងយល់ថា ឯងឈប់ដេកទៅ! យើងទៅមើលទីនោះទាំងអស់គ្នា ហើយមើលក្មេងវាអនុវត្តគម្រោងការនេះតាមវិធីរបស់បងរាជ។ កូនប្រុសទីពីរយើង ហួត ខេមរិទ្ធិ ឯងស្គាល់គេហើយ គេប្រាកដជាមានទេពកោសល្យអាចធ្វើការងារនេះបាន! »
ប៉ែន ពេជ្រ មិនឆ្លើយបានទេ ប៉ុន្តែភរិយាគាត់និយាយមកពីមាត់ទ្វារបន្ទប់៖
«អត់ទេស៊ីវ! គម្រោងការនោះ ត្រូវឲ្យទៅប្រាថ្នាជាអ្នកធ្វើ!»
ហួត ស៊ីវ បែរក្រោយ មករកអតីតនារីដែលធ្លាប់តែមានអត្ថន័យក្នុងបេះដូងគាត់។ លោកជំទាវប្រកបដោយទឹកមុខម៉ឺងម៉ាត់បោះជំហានចូលមកហើយរុញទ្វារ បិទទៅវិញជិត ព្រោះមិនឱ្យរបូតការណ៍សំងាត់ទាំងអស់នេះទៅក្រៅបន្ទប់បានឡើយ។
គាត់អង្គុយទៅលើសាឡុង ហើយបញ្ជាក់ទៅរក ហួត ស៊ីវ នូវប្រយោគទីពីរ៖
«បងពេជ្រ មិនដឹងពេលណាដឹងខ្លួនមកវិញទេ តែគម្រោងការនោះជារបស់គាត់ កូនគាត់ជាអ្នកទទួលបន្ត! ប្រាថ្នាទើបមានសិទ្ធិទទួលធ្វើគម្រោងការរតនៈសោភ័ណ!»
ហួត ស៊ីវ ងាកមករកជំទាវដ៏អស្មិមានៈ គាត់និយាយយឺតៗ៖
«នាងដឹងហើយ ថានាងនិយាយមិនត្រូវតែនាងនៅតែមានះ!»
«អត់មានអ្វីមិនត្រូវទេ! ប្រាថ្នាជាកូនប្រុសធំ! គេជាម្ចាស់គម្រោងការនេះពេញសិទ្ធិព្រោះបងរាជបានអោយមកបងពេជ្រ ចំណែកពេលនេះបងពេជ្រឈឺ កូនប្រុសទទួលជំនួសឪជារឿងធម្មតា»
«តើវាមានសមត្ថភាពបកស្រាយពីអត្ថន័យពិតរបស់ Projectនេះដែរទេ? កុំថាឡើយដល់ទៅធ្វើវា?»
ជំទាវនិយាយដោយងាកមុខចេញ៖
«គ្រាន់តែកាន់កាប់មិនចាំបាច់មានសមត្ថភាពក៏បាន! គម្រោងការល្អយ៉ាងនេះ អ្នកណាធ្វើក៏បានដូចគ្នា! លោកកុំភ្លេចណាស៊ីវ ប្រាថ្នាក៏....»

ប៉ែន ពេជ្រ ស្រាប់តែក្អកខឹកៗ រំជួយអស់ប្រាណដែលធ្លាប់តែស្តុកស្តឹង ធ្វើឲ្យស្ត្រីបុរសទាំងពីរត្រូវភិតភ័យ រវ៉ែ្នកទាំងពីររកគាត់ជាបន្ទាន់។
ក្នុងពេលដែលលោកជំទាវ ស្ទុះទៅជិតគាត់ ហួត ស៊ីវ រំកិលរទេះទៅក្បាលគ្រែហើយចុចកណ្ដឹងហៅពេទ្យ.....
....សាជាថ្មី ប៉ែន ពេជ្រ ត្រូវបានបញ្ជូនទៅសង្គ្រោះបន្ទាន់....គាត់គឺចេញចូលបន្ទប់នេះញឹកញាប់ សឹងតែក្លាយជាទម្លាប់ទៅហើយ...ដែលប្លែកលើកនេះគឺនៅក្រៅបន្ទប់ កូនៗគាត់បានមកជុំគ្នាទាំងអស់ រួមកូនប្រុសទាំងទ្វេរបស់ ហួត ស៊ីវ ផងដែរ។
គ្មានអ្នកណាម្នាក់ត្រូវបានអនុញ្ញាតឲ្យចូលទេ ដូច្នេះពួកគេនៅក្បែរបន្ទប់នេះទាំងអស់គ្នាប្រការដែលសំខាន់គឺជំទាវមិនមើលមុខអ្នកណាទាំងអស់ក្រៅពីកូនស្រី ប្រុសរបស់គាត់។
«អមរា ! ម៉េចក៏ឲ្យពួកគេមកធ្វើអីអ៊ូអរម៉េះ? មនុស្សអស់នេះម៉ាក់មិនចង់ឃើញទេ!»
ជំទាវនិយាយរអ៊ូដាក់កូនស្រីដោយទោមនស្សធ្វើឲ្យនារីរវ៉ែ្នក សម្លឹងទៅរកវិទ្ធិនិងយុត្តនាដែលនៅឯសាឡុងម្ខាងក្បែរពៅបញ្ញា។ ចំណែកសក្ខណានិងប្រាថ្នាឈរជ្រប់មុខឯជ្រុងម្ខាងទៀត។
«ជំទាវម៉ាក់! សុខភាពលោកប៉ាសំខាន់ជាងកុំទៅរវល់ខឹងរឿងផ្សេងអី!»»
ថាហើយនាងរវ៉ែ្នកទៅរកនាយវិទ្ធិដែលកំពុងកាន់ទឹកពីរកែវដើរមក រកសក្ខណា។ នាងដឹងថាអ្វីទៅដែលនៅពីក្នុងទិដ្ឋភាពនេះ ចំណែកឯជំទាវកុសុមាក៏យល់ដូចគ្នា។ គាត់សើចចុងមាត់ជាសញ្ញាមិនពេញចិត្តហើយរអ៊ូបន្តដាក់កូនស្រីធំ៖
«ក្មេងប្រុសនោះសម្លឹងខ្ពស់ហួសមាឌហើយ!»
អមរាត្រចៀកស្ដាប់សម្ដីម្ដាយ ប៉ុន្តែភ្នែកនាងតាមដានបបូរមាត់នឹងស្នាមញញឹមស្រស់របស់សក្ខណា ក្នុងពេលនាងតូចទទួលកែវទឹកពីដៃវិទ្ធិ។ នាងមិននិយាយតបនឹងម្ដាយ តែនាងទម្លាក់ភ្នែកស្រពោន មិនដឹងថានាងបារម្ភអាណិតស្នេហារបស់សក្ខណាឬអាណិតខ្លួនឯងដែលស្ដាយបុរសល្អម្នាក់នេះនោះទេ។
«អ្នកជំងឺដឹងខ្លួនហើយ!»
សម្ដីរបស់វេជ្ជបណ្ឌិតដែលទើបតែចេញមកបង្ហើបប្រាប់នេះបានបង្អើលឲ្យគ្រប់គ្នាស្ទុះចូលមកក្បែរទ្វារស្រេ។
ពៅបញ្ញាវាចាមុនគេ៖
«ខ្ញុំសុំចូលទៅមើលលោកប៉ាផងបានទេ?»

វេជ្ជបណ្ឌិតសម្លឹងមុខនាង ឯជំទាវក៏សម្លឹងមកទាំងមិនពេញចិត្ត ព្រោះគាត់យល់ថាគាត់គួរតែបានចូលទៅមុនគេ ប៉ុន្តែដោយសារគាត់មិនមែនជាភរិយាយូរមកហើយ ដូច្នេះមានតែនៅសំងំស្ងៀមទាំងមិនសប្បាយចិត្ត។
វេជ្ជបណ្ឌិតឆ្លើយតបមួយៗ៖
«គង់តែបានចូលទៅទេ! តែម្តងម្នាក់ព្រោះមិនអាចឲ្យមានអ្វីកើតឡើងរំខានអ្នកជំងឺទេ! ការសង្គ្រោះលើកនេះជោគជ័យណាស់ ប៉ុន្តែអ្នកជំងឺនៅខ្សោយ! គាត់មានជំងឺបេះដូង ដូច្នេះប្រសិនបើជួបរឿងអ្វីដែលប៉ះទង្គិចចិត្ត គាត់អាចរើមកអាក្រក់វិញភ្លាមៗបាន! សូមជួយប្រយ័ត្នចំណុចនេះ! មួយទៀតតាមសំណូមពរអ្នកជំងឺ អ្នកដែលគាត់ចង់ជួបមុនគេគឺ លោក ហួត ខេមរិទ្ធិ!»
គ្រប់គ្នាភ្ញាក់ផ្អើលនឹងព័ត៌មាននេះហើយរវៃភ្នែកទៅរកកំលោះដែល គ្មានជាប់សាច់ឈាមអ្វីនឹងឧកញ៉ាប៉ែន ពេជ្រ តែបែរជាត្រូវបានហៅឲ្យចូលទៅជួបមុនគេ ។
អ្នកប្រុសទីពីរក៏ងឿងឆ្ងល់ តែគេបោះជំហានវែងៗតម្រង់ទៅកាន់ទីនោះភ្លាមមិនរវល់នឹងការគិតឃើញ របស់មនុស្សជុំវិញខ្លួនឡើយ។
គេរុញទ្វារចូលទៅ....បរិយាកាសគឺមិនខុសអ្វីពីពេលមុនៗដែលគេតែងតែ ចំណាយពេលជាមួយបុរសចំណាស់នេះពិភាក្សានិងជជែកលេង ឆ្លងកាត់ដំណាក់កាលតស៊ូនឹងជំងឺរបស់គាត់នោះទេ....

ជំពូក២៣

ក្រោយភ្លៀងមេឃស្រលះ?

...រថយន្តឈប់ង៉ក់នៅពីមុខលានវាយកូនគោល។ ទីនេះជាកន្លែងដែលសក្ខណាធ្លាប់តាមរិទ្ធិយ៉ាងឆ្ងាយព្រោះតែនិស្ស័យ ស្អប់បង្កប់ស្នេហ៍។ ក៏ជាកន្លែងដែលនាងត្រូវបានគេផ្ទប់មាត់ចាប់ហើយបានឱកាសបង្កើតអនុស្សាវរីយស្នេហ៍ជាច្រើនជាមួយអ្នកប្រុសទីពីរ។
នាងចុះពីររថយន្ត ហើយពៅបញ្ញាចុះតាមពីក្រោយ។ ឡានមួយទៀតអែបឈប់ដែរនោះ គឺប្រាថ្នានិងអមរាបន្ទាប់មករថយន្តទីបីគឺយុត្តនានិងរិទ្ធិ។
យុវជនទាំង៦នាំគ្នាចូលទៅកាន់បរិវេណវាលស្មៅបៃតងស្រស់អមបណ្តោយដង ស្ទឹងត្រជាក់ចិត្តជាទីដែល ហួត ស៊ីវ តែងតែចំណាយពេលចុងសប្តាហ៍មកជួបកូនប្រុសៗរបស់ខ្លួន។
ពេលដែលស្រីៗនាំគ្នារៀបចំភេសជ្ជៈ ប្រាថ្នាឈរសម្លឹងផ្ទៃទឹក។ យុត្តនានៅឈរផ្អែកនឹងដើមឈើលេងទូរសព្ទធ្វើហី ទុកឲ្យរិទ្ធិដើរទៅនិយាយជាមួយនាយកK-P-Iដែលសែនស្រងូត៖

«ម៉េចមិននាំបុស្បាមកលេងផង!»
«ហៅហើយ! តែគេថាចង់នៅស្ងាត់ស្ងៀមសិន! គេនៅពិបាកចិត្តរឿងពូគេស្លាប់!»ប្រាថ្នា និយាយមួយៗទាំងភ្នែក សម្លឹងមើលទៅខ្សែទឹក។
ពៅបញ្ញា យកទឹកក្រូចមកពីរកែវហើយហុចឲ្យពួកគេ។ នាងមិនមាត់ តែរិទ្ធិនិយាយបន្ថែមៈ
«បើកុំបានឯងទេប្រាថ្នា! ខ្ញុំក៏មិនដឹងថា គម្រោងការរតនៈសោភ័ណមានឥទ្ធិពលលើតាចាស់នោះ ហើយយើងចាត់ការវាបានងាយស្រួលយ៉ាងនេះដែរ!»
ប្រាថ្នាក្រេបទឹកក្រូចហើយទើបឆ្លើយៈ
«បុស្បាប្រាប់ខ្ញុំ!»
«នៅទីបំផុតនាងសុខចិត្តជួយយើងប្រឆាំងនឹងពូនាង?»
«ទេ! នាងគ្រាន់តែចង់ឲ្យគ្រប់គ្នាបានសុខហើយចង់ឲ្យពូនាងរួចទោស! តែឥឡូវនេះ លទ្ធផលទៅជាអញ្ចឹង! នាងប្រហែលត្រូវការពេលយូរនឹងធ្វើចិត្តបាន!»
«ត្រូវការខ្ញុំទៅជួយនិយាយទេ?»អមរានិយាយបណ្ដើរដើរមកបណ្ដើរ។
រិទ្ធិសម្លឹងនាង គេដឹងថាអមរាបានដើរតួនាទីសំខាន់នៅក្នុងការជួយពន្យល់បុស្បា បន្ថែមពីលើយុត្តនា។ ដូច្នេះហើយបានជាចុងក្រោយបុស្បាគិតយល់ ហើយសុខចិត្តចាកចោលការរួមគំនិតជាមួយប៉េង។
ពៅបញ្ញា ដែលនៅស្ងៀមយូរហើយលូកមាត់សួរវិញៈ
«ស្ដាប់យូរទៅ ដូចអ្នកទាំងអស់គ្នាបានដឹងផែនការមុនហើយរួមដៃគ្នាកម្ចាត់តាប៉េងនោះ?»
រិទ្ធិមុនពេលឆ្លើយតបទៅនឹងមេធាវីតូចគេដៀងភ្នែកទៅរកយុត្តនាដែលនៅឈរឆ្ងាយពីគេសិន ទើបងាកមកឆ្លើយៈ
«តាមពិត តាំងពីថ្ងៃដែលយុត្តនាទៅរកខ្ញុំនៅរតនគិរី គឺខ្ញុំបានដឹងថាប៉េងនៅពីក្រោយរឿងសំណង់Java ទៅហើយ! ដែលសំខាន់ពីរនាក់យើងដឹងថាយើងគ្មានភស្តុតាងគ្រប់គ្រាន់សម្រាប់ លេងវាវិញទេ ដូច្នេះឱកាសរបស់យើង គឺខ្ញុំបន្តធ្វើជាបាត់ខ្លួនសិន! ខ្ញុំលួចត្រលប់មកវិញនៅភ្នំពេញគឺមានតែយុត្តនាទេដែលដឹង ហើយបន្ទាប់មកខ្ញុំបានដំណឹងថាលោកប៉ាដួល! យុត្តនាបានជួបប្រាថ្នាតាមផ្លូវ គេដឹងថាប្រាថ្នាចាញ់បោកលេខាប៉េងទៅហើយ! ល្បិចរបស់គាត់គឺព្រួញមួយបាញ់បានសត្វពីរ ទោះបីយើងនិយាយរឿងពិតឬមិនពិត បើយុត្តនារួចខ្លួនគឺប្រាថ្នាជាអ្នកជាប់ទោសព្រោះប៉ានៅ សម្រាន្តលក់មិនអាចក្រោកមកការពារកូនៗបាននៅចំពោះមុខភាគហ៊ុនទេ ដូច្នេះ ខ្ញុំត្រូវតែទៅរកតានោះធ្វើឲ្យគាត់យល់ថាខ្ញុំសង្ស័យយុត្តនា !»

«ពូកែលេងល្បិចដូចតួកុនអញ្ចឹងហ្ន៎?»
សក្ខណានិយាយឌឺពីចម្ងាយហើយលើកទឹកមួយកែវមកឲ្យគេ។
«ម៉េចឲ្យទឹកសអញ្ចឹង? គេបានទឹកក្រូចគ្រប់គ្នា» គេសួរទាំងក្នាញ់ចំពោះទឹកមុខង៉ក់ងររបស់នាង។
«សំណាងហើយដែលគ្មានទឹកបណ្ដូលពេជ្រមកជាមួយ!» នាងឆ្លើយទាំងក្ដាប់មាត់។
រិទ្ធិញញឹមហាក់ក្នាញ់នឹងភាពញ៉ិកញ៉ក់របស់ស្រីតូច។ នាយលែងនិយាយស្ដីតែដៀងសម្លក់នាងដោយខ្សែភ្នែកស្រទន់ធ្វើឲ្យ ពៅបញ្ញានឹកឃើញដល់ម្ចាស់បេះដូងនាង ហើយរវើភ្នែកទៅរកនាយ ចំពេលអ្នកប្រុសទីមួយដៀងមកសម្លឹងនាងដូចគ្នា។
គេនៅតែមិនដើរចូលមកក្នុងចំណោមអ្នកជជែកទេ នេះជាចរិតរបស់គេ ដូច្នេះមេធាវីដើរទៅរកគេយឺតៗហើយនិយាយឌឺដង។
«គ្រាន់បើណាស់ហ្ន៎ លោកនាយកធនាគារ! ចេះលាក់ជិតល្អណាស់ហ្ន៎! មកពីចេតិយនោះវិញមួយម៉ាត់ក៏មិនប្រាប់ថាបានជួបប្អូនប្រុសលោក ដែរ ហើយធ្វើមុខស្លូត បោកចិត្តគេឯងឲ្យអាណិតទៀត!»
យុត្តនាញាក់ចិញ្ចើមតប ព្រមពេលដៃគេចុចទូរសព្ទបិទដែរ។ គេនិយាយធ្វើហី៖
«ជាមួយពួកមេធាវី ពួកអ្នកចេះច្បាប់អីអស់នេះ បើមិនលេងល្ខោនអោយខ្លាំងម៉េចបាន? ដើរតួមិនដល់គឺគេអត់ជឿទៀតហ្នឹង!!! នាំតែពិបាក!»
«ឥឡូវនេះក៏គ្មានអ្នកណាជឿលោកដែរ! ពីរនាក់បងប្អូនលោកនេះពូកែសម្ដែងឫកពេញទីហើយ! គួរតែទៅបើកក្រុមល្ខោនមួយទៅ!»ពៅបញ្ញានិយាយទាំងង៉ក់ងរ។
អមរា ឃើញបរិយាកាសពោរពេញទៅដោយពណ៌ស៊ីជម្ពូ នាងដឹងថាពួកគេកំពុងលង់ក្នុងភាពក្និកក្នក់ដាក់គ្នា ក៏ញញឹមនិយាយម្ដង៖
«ពៅ! ឯងបន្ទោសគេធ្វើអី? បើកុំតែបានពួកគេ បងនិងបុស្បាត្រូវតានោះបោកប្រើដូចតែគ្នាហើយរហូតដល់ឥឡូវមិនដឹងជាមានរឿងស្មុគស្មាញអីខ្លះផងទេ! បើយុត្តនាមិនឲ្យរិទ្ធិទៅក្បែរតានោះទេក៏គាត់ច្បាស់ជាមាន ក្រឡាផ្សេងទៀតមកទប់យើងដែរ! សរសើររឿងមួយគឺគេពីរនាក់ចេះវិធីមានដោះស្រាយបញ្ហាបានគឺធ្វើ យ៉ាងណា ឲ្យសត្រូវងាកមកជាមិត្ត!! រឿងនេះបងរៀនសូត្របានច្រើនពីយុត្តនានិងរិទ្ធិ!»
សក្ខណាសួរវិញភ្លាម៖
«តែកាលក្នុងពេទ្យ គឺបងអមរាឯងថា...»

«ត្រូវហើយ! កាលហ្នឹងយើងត្រូវបុស្បាបញ្ចុះបញ្ចូលឲ្យខឹងពៅបញ្ញាព្រោះយល់ថា គេកាន់ជើងអ្នកក្រៅធ្វើបាបបងប្រាថ្នាឲ្យបាត់ខ្លួនក៏មិនសារភាព! អញ្ចឹងបានបងនិយាយរំអុកអ្នកម៉ាក់ឲ្យធ្វើយ៉ាងណាឲ្យពៅបញ្ញាអស់ សិទ្ធិបណ្ដោះអាសន្នមិនអាចឡើងការពារយុត្តនាបាន! ប៉ុន្តែពេលចេញពីពេទ្យមកវិញរិទ្ធិបានស្ទាក់ជួបបង! គេបានពន្យល់បងពីការងារគ្រប់យ៉ាង ពេលហ្នឹងហើយ បងបានយល់ក៏ចេញទៅណាត់ជួបបុស្បានៅហាងកាហ្វេ! នៅកន្លែងនោះបងបានជួបពៅ ហើយឃើញបុស្បាជះទឹកដាក់វា ក៏វាមិនតបតខឹង បងដឹងថាពៅបញ្ញាមិនមានសារធាតុជាមនុស្សអាក្រក់ទេ ដូច្នេះបងបានសម្រេចចិត្តតាមដានបុស្បាវិញ។ យប់នោះបងចេញពីក្លឹបក៏ជិះកាត់ Apartmentនាង។ បងឃើញលេខាប៉េងជិះម៉ូតូឌុបចេញបង សង្ស័យក៏ឡើងទៅមើល គឺបុស្បាកំពុងព្យាយាមសម្លាប់ខ្លួនឯង! នាងអស់សង្ឃឹមខ្លាំង នាងមានរបួសផង ឈឺចិត្តផង! ទីបំផុតបន្ទាប់ពីនិយាយត្រូវគ្នា នាងបានសន្យានឹងបងថានឹងគិតសាជាថ្មីឡើងវិញដោយព្រមធ្វើអំពើល្អ តែនាងមានលក្ខខណ្ឌថាគ្រប់គ្នាត្រូវតែអភ័យទោសឲ្យពូនាង នាងនឹងនាំគាត់ទៅទំនប់រលកវិញ!»

សក្ខណាតបទាំងគ្នាន់ក្នាញ់៖

«មនុស្សដូចតានោះបើនៅរស់ក៏នឹងបង្កើតភ្លៀងផ្គរទៀតដដែលហ្នឹង! គ្រប់គ្នាជឿថាគាត់ព្រមដែរ? ទៅស្រុកកំណើតវិញ? លើកនេះសំណាងហើយដែលគាត់ធ្លាក់ស្លាប់បានវាចប់រឿង!»

អមរាបន្តភ្លាម៖

«ពួកយើងក៏គិតអញ្ចឹងដែរបានជាយើងពន្យល់បុស្បាថាតាមពិតពូនាង គឺមិនអាចរួចខ្លួនទេ! គាត់កសាងអំពើអាក្រក់និងល្មើសច្បាប់ច្រើន ចុងក្រោយគាត់ដល់ថ្នាក់ចង់សម្លាប់សូម្បីក្មួយស្រីដែលដើរតាម គាត់មកតាំងតែពីតូច! យើងពន្យល់នាងថា គាត់គួរតែទុកឲ្យច្បាប់ដោះស្រាយ! បើគាត់ទៅនៅក្នុងគុក ក្រែងលោគាត់មានពេលអង្គុយគិតពីកំហុសហើយមិនបង្កទោសបន្ថែម!»

«ហើយបុស្បាថាម៉េច?»ពៅបញ្ញាសួរម្ដង។

អមរានិយាយតប៖

«យើងទាំងពីរនាក់ពន្យល់នាង នាងនៅតែមិនព្រមព្រោះមិនដាច់ចិត្ត តែចុងក្រោយបងប្រាថ្នាបាននិយាយនឹងនាង នាងមិនដឹងយ៉ាងម៉េចក៏ព្រម។

គ្រប់គ្នារវេភ្នែកទៅរកប្រាថ្នា គេងើបមុខមកឃើញម្នាក់ៗហាក់រង់ចាំចម្លើយពីគេគេក៏និយាយ

បកស្រាយ៖
«យប់នោះខ្ញុំសន្យានឹងគេថាបើគេព្រមឲ្យពួគេទទួលទោសទៅកែខ្លួន ក្នុងគុក ខ្ញុំក៏សុខចិត្ត លះបង់គ្រប់យ៉ាងនៅភ្នំពេញនេះ គ្រួសារមុខការហើយលុយកាក់ចេញទៅនៅស្រុកក្រៅតែពីរនាក់គេ មិនរវល់នឹងអ្វីៗនៅទីនេះទាំងអស់!»
«បងឯងសន្យាម្ល៉ឹងៗ រឿងអីស្រីៗគេមិនទន់ចិត្ត! ហើយ K-P-Iអ្នកណាមើលខុសត្រូវ?»
ប្រាថ្នាឈ្ងោកមុខជ្រប់៖
«បងនិយាយហើយត្រូវតែធ្វើ! កាលណោះដើម្បីជួយអ៊ំស៊ីវនិងបញ្ចប់រឿងរញ៉េរញ៉ៃនៅធនាគារគាត់បង គិតគាត់ដូច្នេះ ស្អីក៏បងត្រូវធ្វើដែរឲ្យតែបុស្បាព្រមប្រាប់ចំណុចខ្សោយរបស់ ពួគេ! »
«គឺរតនៈសោភ័ណមែនអត់?»ពៅបញ្ញាសួរ។
ប្រាថ្នាងក់ក្បាលផ្ងក់ៗហើយពោលបន្ថែម៖
«ត្រូវ! ....ឥឡូវនេះពួគេមិនត្រឹមជាប់ទោស ទេគឺស្លាប់តែម្តង ដូច្នេះបងរឹតតែត្រូវរក្សាសន្យាជាមួយគេកុំឲ្យគេខូចចិត្ត!»
«មិនមែនទេ! ពួគេស្លាប់តែហោងហ្នឹងហើយដែលគ្មានអីត្រូវគិត! គេរឹតតែមិនចាំបាច់ចេញទៅឆ្ងាយហើយបងអាចបន្តនៅភ្នំពេញធ្វើការងារ របស់បងតាមធម្មតាបាន! គឺគេក៏អស់បន្លាក្នុងទ្រូង»
សក្ខណានិយាយទាំងញញឹម។ ប្រាថ្នារាងធូរស្រាលចិត្តនាយងាកមកសួរប្អូនស្រីភ្លាម៖
«ស្រីៗគិតអញ្ចឹងមែន? អាចបុស្បាព្រមទេ?»
សក្ខណាមិនឆ្លើយតែពៅបញ្ញាឆ្លើយតបវិញ៖
«ព្រម!!!!»
ប្រាថ្នាមិចភ្នែកសម្លឹងមុខប្អូនស្រីម្នាក់នេះ គេមិនទាន់បានសួរផងយុត្តនាឱមកវិញ៖
«ច្បាស់លាស់ម៉េះមេធាវី?»
នារីក្របួចមាត់ នាងមិនរវល់តបនឹងបុរសកំពូលដួងចិត្តទេ តែនាងនិយាយតបនិងបងប្រុស៖
«បងប្រាថ្នា! ស្រីៗគឺរស់ដើម្បីមនុស្សប្រុសដែលគេស្រលាញ់! បុស្បាគឺស្រលាញ់បងជាងជីវិតរបស់នាង អញ្ចឹងហើយបានជាកាលនោះ នាងខឹងផ្ទះនេះយ៉ាងណាក៏នៅតែ នាងសុខចិត្តលាក់បងពីពួនាង ហើយចុងក្រោយក្បត់ពួនាងដើម្បីបង! មិនមែនមកពីនាងត្រូវបងរិទ្ធិ យុត្តនា ឬអ្នកបងអមរាលួងបានទេ ប៉ុន្តែពួកគេធ្វើឲ្យនាងទទួលស្គាល់ចិត្តស្រលាញ់លើបង ហើយឲ្យនាងសម្រេចចិត្ត!ការសម្រេចចិត្តនេះបង្ហាញច្បាស់ហើយថានាង អាចធ្វើគ្រប់យ៉ាងដើម្បីបង!

អញ្ចឹងមានរឿងអី ដែលថានាងសុខចិត្តឲ្យប្រុសដ៏ពូកែរបស់នាងបោះបង់ការរកស៊ីហើយបោះបង់អ្វីៗនៅទីនេះ ទៅឆ្ងាយជាមួយនាង?»
ប្រាថ្នាចាប់ផ្ដើមឆ្លេឆ្លាដោយរំភើបសក្ខណាក្ដាប់មាត់និយាយតឿន៖
«នៅធ្វើអីទៀត? ទៅរកគេភ្លាមទៅ!»
ប្រាថ្នាញញឹមឡើងវិញតិចៗបន្ទាប់ពីស្រពោនយូរមកហើយ៖
«ត្រូវហើយ! បងគួរទៅរកគេ!»
«យ៉ាប់មែនបងខ្ញុំ!»សក្ខណានិយាយផងរុញគេផង។
បានឱកាសប្រាថ្នារត់សំដៅឡានជាមួយវាចាផ្ដាំ៖
«ថ្ងៃក្រោយចាំជួបគ្នាទៀត! ខ្ញុំនឹងនាំគេមកដែរ!»
ពៅបញ្ញានិងសក្ខណាញញឹម ពេលឃើញភាពរំភើបរីករាយរបស់បងប្រុសខ្លួនដែលធ្លាប់តែជាព្រាននារីម្នាក់។
«គាត់អស់លក្ខណ៍ហើយ!»អមរាអ៊ូតិចៗ។
ស្រីតូចសក្ខណាបន្ថែមភ្លាម៖
«មែនហ្នឹង!»
ដឹងអីពៅបញ្ញាញញឹមនិយាយទាំងក្រពាត់ដៃ៖
«ស្មានមានតែបងប្រាថ្នាម្នាក់ហ្អី? អ្នកផ្សេងទៀតក៏អស់លក្ខណ៍ដែរ!»
អមរាញាក់ចិញ្ចើមញញឹមព្រោះយល់ការណ៍តែធ្វើជាសួរធ្វើពើ៖
«អ្នកណាទៅហ្ន៎? ដែលអស់លក្ខណ៍ដូចបងប្រុសខ្ញុំដែរ?»
«អ្នកដែលធ្លាប់តែធ្វើមុខស្មើៗ សុភាពៗ ឥឡូវក្លាយ....»
រិទ្ធិដឹងថានាយកំពុងជាចំណុចស៊ីបហើយបានជារភ្នែកមកសម្លឹង នាងតូចម្ចាស់បេះដូងចំពេលនាងញញឹមខ្ទឹបមុខក្រហមងៅ ។ នាងដឹងថាគ្រប់គ្នាសុទ្ធតែឌឺនាង នាងក៏និយាយបន្លប់៖
«នែ៎ អ្នកខ្លះមិនទាន់និយាយប្រាប់យើងទេថា ហេតុអ្វីប៉ាដឹងខ្លួនមកវិញភ្លាមហៅគេហ្នឹងឲ្យចូលទៅមុនគេ!?»
អ្នកប្រុសដើរមកឈរក្បែរនាងហើយដៃនាយលូកវាវរកម្រាមនាងទាំង ប្រាំ ទោះបីស្រីតូចខំគេចម្រាមចេញ តែគេនៅតែក្រសោបទាល់តែបានទើបអស់ចិត្ត។ នាងនិយាយរអ៊ូ៖
«បងប្រាថ្នាអាចថាអស់លក្ខណ៍តែគេនេះ មិនមែនអស់លក្ខណ៍ទេគឺចាប់ផ្ដើមយ៉ាប់ហើយ! បង

រិទ្ធិរបស់ឯង ណ៎ាពៅបញ្ញា គឺដូរពីសុភាពមកជាកាង ទំនើង ឌីហើយ....»
«ហើយម៉េចទៀត?»គេបន្ថែមដៃម្ខាងមកលើចង្កេះនាងក្នុងពេលស្រីៗពីរនាក់ទៀតកេះគ្នាអៀនងាកមុខចេញ។
ស្រីតូចមិននិយាយអ្វីបន្ថែមបានត្រឹមក្ដាញ់ដៃគេ ដែលមានះមកប៉ះពាល់នាងបានឱកាសគេនិយាយ៖
«ទោះទំនើង ទោះកាង តែអ្នកនាងត្រូវជួបគេនេះច្រើនទៀតដដែលហ្នឹង គេចមិនរួចទេ!»
«ដេកយល់សប្ដិម្នាក់ឯងទៅជំនួយការរិទ្ធិ!»
«យល់សប្ដិយូរហើយ តែម្សិលមិញក្លាយជាការពិតស្រេច! គឺលោកឧកញ៉ាហៅចូលទៅ ផ្ដាំខ្ញុំឲ្យបង្ក្រាបកូនស្រីយ៉ាប់មួយរបស់គាត់ម្នាក់ដែលទៅរៀន ស្រុកគេយូរពេក ចរិត មួយបេនពេកត្រូវការឲ្យមានគេសង្កត់ចេញខ្លះ!»
«អត់ជឿទេ! មិនដែល!!!!! លោកប៉ាឯណាក្រោកពីឈឺមកនិយាយរឿងអស់នេះ?»
គេញញឹមសម្លឹងមុខនាង តែនាងដឹងហើយថាបុរសនេះមិនមែនជាមនុស្សនិយាយកុហកទេ នាងក៏នៅស្ងៀមទាំងបេះដូងលោតញាប់។
«លោកប៉ាពិតជានិយាយរឿងនេះមែនអ្វី? ដែលហៅបងរិទ្ធិឲ្យចូលទៅមុនគេ?»ពៅបញ្ញា សួរវិញព្រោះចាប់អារម្មណ៍។

«បើគាត់ដឹងថាមនុស្សដែលគាត់ធ្លាប់តែស្រលាញ់ទុកចិត្តតាមពិតជាជនបង្កប់ម្នាក់ គាត់ប្រាកដជាខូចចិត្ត»
សក្ខណាបន្ថែមមុនរិទ្ធិអាចហើបមាត់បាន។ តែអ្នកប្រុសទីពីរឆ្លើយទាំងធ្វើឡូយដាក់នាង ៖
«ខុសហើយ! គាត់មិនត្រឹមតែមិនប្រកាន់ទេគឺស្រលាញ់ខ្ញុំលើសដើម!»
«ក្អួតមិនចេញទេ!»
នាងងាកទៅម្ខាងឌីគេតែពៅបញ្ញាមិនចង់ឲ្យពួកគេងរង៉ក់គ្នារំខានការចង់ដឹងរបស់នាងឡើយ បានជាមេធាវីតូចនិយាយកាត់៖
«និយាយទៅបង លោកប៉ាថាម៉េចខ្លះ?»
រិទ្ធិធ្វើមុខមាំទាំ គេនិយាយមួយៗ៖
«លោកឧកញ៉ាប្រគល់គម្រោងការរតនសោភ័ណឲ្យខ្ញុំដំណើរការ!»
ម្នាក់ៗរភ្នែកមករករិទ្ធិ ស្របពេលគេពោលយឺតៗបន្ថែម៖

«លោកជ្រាបយូរហើយថាខ្ញុំមកផ្ទះនេះតាមបញ្ជាលោកប៉ា ហួត ស៊ីវ តែលោកឧកញ៉ាតែងតែធ្វើមិនដឹងហើយជានិច្ចជាកាលបង្អើបប្រាប់ខ្ញុំ ពី Project នោះ!»
ពៅបញ្ញាងក់ក្បាលផ្ងក់ៗយល់សាច់រឿង។ អមរានិយាយវិញខ្សឹបៗ៖
«ចុះលោកគិតយ៉ាងម៉េចទៅ? លោកព្រមទៅធ្វើវាទេ?»
រិទ្ធិដៀងភ្នែកមកយុត្តនា ៖
«គេនេះគួរតែទៅជាមួយខ្ញុំ! គម្រោងការរតនសោភ័ណគឺគេជាអ្នកបំបែកបាន យើងត្រូវការមនុស្សពូកែច្រើនមករួមដៃគ្នា ព្រោះមិនចង់ឲ្យ អ៊ំរាជខកបំណង!»
ម្នាក់ៗរេភ្នែកទៅរកយុត្តនា តែពៅបញ្ញាដឹងហើយថាបើឲ្យគេទៅនៅក្នុងព្រៃដូចឲ្យគេទៅស្លាប់អញ្ចឹងដែរតាមចរិតបុរសអ្នកលេងរបស់នាង។
នាងញញឹមមិននិយាយតែសក្ខណាសួរវិញ៖
«យុត្តនា! លោកមិនប្រកែកទេមែនអត់?»
យុត្តនា ដៀងភ្នែកសម្លឹងមកមេធាវីតូចសិនមុនពេលគេឆ្លើយ៖
«បើខ្ញុំទៅដែរមិនរំខាន យប់ផ្សំដំណេករបស់នាងហើយសក្ខណា?»
«ស៊ីគេទៅ?»សក្ខណានិយាយទាំងអៀនខ្មាស។
«ស៊ីគេនោះចង់ដឹងសួរបងរិទ្ធិនាងក៏បាន! នាងស្មានថាគេព្រមចូលទៅនៅក្នុងព្រៃហើយគ្មាននាងអ្វី?»
យុត្តនានិយាយពីគូមួយនេះ តែភ្នែកគេដៀងមករកស្រីតូចរបស់គេជានិច្ច។

រិទ្ធិបានឱកាសនិយាយវិញផ្ទួង៖
«ព្រៃនោះក្រាស់មិនងាយរកផ្លូវជាតិឃើញទេ កុំថាឡើយ facebook សូម្បីតែរកបាយឆ្ងាញ់មួយចានក៏យ៉ាប់ មានស្រីស្អាតឯណាគេព្រមទៅនៅជាមួយខ្ញុំនោះ? អ្នកធ្វើ Projectរតនៈសោភ័ណមានតែទ្រាំរស់នៅម្នាក់ឯងដូចអ៊ំរាជអញ្ចឹងដែរ!»
«គ្មានអ្នកណាខ្វល់ទេ»សក្ខណារអ៊ូតិចៗធ្វើឲ្យម្នាក់ៗទៅជាអស់សំណើចនឹងចរិតរបស់នាងឯអមរានិយាយកាត់៖
«រិលមុខនឹងគេឌឺគ្នាណាស់នៀក!»
នាងរៀបនឹងដើរចេញ តែយុត្តនាហៅ៖
«អមរា!»

អមរាងាកមកវិញទាំងញញឹម យុត្តនានិយាយបន្តទាំងឈានទៅក្បែរនាង៖
«ប៉ា ហួត ស៊ីវ ស្រលាញ់នាងណាស់! នាងជាកូនស្រីតែមួយគត់របស់គាត់! សេចក្តីសុខរបស់នាងជាអ្វីដែលគាត់ចង់បាន! យប់មិញ គាត់បានប្រាប់បងប្អូនខ្ញុំទាំងពីរឲ្យតាមមើលនាង! ពេលនេះរិទ្ធិមិននៅ គេទៅព្រៃជ្រៅបាត់នាំទាំងប្អូននាងទៅផង អញ្ចឹងខ្ញុំជាអ្នកនៅទំនេរ! នាងទៅធនាគារធ្វើការទៅ គឺទេសាភិបាលស្រីទីមួយ ហើយមានការអ្វីនាងអាចរកខ្ញុំបានគ្រប់ពេល! នាងជាអគ្គនាយកចាប់ពីស្អែកទៅ ហើយគ្រប់គ្នាក្នុងគ្រួសារនឹងគាំទ្រនាង!»
ឯអមរាញញឹមតបវិញ៖
«ខ្ញុំសំណាងពេកហើយមានប៉ាដល់ទៅពីរសុទ្ធតែស្រលាញ់ខ្ញុំ! យប់មិញប៉ាខ្ញុំក៏ផ្តាំខ្ញុំឲ្យមើលពៅបញ្ញាដូចគ្នា! ចំណែកបងប្រាថ្នានិងខ្ញុំបានគិតរួចហើយយើងនឹងប្រើសិទ្ធិជា ភាគហ៊ុនដែលប៉ា ហួត ស៊ីវ ចែកឲ្យ បោះឆ្នោតបន្តអាណត្តិលោកនៅធនាគារ! លោកមិនទៅព្រៃ តែការងារត្រូវធ្វើ ប៉ា ប៉ែន ពេជ្របានឲ្យមកបងប្រាថ្នាអស់ហើយ អញ្ចឹងពៅបញ្ញាគឺទំនេរអាចទៅនៅជាជំនួយការលោកបាន! លោកត្រូវចេះថែរក្សាជំនួយការឆ្នាសនេះ បើមិនអញ្ចឹងទេលុយលោកប៉ុន្មានក៏ជួលគេមិនបានយូរដែរ!
«ចុះនាង?» យុត្តនាសួរ
«ខ្ញុំចង់មានពេលសម្រាប់ខ្លួនឯង! គ្រប់គ្នាមានសុភមង្គលអស់ហើយចង់រត់ទៅបាត់ទុកខ្ញុំឲ្យធ្វើការ កាលណាខ្ញុំអាចរកបានបុរសល្អម្នាក់ទៅ!?»
តែសក្ខណានិយាយកាត់ភ្លាម៖
«តែថ្ងៃមុនខ្ញុំឃើញបងនៅជាមួយប្រុសម្នាក់នៅហាងតែ!»
អមរាញញឹម៖
«ដំណាក់កាលទីមួយទេ មិនទាន់ដឹងចិត្តគ្នានៅឡើយ!»
សក្ខណាបន្តភ្លាម៖
«គេនោះសង្ហាណាស់តែខ្ញុំដូចធ្លាប់ឃើញ! តែរកនឹកមិនចាំសោះថាជួបនៅឯណា!»
«នៅក្នុងឃ្លាំង!» រិទ្ធិនិយាយកាត់។
សក្ខណាងាកមករកនាយហើយនៅតែបង្ហាញទឹកមុខថានាងនឹកមិនចេញ។ រិទ្ធិនិយាយបន្ថែមភ្លាម៖
«ម្នាក់នោះចូលទៅជួយយើងម្តងជាពីរដងឲ្យដែកកេះខ្ញុំ....ហើយ....ហើយគេឲ្យខ្ញុំ...»
«គេហាមលោកកុំឲ្យរវល់នឹងខ្ញុំនោះមែនអត់?..» សក្ខណាទើបតែនឹកឃើញ។

រិទ្ធិញញឹមគេឌឺ៖
«នាងឆ្នាសពេកម្នាក់នោះគេបារម្ភពីខ្ញុំ!»
សក្ខណាបួញមាត់ងាកមករកបងស្រី៖
«មនុស្សនោះមិនសមនឹងបងឯងទេ!»
អមរាញញឹមមិនមាត់។ សក្ខណាសួរបន្តមិនអស់ចិត្ត៖
«ហើយ...គេនោះជាអ្នកណា? ម៉េចមកតាមជួយលោកម្តងហើយម្តងទៀត ហើយចុងក្រោយមកស្គាល់បងស្រីខ្ញុំ??? រញ៉េរញ៉ៃណាស់!»
រិទ្ធិក្រពាត់ដៃ អមរាលូកដៃមកឱបសក្ខណាហើយបណ្តើរនាងដើរតម្រង់ទៅរកមាត់ទឹក មាត់ឆ្លើយ៖
«គេជាពេទ្យ! គេជាមិត្តភក្តិបងមកពីជប៉ុន តែគេធ្វើពេទ្យនៅទីនេះ! គេតាមស្រលាញ់បងយូរហើយដំបូងបងស្អប់គេណាស់ តែពេលគេតាមពេក បងនិយាយលេងនឹងគេថាបើគេស្រលាញ់បងមែន ត្រូវទៅនៅជិតប៉ា ហួត ស៊ីវ ស៊ើបរឿងពិតឲ្យបង គឺបងដឹងថាគាត់តាមពិតជាប៉ាបងបង្កើត គឺបងចង់ដឹងអ្វីទាំងអស់នៅក្នុងផ្ទះនោះ! ដឹងអីចុងក្រោយ គេទៅតាម តែម្នាក់នោះល្ងង់ណាស់! ឯងដឹងអត់គេបន្លំជាកូនចៅរបស់ពួកលេខាប៉េង ទីបំផុតក៏ត្រូវលេខាប៉េងនាំគ្នាទៅចាប់រិទ្ធិ គេក៏ទៅជាមួយនោះទៅ! តាមមើលគេមិនស្គាល់ឯងថាជាអ្នកនាងទេ ហើយឃើញឯងកាចពេកបានជាកាលហ្នឹងឃាត់ជំនួយការរិទ្ធិមិនឲ្យនៅ ទាក់ទាមជាមួយឯងគេខ្លាចគាត់រត់មិនរួច!»
«ចុះគេដែលស្គាល់ ហួត ខេមរិទ្ធិ ពីកាលណាហេតុអ្វីជួយគាត់ម្តងជាពីរដង!»
«ចរិតគេគឺអញ្ចឹង! ខ្លួនឯងខ្សោយមិនចេះវាយតប់ ចេះតែព្យាបាលជំងឺ ប៉ុន្តែចូលចិត្តជួយគេណាស់! គេមិនដឹងផ្ទៃក្នុងលេខាប៉េងទេតែគេដឹងថាជំនួយការរិទ្ធិជា អ្នកប្រុសដែលត្រូវគេចាប់ទៅ ដូច្នេះគេកើតចិត្តចង់ជួយ!»
«មនុស្សល្អដែរតើ!....អញ្ចឹងសោះបានបងខ្ញុំយកទៅពិចារណា??»
អមរាទម្លាក់ទឹកមុខស្ងួត៖
«រឿងដែលសំខាន់ គឺជំទាវម៉ាក់!»
សក្ខណាក៏ទម្លាក់ទឹកមុខដូចគ្នា។ នាងនឹកដល់ម្តាយក៏ចេះពិបាកចិត្តតាមបងស្រី។ នាងរេភ្នែកទៅរកបុរសទាំងពីរឃើញពួកគេកំពុងកៀកកគ្នាជជែកដោយ រីករាយ នាងគិតម្នាក់ឯង

ស្ងាត់ៗក្នុងចិត្តៈ
«អ្វីៗហាក់ដូចបានស្រលះអស់ហើយ! នៅតែរឿងមួយ គឺរឿងជំទាវម៉ាក!»

## ជំពូក២៤

អំណោយសម្រាប់ ជំទាវកុសុមា

«បងចំណាស់ណេះហើយនៅស្រើបស្រាលរឿងរកស៊ីអីទៀត? ខ្លួនទើបក្រោកពីឈឺ បងមិនត្រូវទៅព្រៃភ្នំក្រំថ្មឲ្យពិបាកធ្វើអី?»
ជំទាវកុសុមានិយាយផងជួយរៀបចំសម្ភារៈអតីតស្វាមីនឹងអាលចេញពីពេទ្យផង។ ឧកញ៉ា ប៉ែន ពេជ្រពោលវិញត្រួសៗ ។
«គម្រោងការនោះ ជាញើសឈាមរបស់បងរាជ!! បងត្រូវការមើលវាដោយផ្ទាល់ភ្នែកហើយ ជ្រោមជ្រែងក្មេងៗឲ្យពេញដៃ!»
ជំទាវរអ៊ូតិចៗៈ
«ចុះម៉េចក៏បងមិនព្រមឲ្យទៅកូនប្រាថ្នាធ្វើ? ក្មេងប្រុសនោះជាកូនអ្នកក្រៅ....»
«វាក៏ជាកូនប្រុសរបស់អាស៊ីវ....»គាត់និយាយកាត់អតីតភរិយាព្រោះថា ស្គាល់នាងជាច្រើនឆ្នាំមកហើយ នាងគ្រាន់តែចាប់ផ្តើមឃ្លាដំបូង គាត់ក៏យល់ចិត្តនាងដឹងថានាងចង់រអ៊ូពីរឿងអ្វីស្រេច។
ជំទាវនៅតែមិនអស់ចិត្ត ទោះបីគាត់មានការគួរសមចំពោះបុរសនេះ ព្រោះគាត់ធ្លាប់ជាភរិយាគេ តែគាត់នៅតែមិនលាក់បាំង អ្វីដែលគាត់គិតទេគាត់និយាយតិចៗៈ
«តែក៏មិនមែនជាកូនបង្កើតដែរ គ្រាន់តែជាកូនចិញ្ចឹម!»
«ចិញ្ចឹមក៏ជាកូន បង្កើតក៏ជាកូន! បើយើងមិនទុកគេជាកូនបង្កើត យើងក៏មិនបាច់យកគេមកចិញ្ចឹមដែរ! នេះជាចំណុចល្អរបស់អាស៊ីវ ទីបំផុតវាបានផលល្អមកវិញ! ក្មេងៗពីរនាក់នោះសុទ្ធតែមានសមត្ថភាព មានកតញ្ញូ តើវាមានអីមិនអស់ចិត្តទៀត!»
ជំទាវនៅស្ងៀមគាត់គិតបន្តិចទើបនិយាយៈ
«ទោះជាយ៉ាងណាក៏ដោយរបស់នោះមិនមែនបងរាជឲ្យមក ហួត ស៊ីវ តែម្នាក់ដែរ!»
«ល្អហើយដែលជំទាវចេះគិតអញ្ចឹង! តាមពិតទៅបងរាជមិនបានឲ្យអ្នកណាទេ ដោយសារតែគាត់ខ្លាចថាគម្រោងនោះបានក្លាយជាគម្រោងរកស៊ីដែល បំផ្លាញកេរមរតកដូនតាបានជាក្រោយមកគាត់បានធ្វើឲ្យវាស្ងាត់វិញ ជាមួយផ្ទាំងក្រវេមក្រវាមប្រាំសន្លឹកហ្នឹង!! គឺគាត់ទុកវា

សម្រាប់អ្នកណាដែលសមនឹងវា! ក្មេងប្រុសនោះ ...ហួត យុត្តនា គេមានភាពបរិសុទ្ធ គ្មានចិត្តលោភ គ្មានជំនក់ចិត្តនឹងការចង់ឈ្នះចង់ចាញ់ ប្រហែលជាគេហ្នឹងហើយ ដែលសមនឹងរបស់នោះបានជាចំណោទរបស់បងរាជគេស្រាយវាចេញ!»

«បើនិយាយពីក្មេងប្រុសនោះ ខ្ញុំរឹតតែមិនពេញចិត្តគេទៀតហើយ!»

ជំទាវចងចិញ្ចើមល្អឹកណានាងនឹកដល់នាយ គឺនឹកដល់កូនស្រីភរិយាក្រោយរបស់អតីតស្វាមីដែលត្រូវខ្លួនប្ដឹងព្យួរសិទ្ធិ។

ប៉ែន ពេជ្រ យល់ប្រការនេះ គាត់បង្ហាញភាពទុក្ខព្រួយក្នុងពន្លឺភ្នែក ។ គាត់ដកដង្ហើមយូរធ្វើឲ្យជំទាវភ្ញាក់ខ្លួនមកវិញ រវើ្ភកលបគិតវែងឆ្ងាយដែរ។

ស្ត្រីនេះមិនមែនឆោតទេ ពេលនេះសកម្មភាពអតីតប្ដីគាត់ធ្វើឲ្យគាត់រអៀសខ្លួនមកវិញខ្លាចតែឧកញ៉ាបានដឹងរឿងនេះដូចគ្នា។

ទោះយ៉ាងណាគាត់គេចនៅតែមិនរួច បានជាត្រចៀកឮសូរសព្ទអតីតស្វាមីលាន់មកតិចៗ៖

«កុសុមា???»

គាត់ងាកមកវិញហាក់ផ្អើលៗ៖

«ចាស៎?»

«អូនទៅដកពាក្យបណ្ដឹងពីពៅបញ្ញាហើយឬនៅ?»

ជំទាវឆ្លើយលឺបលព្រោះខ្មាស៖

«ទូលពិតលឿនណាស់ហ្ន៎? ឪពុកទើបតែជាមិនបានអីផង?»

បុរសដកដង្ហើមធំដោយផ្ដោតភ្នែកលើផ្ទៃមុខស្រស់ប្រផូររបស់នារីឋានៈ ខ្ពស់ ដែលរហូតមកដល់ពេលនេះគ្មានកូនស្រីណាម្នាក់របស់គាត់អាចយកឈ្នះ ដាច់រូបសម្រស់របស់គាត់នៅឡើយ។

ប៉ែន ពេជ្រ លូកដៃទៅចាប់ប្រអប់ដៃរបស់ជំទាវដែលរាវស្ដួចដូចបន្លាក្រូច។ គាត់នឹកដល់រយៈពេលមួយពីអតីតកាលដែលនារីក្នុងទីស្រមៃនៃបុរសជា ច្រើនម្នាក់នេះបានឱនមកលាងជើងទទួលគាត់ចូលរោងជ័យដោយសារការ បង្ខំពីឪពុកម្ដាយនាង។ ក៏នារីម្នាក់នេះដែលបានរស់នៅជិតគាត់ប្រកបដោយការគោរពនិង ប្រតិបត្តិជាកុលស្ត្រីពេញលក្ខណៈនៃត្រកូលអភិជនគ្មានដែលធ្វើអ្វីមួយឲ្យស្វាមីទើសចិត្តតែប្រការដែលសំខាន់នោះ គឺរយៈពេលជាច្រើនឆ្នាំមកនេះ គ្មានពេលណាមួយដែលបេះដូងនាងនៅចាំអាពាហ៍ពិពាហ៍មួយនេះឡើយ ។

មាត់នាងញញឹមដាក់ប្តី តែចិត្តនាងនឹកដល់បុរសចិនម្នាក់នោះជានិច្ច ព្រោះកូនប្រុសស្រីពីរនាក់ដែលនាងឱបត្រកងគឺជាសំណល់អនុស្សាវរីយ របស់ពួកគេ។
បុរសចិនដ៏ស្រស់សង្ហាមានសមត្ថភាពនិងមិនដែលសូម្បីតែយកភ្នែក មើលនារីណាផ្សេងដោយសារតែស្នេហាទីមួយរបស់គាត់បានប៉ះចំស្រ្តី លើស្រ្តីទៅហើយ។
«ឈប់ធ្វើបាបខ្លួនឯងទៅកុសុមា!»
គាត់និយាយតិចៗតែបេះដូងហាក់ឈឺ។ ទោះបីការឈឺចាប់នោះវាធ្លាប់អស់ហើយគាត់ដល់វេនដែលអាចថាស៊ាំនឹង វាបានតែមិនដឹងហេតុអ្វីបានជានិយាយដល់រឿងនេះចិត្តគាត់នៅតែជៀសឈឺមិនរួច។ឈឺទីមួយគឺអាណិតមិត្តសម្លាញ់ដែលអភព្វពេញមួយជីវិត ដោយសារស្នេហានេះ ទីពីរគឺអាណិតស្រីម្នាក់ដែលខុសពីស្រ្តីឯទៀត កំពុងនៅចំពោះមុខខ្លួន។
«នាងឃើញហើយ! អាស៊ីវវាយ៉ាងម៉េចខ្លះ!?»
«រឿងពួកម៉ាកបងឯងជារឿងរបស់ពួកបងឯង យកមកនិយាយធ្វើអី!?»ស្រ្តីនិយាយគេចវេះពីបញ្ហា។
តែដៃ ប៉ែន ពេជ្រ ចាប់ម្រាមដៃស្រ្តីម្នាក់នេះថ្នមៗ ជាស្រីម្នាក់ដែលចិត្តគាត់គ្មានទេសេចក្តីស្នេហាគឺមានតែការគោរព និងយល់ចិត្តនាងថាជាមិត្តដ៏ល្អម្នាក់។ ឧកញ៉ាវាចាបន្ថែម៖
«បើមនុស្សពីរនាក់ស្រលាញ់គ្នាតែត្រូវបែរខ្នងដាក់គ្នា ហើយឈឺចាប់ម្ល៉ឹងៗ ហេតុអ្វីនាងមិនព្រមរើបម្រះខ្លះកុសុមា? ព្រោះតែអ្វី? នាងព្រោះតែខ្លាចអ្នកដទៃថា ខ្លាចកូនៗនាងថាឬខ្លាចអ្វី? តាមពិតនាងខ្លួនឯង ដែលធ្វើបានខ្លួនឯង»
«បងឯងក្រោកពីឈឺមកនិយាយវង្វេងវង្វាន់អី?»
នាងដកដៃចេញទាំងមុខក្រហមដូចភ្លើង។
ស្រីស្អាតដែលនៅចំពោះមុខគឺជាស្រីម្នាក់ដែល ប៉ែន ពេជ្រ បានបោះបង់ចោលការគ្រប់គ្រងនាងជាយូរមកហើយ ព្រោះគាត់យល់ថាធ្វើយ៉ាងនេះនាងនឹងអាចវិលទៅជួប ហួត ស៊ីវ វិញ ប៉ុន្តែគាត់បានគិតខុស។

នាងមិនត្រឹមតែមានអស្មិមានះស្រលាញ់កិត្តិយសជាងស្នេហា នាងថែមទាំងចម្លែកខុសគេព្រោះថាកាន់តែឯកាកាន់តែមានចរិត គ្មានមនោសញ្ចេតនាទៅទៀត។ គាត់ដឹងថានាងនៅគោរពគាត់ នៅតែល្អនឹងគាត់ វាមិនមែនជាស្នេហាឡើយ តែវាជាការទទួលខុសត្រូវរបស់នាងជាស្រ្តីជាន់ខ្ពស់ដែលយល់ថាខ្លួន បានធ្វើខុសប្រទ្បាក់ប្រឡូសនឹងបុរសផ្សេងហើយមករៀប

ការនឹងគាត់ក៏ គាត់នៅតែរក្សាឈ្មោះឲ្យនាងរហូតមកដែរ។ ពេលនេះទៀតសម្ដីគាត់ក៏រឹតតែធ្វើឲ្យជំទាវសង្ស័យថាសូម្បីក្មេង ប្រុសស្រីពីរនាក់នោះមិនមែនជាសាច់ឈាមគាត់ក៏គាត់ដឹង។

«មុនពេលបងចេញទៅរតនគិរី មិនដឹងថាមានពេលមកអង្គុយនិយាយគ្នា ស្រួលៗល្អៗដូចពេលនេះទៀតឬក៏អត់ អញ្ចឹងហើយថ្ងៃនេះមានរឿងសំខាន់ពីរដែលបងចង់និយាយឲ្យហើយ!»

ជំទាវកុសុមាលើកដៃជូតទឹកភ្នែក។ នាងដឹងថាបុរសនេះគឺជាបងប្រុសល្អម្នាក់ដែលមួយកំណាត់ជីវិតមក ហើយ គ្មានអ្នកណាដឹងទេថា គាត់លែងលះនាងព្រោះចង់ឲ្យនាងវិលទៅរកសង្សារចាស់គេបែរជាយល់ថា គាត់មានភរិយាក្រោយក្បត់ចិត្ត ។

«និយាយទៅ! ទោះអ្វីក៏ដោយ! ខ្ញុំធ្វើបានដើម្បីលោកទាំងអស់ ឧកញ៉ា ប៉ែន ពេជ្រ! បើជារឿងដកបណ្ដឹងជាមួយក្មេងនោះ លោកឈប់ព្រួយទៅ កូនប្រាថ្នាមកវិញហើយ គេបានទៅធ្វើហើយ កូនៗត្រូវគ្នាអស់ហើយ លោកមិនបាច់ខ្វល់ទេ! តែខ្ញុំចង់បញ្ជាក់ប្រាប់លោករឿងមួយឲ្យច្បាស់ខ្ញុំតែងតែមិន ត្រូវជាមួយក្មេងស្រីនោះក៏មិនមែនដោយសារវាជាកូនប្រពន្ធក្រោយរបស់លោក ហើយខ្ញុំគុំខឹងស្អប់ទេ ប៉ុន្តែខ្ញុំគ្រាន់តែមិនចូលចិត្តក្មេងស្រីដែលមានទំនាក់ទំនងជាមួយ ប្រុសកំលោះគ្មានពូជត្រកូល។ ឪពុកឈឺមិនគិតខ្វល់ខ្វាយ គិតពីសប្បាយនឹងស្នេហា! លោកឃើញហើយ ជីវិតខ្ញុំខ្ទេចខ្ទីដល់ឥឡូវដោយសារតែរឿងអស់នោះ ដូច្នេះខ្ញុំមិនចង់ឲ្យ ពួកក្មេងៗ ជាន់ដាននេះតទៅទៀត! ខ្ញុំចិត្តចង្អៀតយកតែចិត្តខ្លួនឯង ខ្ញុំដឹង ប៉ុន្តែអនាគតនៃមនុស្សស្រីម្នាក់បើបានជាខុសហើយគឺខុសមួយជីវិត វាមិនអាចថយក្រោយបានទេ! លោកគួរប្រាប់កូនស្រីលោកឲ្យគិតសាជាថ្មីមិនត្រឹមតែជារឿងពូជ ត្រកូល ប៉ុន្តែចរិតលក្ខណៈគឺរឹតតែមិនអាចទៅរួចទៅហើយ រវាងប្រុសកំលោះគ្មានការសិក្សាគ្មានសញ្ញាប័ត្រម្នាក់ជាមួយមេធាវីមកពីគ្រួសារ ប៉ែន ពេជ្រ ! លោកជាឪពុកម្នាក់ត្រូវតែធ្វើអ្វីមួយដើម្បីរារាំងពួកគេ ទោះធ្វើឲ្យពួកគេស្អប់នៅថ្ងៃនេះក៏មិនអីដែរតែមិនត្រូវ ឲ្យ.....»

«នាងឈប់ទៅកុសុមា! ឈប់គិតអ្វីៗដែលធ្វើឲ្យខ្លួនឯងពិបាកដកដង្ហើមទៅកុសុមា! នាងហត់ទេ?ហេតុអ្វី? ហេតុអ្វីមនុស្សចាំបាច់បែងចែក ចាំបាច់ប្រកាន់គ្នា? បើមនុស្សពីរនាក់រស់នៅជាមួយគ្នាបានសុខហេតុអ្វីមិនអបអរសាទរគេ ទៅ? នាងនៅនឹកឃើញទេ បើកាលពី៣០ឆ្នាំមុន បើចាស់ទុំយើងមិនបង្ខំយើង នាងនិងអាស៊ីវរស់នៅជាមួយគ្នាបានសុខសប្បាយយ៉ាងណា?»

«ខ្ញុំមិនមែនមិនចង់ទេ តែយើងរស់នៅក្នុងសង្គមមនុស្សជាច្រើនចាំមើលយើង! ខ្ញុំមិនអាច....»
«នេះហើយជាគំនិតដ៏ខុសរបស់នាងជំទាវសក្ខកុសុមា! សង្គមស្អីទៅ? មនុស្សជាច្រើនណាទៅ?ម្នាក់ៗត្រូវរវល់ស្វែងរកសេចក្ដីសុខឲ្យជីវិត ខ្លួនឯងនិងមនុស្សដែលយើងស្រលាញ់មែនអត់? មានអ្នកណាទំនេរដល់ម្ល៉ឹងមកតាមដានខ្សែជីវិតនាងដល់ទៅរាប់សិប ឆ្នាំ....??? បើមានមែន..សួរថាតើនាងទៅខ្វល់ធ្វើស្អី? កុសុមាមនុស្សយើងរស់នៅមិនមែនសម្រាប់ឲ្យអ្នកណាមកសរសើរមកថាល្អ ឬអាក្រក់ទេ! អ្វីៗមិនមែនធ្វើដើម្បីឲ្យគេមើលឡើយ ព្រោះយើងមិនមែនទំនិញតាំងពិព័រណ៍! ជីវិតមនុស្សខ្លីណាស់! នៅលើសំណង់ Java ខ្ញុំមិនដែលគិតថា ខ្ញុំអាចនៅរស់ចុះមកវិញទេ! ពេលនោះខ្ញុំគិតថា បើខ្ញុំនៅសល់តែមួយដង្ហើម ក៏ខ្ញុំត្រូវធ្វើអ្វីម្យ៉ាងដើម្បីខ្លួនខ្ញុំនិងពួកម៉ាកខ្ញុំ! នាងដូចគ្នា នាងសល់ពេលច្រើន នាងគិតពីមនុស្សអស់នោះច្រើនជ្រុលហើយ គួរងាកមកគិតពីខ្លួនឯងម្ដង!.»

ជំទាវចងចិញ្ចើមឈ្ងោកមុខនៅស្ងៀម ប៉ែន ពេជ្រ បន្ត៖
«ទៅនៅក្បែរមនុស្សដែលនាងស្រលាញ់! ថៃទាំគ្នាទៅវិញទៅមកទៅកុសុមា! ហើយ....ទុកសេរីភាពឲ្យក្មេងៗ.....ខេមរិទ្ធិជាក្មេងប្រុសដ៏ល្អ សក្ខណាបានទៅគេ បងអស់ចិត្តហើយ! ចំណែកយុត្តនាក្មេងនោះមានកំណើតណាស់ ហួត ស៊ីវ ក៏ជឿគេ មិនមែនវាចាស់ពេកភ្នែកស្អុយទេ! ពៅបញ្ញាបានទៅគេហើយសប្បាយចិត្ត បងមានតែព្រម!»
«លោកគិតយ៉ាងម៉េចក៏គិតទៅ នាងជាកូនស្រីលោក! តែ....»
«ពៅបញ្ញាក៏ជាកូនស្រីរបស់នាងដែរកុសុមា.....នេះជារឿងទីពីរដែលបងត្រូវនិយាយឲ្យនាងដឹង!»
«បងថាម៉េច?....»
«ជាងម្ភៃឆ្នាំមុន.....នាងសម្រាលជាលើកទីពីរមិនមែនបានកូនស្រីតែ ម្នាក់គឺ ប៉ែន ពេជ្រសក្ខណាទេប៉ុន្តែគឺជាកូនភ្លោះដូចគ្នា! គឺកូនភ្លោះស្រីពីរ! ម្នាក់ត្រូវបានខ្ញុំយកទៅ ហើយម្នាក់ទៀតទុកនៅនឹងនាង!»
«បងកុំមកនិយាយលេងនឹងខ្ញុំ ប៉ែន ពេជ្រ....ខ្ញុំមិនព្រមចាញ់បោកលោកទេ!»ជំទាវនិយាយទាំងក្ដុកក្ដួលចិត្ត។
តែអតីតស្វាមីនិយាយមកបន្ថែម៖
«វាជាការពិតកុសុមា! ជាការពិតដែលខ្ញុំតាមថាត្រូវលាក់នឹងនាងជារៀងរហូត! បំណងរបស់ខ្ញុំ

គឺចង់យកកូនមួយនេះចាកចេញ ទៅរកស្រីម្នាក់ផ្សេងឲ្យធ្វើម្ដាយគេហើយខ្ញុំបំភ្លេចនាងឲ្យនាងបានវិលទៅជុំកូនប្ដីជាមួយអាស៊ីវិញ! ប៉ុន្តែនាងមិនត្រឹមមានសត្វណាទេគឺមានពៅបញ្ញាទៀតប៉ុន្មាននាទី ក្រោយមក! ពេលនោះនាងដឹងខ្លួនមកវិញ នាងរាវប៉ះចំកូនច្បង ខ្ញុំក៏សម្រេចចិត្តដកយកកូនពៅចាកចេញ។ នាងគិតថាខ្លួនឯង ប្រសូតលើកនេះបានកូនតែមួយប៉ុណ្ណោះ ប៉ុន្តែម្ដៃឆ្នាំមកនេះកូនស្រីពៅរបស់នាងបានហៅស្រីផ្សេងថាម៉ែ ហើយគេមិនដែលដឹងពីរឿងអតីតកាលរញ៉េរញ៉ៃអស់នេះទេ! »

ជំទាវអង្គុយស្ងៀមនិយាយស្ដីមិនចេញ តែទឹកភ្នែកគាត់ស្រក់ចុះមកស្ងាត់ស្ងៀមទៅតាមអម្រែកចិត្តដែលគាត់កំពុងតែរែក។

«យើងមែនទេដែលធ្វើបាបកូនខ្លួនឯង?»

ប៉ែន ពេជ្រ ជាអ្នកណា គាត់ស្គាល់យូរហើយ។ មិនបាច់សួរបញ្ជាក់គាត់ក៏ដឹងថាបុរសនេះកំពុងតែនិយាយការពិតចេញ មក។ បុរសនេះបានចាកចេញពីគាត់ព្រោះដឹងថាកូនមុនពីរនាក់ជាសាច់ឈាមហួត  ស៊ីវ មិត្តស្លាប់រស់របស់គេ ក៏ជាបុរសម្នាក់នេះដែរ ដែលបានអត់ទោសនិងទុកកិត្តិយសឲ្យគាត់រហូតមក។

«កូនយើងជាមួយ ហួត ស៊ីវ ក៏ជាកូនភ្លោះហើយជាមួយ ប៉ែន ពេជ្រ ក៏ជាកូនភ្លោះ?»

ជំទាវសួរខ្លួនឯងស្ងាត់ៗទាំងទឹកភ្នែកហូរសោកសង្រេង។ គាត់នឹកដល់គ្រាមួយដែលគាត់បានជួបស្រីតូចសម្បុរស្រអែមនោះ «ម៉ាក់ធំ!....គឺ...» «ខ្ញុំមានកូនស្រីតែពីរប៉ុណ្ណោះ....! ហើយបើខ្ញុំមិនសួរ នាងកុំមកលូកមាត់! ចាស់ទុំផ្ទះនាងគួរចេះប្រដៅប្រដៅកូនដែរមែនទេ?....»

លោកជំទាវនិយាយតិចៗទាំងរអាក់រអួល៖

«បើជ្រុលជាលាក់យូរមកហើយ ម៉េចមិនលាក់រហូតទៅ! ពេលនេះលោកទើបតែមកប្រាប់ខ្ញុំតើប្រាប់ធ្វើអ្វី?»

«ដូច្នេះខ្ញុំប្រាប់នាង ព្រោះខ្ញុំខ្លាចថាថ្ងៃណាមួយ ម្ដាយបង្កើតជ្រុលធ្វើអ្វីមិនគប្បីចំពោះកូនខ្លួនឯង ហើយខ្ញុំត្រូវរ៉ាប់រងកម្មពៀរនេះ!»

លោកជំទាវក្រោកឈររឹងលែងដៃពីបុរសចំណាស់ ហើយបែរមុខទៅរកបង្អួច។ គាត់ទប់ចិត្តបានទើបមិនរត់ចេញក្រៅ។ សំឡេង ប៉ែន ពេជ្រ លាន់មកបន្ថែមពីក្រោយខ្នង៖

«យើងចាស់ៗ បង្ករឿងឲ្យក្មេងៗពិបាកច្រើនមកហើយដែរ! ឥឡូវជាពេលដែលយើងត្រូវធ្វើឲ្យអ្វីៗធូរស្រាលវិញ!»

ជំទាវគ្រវីក្បាលយឺតៗទាំងហួសចិត្តនិងតឹងតែងក្នុងទ្រូង។ ដំបូងគឺគាត់មានកំហុសដែលមានកូនមុនពេលរៀបការ បន្ទាប់មកគឺស្វាមីម្នាក់នេះរើសយកវិធីនេះលែងលះ ឲ្យគាត់ចេញទៅរកសង្សារចាស់វិញ តែមិនបានអញ្ជឹងឯណា ដោយគាត់ជាមនុស្សគិតមុខមាត់ជាងបេះដូង ដូច្នេះអ្វីៗគឺនៅរញ៉េរញ៉ៃរហូតដល់ពេលនេះ។

បុរសចំណាស់ក្រោកដើរត្រុនៗមកក្បែរនាង ធ្វើឲ្យជំទាវបែរក្រោយទៅជួយគ្រាគាត់។ ប៉ែន ពេជ្រ និយាយបន្តៈ

«កុសុមា! កាលខ្ញុំដេកស្ងៀម ខ្ញុំឮពៅបញ្ញានិយាយរឿងជាច្រើនប្រាប់ខ្ញុំ! កូនយើងជាក្មេងស្រីរឹងមាំម្នាក់ តែនាងមានសារជាតិ ត្រង់ហួស មិនស្គាល់ល្បិចកលជ្រៅរាក់អីទេ! រយៈពេលចុងក្រោយនេះគ្នាជួបរឿងស្មុគស្មាញច្រើនណាស់ហើយ! ទីបំផុតគេបានរកឃើញមនុស្សដែលគេស្រលាញ់ហើយអាចធ្វើឲ្យគេ សប្បាយចិត្តនឹងជីវិតរស់នៅ អូនកុំហាមឃាត់គេ! យុត្តិនាជាកូនប្រុសបងយុទ្ធ! ឪពុកបែបណាកូនក៏បែបនោះ! គ្នាឆេវឆាវព្រោះតាំងពីតូចមកត្រូវកំព្រាម្ដាយឪពុក ទោះយ៉ាងណាសារជាតិជាមនុស្សល្អមិនអាចបាត់បង់ទេ! គេត្រូវបាន ហួត ស៊ីវ ស្រលាញ់ថ្នាក់ថ្នមទុកជាអ្នកប្រុសទីមួយ! ឥឡូវគ្រប់គ្រងការងារធំ! គេនិងពៅបញ្ញាជាឆ្នាំងនិងគម្របដែលអាចបង្គ្រប់ឲ្យគ្នាបាន!»

ជំទាវទម្លាក់ភ្នែកសម្លឹងឥដ្ឋ មាត់គាត់និយាយតិចៗៈ

«បងពេជ្រ! បងសន្យានឹងខ្ញុំរឿងមួយ....»

«និយាយមក!»

«មិនបាច់រំលឹករឿងនេះឲ្យនាងដឹងទេ!!»

«ពៅបញ្ញា?»

«ចាំ!»

បុរសនៅស្ងៀម លោកជំទាវនិយាយបន្ថែមៈ

«ខ្ញុំនឹងសងគេ នូវអ្វីដែលបានជំពាក់ក្នុងនាមជាម្ដាយម្នាក់ ប៉ុន្តែក្នុងនាមជាម្ដាយធំបានហើយ! ព្រោះខ្ញុំអៀនខ្មាសណាស់ បើគេដឹងថាម្ដាយបង្កើតរបស់គេធ្លាប់ធ្វើខុសលើគេច្រើនយ៉ាងនេះ....»

ប៉ែន ពេជ្រ ងក់ក្បាលផ្ងក់ៗ គាត់មិនមាត់ តែគាត់ក៏សប្បាយចិត្តវិញ។ វាជាជាប្រការល្អមួយដែលស្ត្រីម្នាក់នេះអាចនឹកឃើញចង់សងទៅកាន់ កូនស្រីរបស់គាត់វិញ ដើម្បីប៉ះប៉ូវនូវកំហុសទាំងអស់របស់គាត់កាលពីមុន។ ឧកញ៉ាក៏រឹតតែសង្ឃឹមដែរថាស្ត្រីម្នាក់នេះ ក៏នឹងនឹកឃើញទៅ

ដល់បុរសម្នាក់ទៀតដែលបានធ្វើល្អដាក់នាងពេញមួយ ជីវិតមកហើយ។
«ហួត ស៊ីវ មិនដឹងពេលណាដើរបានឬមួយត្រូវអង្គុយលើរទេះមួយជាតិនេះទេ! អូនទៅមើលវាផងទៅ!»
គាត់និយាយតិចៗ តែគាត់មើលឃើញមនោសញ្ចេតនាអាណិតស្រលាញ់ជ្រាលជ្រៅផុតចេញពីពន្លឺ ភ្នែកសក្ខកុសុមា។ ប្រហែលមានតែបុរសម្នាក់នេះប៉ុណ្ណោះដែលយល់ច្បាស់ពីទំហំទុក្ខព្រួយរបស់ជំទាវនេះ។ គាត់ពោលបន្ថែម៖
«កុសុមា! មនុស្សយើង ត្រូវរស់ជាមួយការស្រលាញ់ ហើយត្រូវតែល្អចំពោះខ្លួនឯង មិនអញ្ចឹងហោចណាស់ត្រូវល្អចំពោះមនុស្សដែលគេស្រលាញ់យើង!»

ជំពូក២៥

ចុងបញ្ចប់នៃសមរភូមិស្នេហ៍

វាជាពេលវេលាដ៏អស្ចារ្យសម្រាប់ការវិលត្រលប់មកក្រេបតែក្តៅជុំ គ្នា នៃមិត្តសម្លាញ់ពីររូបដែលមិនធ្លាប់មានបរិយាកាសសន្តិភាពបែបនេះ ជាងម្ភៃឆ្នាំមកហើយ....
....ប៉ែន ពេជ្រ អង្គុយលើកៅអីផ្តៅ សម្លឹងហ្វូងតារាអមព្រះចន្ទ្រា ចំណែក ហួត ស៊ីវ នៅអង្គុយលើរទេះ «រតនសោភ័ណគឺជាគម្រោងការពិត យើងប្រាប់ឯងយូរហើយតែឯងនៅតែភ្លើគិតវាមិនចេញ! បើឯងព្រមយកវាចេញមកតាំងពីដំបូង មិនចាំបាច់ដល់យើងចាស់កោងខ្នងធ្វើអីលែងបានអញ្ចឹងទេ!!!!»
«ដោយសារលើលោកនេះមានមនុស្សលោភដូចឯងអញ្ចឹងច្រើន បានជាបងរាជត្រូវប្រយ័ត្ន! បើម្ភៃឆ្នាំមុនគាត់ឲ្យឯងធ្វើគម្រោងនេះប្រហែលស្រុកខ្មែរត្រូវ អស់ត្បូងពីដីហើយក៏មិនដឹង!»
«ស្តាយណាស់ដែលគាត់មកជឿមនុស្សល្ងង់ដូចឯង មុនស្លាប់ប្រគល់វាឲ្យឯង! ហើយឯងចាស់ញ័រតគាត់ហើយឯងទៅរតនគិរីធ្វើអី? បើថាឲ្យក្មេងៗធ្វើហើយទុកឲ្យគេធ្វើទៅ! ស្លាប់នៅព្រៃវាមិនស្រួលដូចស្លាប់នៅផ្ទះទេវ៉ី!»ហួត ស៊ីវ និយាយឌឺដងឲ្យមិត្តគាត់ដែលអង្គុយញញឹមសម្លឹងមេឃ។
ប៉ែន ពេជ្រ ហាក់មិនរវល់នឹងសម្តីមិត្តគាត់គិតពីញញឹម ហើយឆ្លើយតបពីរឿងផ្សេង៖
«ឯងច្រណែនដែលកូនឯងមិនព្រមឲ្យទៅ អញដឹង! ឯងកំបាក់អញ្ចឹងហើយនៅផ្ទះសោយសុខទៅ! ណាមួយគង់តែមានគេកើតចិត្តអាណិតឃើញឯងអផ្សុក គេមកមើលឯងនាំជជែកលេងមិនខាន!»

«អ្នកណា?»ហួត ស៊ីវ ធ្វើភ្នែកក្រឡឹតក្រឡាប់ដោយសង្ស័យ។ ត្របកភ្នែកតូចស្តើងរបស់គាត់បានបង្ហាញ ប៉ែន ពេជ្រ ស្រេចហើយថាក្នុងវិនាទីដំបូងនៃសំណួរគាត់ គាត់ប្រាកដជានឹកដល់នារីនោះ ដែលគាត់មិនដែលស្រមៃថានឹងអាចបានទទួលភាពផ្អែមល្ហែមរបស់នាងជា លើកទីពីរទៀតឡើយក្នុងជាតិនេះ។

សំឡេង ប៉ែន ពេជ្រ បន្លឺឡើងយឺតៗ៖

«ក្រៅអាថ៌កំបាំងរបស់រតនសោភ័ណ មានរឿងមួយទៀតដែលឯងត្រូវដឹងដែរ! កុសុមាគឺស្រលាញ់ឯង ស្រីនោះស្រលាញ់ឯងតែម្នាក់គត់ក្នុងជីវិតរបស់គេ!»

ហួត ស៊ីវ ងាកមុខចេញមិនឆ្លើយ តែបេះដូងគាត់ឈឺឆៀបនូវជំងឺកណ្តោចកណ្តែងដែលគាត់ឱបជាប់ទ្រូងជា យូរមកហើយ សម្តីមិត្តរបស់គាត់លាន់មកបន្ត ៖

«ឯងត្រូវក្តាប់ឱកាសនេះ ទាក់ទងគេម្តងទៀតទៅ! ក្មេងៗកសាងគ្រួសារអស់ គេក៏កំព្រាឯកាដូចតែឯងអញ្ចឹងដែរ! »

«ស្រីនោះស្រលាញ់កេរ្តិ៍ឈ្មោះកិត្តិយស គ្មានចិត្តឲ្យអ្នកណា គ្មានចិត្តស្រលាញ់អ្នកណាទេ! គេស្លាប់ទៅយកមុខមាត់កេរ្តិ៍ឈ្មោះរបស់គេនោះទៅតាមក្នុងមឈូស អញស៊ីយអស់កន្លះជីវិតហើយដែលស្គាល់គេនោះហើយភ្លេចគេនោះមិនបាន! ប្តីប្រពន្ធឯងហ្នឹងហើយដែលសមនឹងនៅជុំគ្នាវិញ! គេច្បាស់ជាទទួលយកឯងព្រោះឯងជាមុខមាត់របស់គេ!»

ប៉ែន ពេជ្រ ញញឹមតែភាពក្រៀមស្រពោនបញ្ចេញតាមពន្លឺភ្នែកគាត់ដែលសម្លឹងទៅលើមេឃ៖

«កាលពីមុន យើងចេញពីគេព្រោះយើងចង់គេចរឿងនេះ គឺគេចមិនទទួលស្គាល់ថាស្រីម្នាក់ដែលនៅជាមួយយើងតាមពិតចិត្ត គេនៅនឹងពួកម៉ាកយើង! បើគេឱបយើងហើយចិត្តគេនឹកដល់ឯង តើវាឈឺចាប់ដែរទេ! នៅថ្ងៃដែលយើងដាច់ចិត្តលែងលះគេ ជាថ្ងៃដែលយើងព្រមបញ្ចប់ការឈឺចាប់សម្រាប់បីនាក់យើង ហើយក៏បញ្ចប់ការឈឺចាប់របស់យើងខ្លួនឯង តែគេនោះរញ៉េរញ៉ៃ មានះស្រលាញ់មុខមាត់ខ្លាចនេះខ្លាចនោះមិនស្វាង។ ពេលនេះក្មេងៗដឹងរឿងពិតអស់ហើយ វាគ្មានអីទៀតទេនៅតែឯងទេដែលដឹងថាត្រូវធ្វើយ៉ាងណា!»

ហួត ស៊ីវ រឹងមាំយ៉ាងណានៅតែបង្ហាញអាការៈរញីរញ៉ៃដែលធ្វើឲ្យ ប៉ែន ពេជ្រ នឹកអាណិតមិត្តគាត់។ បុរសចំណាស់ដែលនៅពីមុខគាត់តាមថានៅរឹងមាំក្នុងវ័យនេះ តែគាត់បណ្តោយឲ្យគំនុំនឹងការឈឺចាប់ធ្វើបាបពេកបានជាគាត់ទៅជា យ៉ាងនេះ។ សម្តី ហួត ស៊ីវ លាន់មកកាត់ផ្តាច់ក្រសែភ្នែកក្រៀមក្រំរបស់ ប៉ែន ពេជ្រ៖

«មិនបាច់ទេ! ឲ្យគេរស់នៅសប្បាយចិត្តតាមរបៀបរបស់គេទៅ!»

គាត់ធ្វើជាលើកកែវតែមកក្រេបដើម្បីលាក់កំបាំងពីការទាមទាររបស់ បេះដូង។ ប៉ែន ពេជ្រ បន្ថែមយឺតៗ មិនរវល់ថាមិត្តគាត់ស្តាប់ឬអត់ទេ គាត់យល់ថាខ្លួនឯងចាំបាច់ត្រូវតែនិយាយ៖

«ស្រីនោះគ្មានផ្លូវសប្បាយចិត្តទេ! គេរស់នៅរបៀបឆ្គួតឡប់នេះយូរមកហើយ គឺរស់នៅបំភ្លេចខ្លួនគេចោល! ឯងត្រូវតែជួយគេ ឲ្យគេចេញពីពិភពលោកក្លែងក្លាយអស់ហ្នឹង! ឯងរឹងមាំឡើងអាស៊ីវ! គេត្រូវការឯងហើយឯងជាមនុស្សប្រុសឯងជាអ្នកចាប់ផ្តើមវា! »

ហួត ស៊ីវ នៅស្ងៀមរវេភ្នែកសម្លឹងមុខមិត្តគាត់ដែលញញឹមស្ងួត។ គាត់ដឹងថា ប៉ែន ពេជ្រ ក៏ដូចជាបុរសជាច្រើននាសម័យនោះដែរ គឺបានស្រលាញ់នារីម្នាក់នេះ ប៉ុន្តែស្នេហារបស់នាងដែលក្លែងក្លាយរឹតតែមិនអាចលាក់បាំងបាន កុំថាឡើយដល់ទៅមានកូនពីរនាក់មិនមែនជាកូនរបស់គាត់។ សូម្បីតែរិទ្ធិចូលទៅទីនោះដើម្បីអ្វីគង់តែគាត់ដឹងបាន តើមានអ្វីដែលអាចលាក់បាំងពី ប៉ែន ពេជ្រ បានទៀតទៅ។

ហួត ស៊ីវ អស់ពីរំភើបនឹងមិត្តភាពរបស់គាត់ គាត់ទៅជាស្រែកសើចខ្លាំងៗបន្លប់ការអៀនប្រៀនមាត់និយាយឮៗ ព្រោះអាងថាទីនេះមានតែគាត់ពីរនាក់៖

«ឯងចាស់ឡើងវង្វេងហើយអាពេជ្រ បើឲ្យក្មេងៗឮស្នេហាថ្មី ឯងក្បាលសក់ពីរពណ៌ហើយឯងចេះខ្មាសគេអត់?»

ប៉ែន ពេជ្រ ញញឹមដៀងភ្នែកមើល ហួត ស៊ីវ ដែលខំសើចបន្លប់គាត់និយាយតិចៗ៖

«ឯងចាស់ទៅបាននៅជាមួយស្រីដែលឯងស្រលាញ់ជាសំណាងរបស់ឯងហើយអា ស៊ីវ! ឯងធ្វើរឿងច្រើនណាស់ព្រោះតែខឹងអ្នកដែលការជាមួយនាង ចុះម៉េចលើកនេះមិនធ្វើរឿងខ្លះដើម្បីនាងទៅ!? »

## ភាគបញ្ចប់

.....ធម្មតារដូវផ្ការីកជារដូវដែលធម្មជាតិអំណោយផល ហើយប្រុសស្រីក្មេងចាស់លើផែនដីក៏ទទួលបាននូវបរិយាកាសរស់នៅ អំណោយផលពីអាកាសធាតុនិងសោភ័ណភាពព្រមគ្នា។ ឆ្លងកាត់រឿងរ៉ាវមួយចំនួនធំ បងប្អូនស្រីទាំងបីនៃផ្ទះ ប៉ែន ពេជ្រ ទទួលអារម្មណ៍ថាខ្លួនសមនឹងបានសម្រាកពីការស្មុគស្មាញមកគយគន់ រីករាយក្នុងការកម្សាន្ត នឹងធម្មជាតិ ស្រស់បំព្រងវិញ..ដូច្នេះហើយបានជាថ្ងៃនេះគេឃើញមេធាវីតូច បង្ហាញខ្លួនទាំងព្រលឹមអុរនៅផ្ទះជំទាវសក្ខកុសុមាដែលធ្លាប់តែល្បី ថារបៀបរបបផុតលេខមិនថាតែភ្ញៀវទេសូម្បីកូនៗក្នុងផ្ទះក៏ត្រូវ ត្រង់ភ្លឹងដែរ.....

«ហើយមកពីព្រលឹមម៉េះ?»សក្ខណាខ្សឹបសួរទាំងសម្លឹងទៅកន្ត្រកផ្លែឈើ លើដៃស្រីតូចមេធាវី។ អមរាងាកមកជួយទទួលយក ឯពៅបញ្ញាតបរិញដោយឈ្វោកដោះស្បែកជើង៖
«ជំទាវម៉ាក់ ឲ្យមកញ៉ាំអាហារពេលព្រឹក ម៉េចហ៊ានមកយឺតកើត?»
បងប្អូនស្រីទាំងបីរភ្នែកសម្លឹងគ្នាព្រោះថាតាមធម្មតាស្ត្រីអ្នក របៀបម្នាក់នេះ មិនដែលទាំងមើលមុខពៅបញ្ញាចំផងកុំថាឡើយដល់ទៅខលហៅនាងមកហូប អាហារពេលព្រឹកនោះ។ តើនេះមិនត្រឹមតែជារដូវផ្ការីកពេញផ្ទះជំទាវទេ ថែមទាំងជារដូវជំទាវប្តូរទម្លាប់ទៀត?
អមរាខំសម្រួលបរិយាកាសនៅពេលដែលសក្ខណាធ្វើមុខញញើតញញើម៖
«អ្នកម៉ាក់ ចាំនៅតុបាយហើយតោះៗ!!!! អញ្ជឹងសោះបានជាឮសួរអ្នកម៉ាក់និងមីងៗរវល់តាំងពីព្រឹកព្រហាមស្រាងៗ!»
ពៅបញ្ញាឈានជើងចូលក្នុងផ្ទះបណ្តើរនឹកភ័យអរបណ្តើរចំពោះការ អញ្ជើញតក់ក្រហល់នេះ មួយចំណែកនាងគិតថាគឺស្ត្រីជាម្តាយធំមានបំណងចង់សុំទោសដែល ធ្លាប់បានធ្វើខុសក្នុងការប្តឹងដកសិទ្ធិនាង។ មួយចំណែកទៀតគឺ ស្ត្រីនោះប្រាកដជាហៅគ្រប់គ្នាមកដើម្បីដឹងឮរឿងទទួលយកបុស្បា នារីដើម្បីឲ្យបងប្រុសធំរបស់នាងលែងគិតចាកចេញទៅណា ហើយព្រមរស់នៅកម្ពុជាបន្តទៀត។ទោះរឿងណាមួយក៏ដោយ ពៅបញ្ញា នៅតែមានអារម្មណ៍ថានាងមានសម្ពាធ។

ស្រីតូចដែលក្លាហានមិនដែលព្រមចុះចាញ់អ្វីៗ បានដើរតម្រង់ទៅកាន់បន្ទប់បរិភោគដែលនៅទីនោះស្ត្រីវ័យកណ្តាល ស្រស់ស្អាតដូចដួងចន្ទ្រា កំពុងរៀបចំចាក់ទឹកក្រូចនិងទឹកដោះគោស្រស់ដាក់ជុំវិញតុ។ គាត់ងើបមុខសម្លឹងនាងដោយផ្ទៃមុខស្មើធេងដូចរាល់ដង ដូច្នេះស្រីតូចផ្តុំដៃទៅសំពះសួរតាមទម្លាប់។ ជំទាវសក្ខកុសុមាសំពះតបតែភ្នែកគាត់លបលួចគយគន់នារីសម្បុរស្រអែម តាំងពីក្បាលដល់ចុងជើង វាជាក្រសែភ្នែកនៃម្តាយម្នាក់ដែលមិនធ្លាប់សូម្បីតែបានសម្លឹង កូនខ្លួនដោយមនោសញ្ចេតនា កុំថាឡើយដល់បានបីត្រកងថ្នាក់ថ្នមដោយក្តីស្នេហានោះ។
អមរាហុចកន្ត្រកផ្លែទៅឲ្យអ្នកបម្រើ ដឹងអីត្រូវម្តាយនាងស្មើធេងឃាំងមុន៖
«យើងជាក្មេងទិញផ្លែឈើមកជូនមនុស្សចាស់មិនមែនត្រឹមតែយួរមកហុច ហើយដើរចោលទេ គួរទៅផ្ទះចង្ក្រានចិតសំអាតដាក់ចានដាក់ពានលើកមកត្រឹមត្រូវផង ទើបសមថាមានចិត្តស្មោះ! »

ពៅបញ្ញា នៅទីទើរមើលមុខគ្នា លោកជំទាវនិយាយមកបន្ថែមតាមឫកពាក្រអឺតក្រទមទឹកមុខស្មើធេងរបស់គាត់៖
«ក្មេងៗសម័យនេះអាងតែមានបាវព្រាវប្រើឆ្វេងស្តាំ អាងរៀនបានច្រើនការងារកាន់តែកុំព្យូទ័រ សង្ស័យតែសូម្បីទឹកក៏ មិនចេះចាក់ខ្លួនឯងញ៉ាំផងកុំថាឡើយមកកាន់កាំបិតចិតផ្លែឈើនោះ!»
ទម្លាប់និយាយស្តីឌឺដងស្មើធេងជាទម្លាប់ដែលជំទាវធ្វើឲ្យមនុស្ស ជុំវិញខ្លួនភ័យរាប។ ក្នុងពេលក្មេងស្រីៗកំពុងសម្លឹងគ្នាឡិងឡង់ អ្នកបម្រើម្នាក់ឱនមកខ្សឹប៖
«បើអ្នកនាងពៅធ្វើបាន គួរចិតផ្លែឈើនេះជាស្រេចសឹមលើកមកជូនលោកជំទាវពិសា!»
ពៅបញ្ញា ក្តាប់មាត់ញញឹម៖
«បានតើ! មីងស្មានថាខ្ញុំមិនចេះហ្អី?»
នាងដើរតម្រង់ផ្ទះបាយទាំងមានកន្ត្រកផ្លែឈើទៅជាមួយ ហើយអ្នកបម្រើនោះដើរទៅត្រុកៗតាមពីក្រោយរង់ចាំជួយ។ អមរាស្ទុះទៅឱបម្តាយដែលនៅរៀបចំសេនវិចលើចានតាមរបៀបគាប់ភ្នែក នាងនិយាយចំអន់៖
«ញ៉ាំដាក់ចូលមាត់ដូចគ្នាសោះ ចាំរៀបចុះឡើងច្រើនម៉េះអ្នកម៉ាក់?»
ជំទាវមិនមាត់តែសក្ខណានិយាយបន្ថែមម្តង៖
«មិនដឹងថ្ងៃនេះមានកម្មវិធីអីទេបានជំទាវម៉ាក់ធ្វើសេនវិចផ្ទាល់ ដៃ ហើយលាយទឹកក្រូចស្រស់ពិសេសទៀត?? កូននិងញ៉ាំពីរកែវ!»
ស្នូរឡាននៅខាងក្រៅដែលបោលចូលមកក្នុងបរិវេណភូមិគ្រឹះបានកាត់ផ្តាច់ការជជែកបូរបាច់របស់នារីវ័យក្មេងទាំងពីរ។
«បងប្រាថ្នា?» អមរាភ្លាត់មាត់តិចៗតែភ្នែកនាងផ្តោតទៅលើនារីបង្ហាញម៉ូតដ៏ស្រស់ សោភាដែលឈានចុះមកពីរថយន្តដោយមានបងប្រុសធំរបស់នាងជាអ្នកបើក ទ្វារឲ្យ។
«អ្នកម៉ាក់ឲ្យគាត់នាំបុស្បានារីមក?» សក្ខណាខ្សឹបសួរតិចៗទាំងភ្ញាក់ផ្អើល។ ក្រមុំអភិជនទាំងទ្វេឈានទៅកាន់ទ្វារធំទទួលភ្ញៀវស្រស់ស្អាតដែល គ្រប់គ្រងស្មើរគ្រប់គម្របមុខនៃទស្សនាវដ្តីម៉ូដែលនានា ផ្ទុយអ្វីតែជំទាវកុសុមាដែលគ្មានពេលទៅរវល់នឹងសម្រស់ដូចទេពធីតារបស់នារីសិល្បករនោះទេ គឺបេះដូងគាត់កំពុងហោះទៅចង្ក្រានបាយ។

គាត់ដើរថ្នមៗទៅឈរពីក្រោយមេធាវីតូចដែលកំពុងបែរខ្នងចិត ផ្លែឈើ។ អាកប្បកិរិយានាងគឺយកចិត្តទុកដាក់នឹងការងារនេះ ដោយមិនបានគិតទេថាស្ត្រីម្នាក់ដែលធ្លាប់តែស្អប់ខ្ពើមនិង

ជិនឆ្អន់នាងបានមកឈរពីក្រោយហើយលួចសម្លឹងរាងកាយនាងពីលើដល់ ក្រោម។
«ក្មេងស្រីនេះឬជាកូនស្រីភ្លោះរបស់យើង?»ជំទាវសួរខ្លួនឯងទាំង សង្វេគចិត្ត។ គាត់នឹកដល់បណ្ដាថ្ងៃជាច្រើនដែលនាងត្រូវរស់នៅក្នុងសភាពកំព្រា ម្ដាយហើយឪពុកគេងពេទ្យមិនលោះថ្ងៃ។ ចំណែកការងារជាច្រើនបានធ្លាក់មកលើស្មាដ៏តូចទាបរបស់នាង។
រាងនាងតូចច្រឡឹងមើលពីខាងណាក៏មានលក្ខណៈស្រដៀងនឹងសក្ខណាឥត ខ្ចោះ ខុសត្រង់តែសម្បុរស្បែកដែលមានលក្ខណៈស្រអែមជាង។
«យើងមានសំណាងមានកូនស្រីដល់ទៅបីនាក់! កូនស្រីពៅយើង ជាមេធាវីល្បីឈ្មោះ ហើយជាក្មេងស្រីរឹងមាំម្ល៉ឹងៗ យើងគួរសប្បាយចិត្តយូរហើយ!»
ជំទាវកុសុមាគិតផងលូកដៃទៅអង្អែលកេសារលើបរលោងរបស់មេធាវីតូចដោយ ព្រហ្មវិហារនិងក្ដីស្នេហាយ៉ាងជ្រៅ។ គាត់ធ្វើវាដោយមិនដឹងខ្លួនគឺជាចេតនារម្មណ៍ដែលម្ដាយទូទៅមានលើ កូនៗរបស់គាត់តែគាត់ភ្លេចគិតថាកាយវិការនេះបានធ្វើឲ្យពៅបញ្ញា ភាន់ភាំង។
នាងបញ្ឈប់ការចិតផ្លែឈើហើយរវើរក្នែកគិតទាំងភ័យផងស្ងន់ស្លោផង។
កាយវិការស្ត្រីត្រកូលខ្ពស់នៅសុខៗប្រែមកជាប្លែកថ្នាក់នេះ តើនាងមិនឆ្ងល់ម៉េចនឹងកើត?។
នាងបែរក្រោយសន្សឹមៗរកសួរអ្វីតែនារីបែរជាត្រូវនៅទ្រឹងចំពោះ កែវភ្នែករលើបរលោងរបស់ស្ត្រីដ៏ឆ្មើងឆ្មៃដែលពេលនេះសម្លឹងមកនាងដោយ ទុក្ខសោក។
ឃើញនាងបែរមកចំហើយសម្លឹងតបវិញក្ដី ក៏គាត់នៅតែគ្មានកម្លាំងអ្វីនឹងដកដៃចេញឡើយ ។បបូរមាត់គាត់និយាយរួចតែពីរបីម៉ាត់គត់៖
«កូនម្ដាយ!»
ប្រហែលជាពាក្យនេះ នាងខានបានឮជាយូរមកហើយ ហើយក៏ប្រហែលជាពាក្យនេះជាពាក្យដែលនាងយល់សប្ដិក៏មិននឹកស្មានថា បានឮចេញពីមាត់ស្ត្រីអ្នកមានស្ដុកតែឫកខ្ពស់ហួសមេឃម្នាក់នេះ ដែរ បានជាពៅបញ្ញានៅភ្លឹកភ្លាំង។
«ម៉ាក់សុំទោស! ឲ្យម៉ាក់សុំទោស!»
គាត់និយាយបានតែប៉ុណ្ណោះក៏ទ្រហោយំហើយឱនមកឱបរាងកាយស្រីតូចទៅ ក្នុងរង្វង់ដៃធ្វើឲ្យមេធាវីងើងើគិតអ្វីមិនចេញ ផែនដីស្រាប់តែក្រឡាប់ចាក់។ ហេតុអ្វីពេលនេះអ្វីៗក្លាយជាល្អអីក៏ល្អដល់ម្ល៉ឹង? តើឲ្យមនុស្សលោកធម្មតាម្នាក់បន្សាំខ្លួនទទួលយកការប្រែប្រួលយ៉ាង ប្រចុចញ៉ុចនេះបានដោយគ្មានបញ្ហាដែរទេ? នាងនៅធ្មឹងមិនដឹងធ្វើអ្វីនិងធ្វើយ៉ាងណាតែសោតានៅឮវាចាស្ត្រី រូបស្អាតបណ្ដាច់នោះលាន់មកបន្ថែម៖

«ឆ្លើយនឹងម៉ាក់មក! កូនអត់ទោសឲ្យម៉ាក់បានទេ? ហៅម៉ាក់មកកូន»
ពៅបញ្ញា គិតថាគឺរឿងព្យុះសិទ្ធិមេធាវីនោះហើយ នាងនិយាយទាំងង៉េមង៉ាម៖
«ចាស៎! ម៉ាក់...ម៉ាក់ធំ! គឺ....គឺអត់អីទេ....អ្វីៗចប់អស់ហើយ!»
«កូនអត់ទោសឲ្យម៉ាក់បានទេ?»
គាត់យំសស្រាក់ដូចភ្លៀងធ្វើឲ្យនាងអស់ឆ្ងល់ទៅជាខ្វល់ចិត្ត នារីឆ្លើយតបយ៉ាងរហ័សបញ្ឈប់ទុក្ខសោករបស់គាត់៖
«ចាស៎! គឺ! គឺកូនមិនដែលខឹងម៉ាក់ធំ! មិនខឹងទេ! »
ស្ត្រីញញឹមទាំងទឹកភ្នែក។
«មែនហ្អីកូនម្ដាយ?»
នាងក្រមុំធ្វើភ្នែករលីងរលោងព្រោះឃើញគាត់យំ បន្ទាប់មកនាងកាន់តែល្ងីល្ងើពេលគាត់យំផងសើចផង បន្ទាប់មកគឺពន្លឺភ្នែកគាត់ដែលស្រទន់សម្លឹងមកនាងគ្រប់ សារពាង្គកាយហាក់មើលមិនចេះឆ្អែត។ ពៅបញ្ញានាងមិនដឹងថានេះជាមនោសញ្ចេតនាដ៏ជ្រាលជ្រៅរបស់ម្ដាយម្នាក់ឡើយ ព្រោះនាងគ្មានម្ដាយជាយូរមកហើយ តែទោះយ៉ាងណា ទន្ទឹមនឹងអៀនអន់ដោយចម្លែក ចិត្តនាងរឹតតែទទួលអារម្មណ៍មានសុភមង្គលនិងភាពកក់ក្ដៅដែលបានបាត់ ទៅជាយូរមកហើយ។
«អ្នកម៉ាក់!» សំឡេងសក្ខណាស្រួយស្រែសមកពីមាត់ទ្វារ ធ្វើឲ្យជំទាវលើកដៃលួចជូតទឹកភ្នែកហើយមាត់និយាយបន្លប់៖
«កូននេះ!?? ប្រាប់ប៉ុន្មានដងហើយ? ថាកុំឲ្យនិយាយពញ្ញាក់កុំ ឲ្យនិយាយព្នៗ កុំឲ្យនិយាយកាត់មនុស្សចាស់....»
«អ្នកម៉ាក់ ដុកទ័រនោះ គេនាំប៉ាម៉ាក់គេមកហើយ!»
ជំទាវសម្រួលទឹកមុខ ចំណែកឯពៅបញ្ញាក៏នឹកឃើញភ្លាមដល់ដុកទ័រដែលតាមស្រលាញ់អមរាជាយូរ មកហើយក៏ជាមនុស្សដែលបានជួយយកអាសារិទ្ធិពីក្នុងដៃពួកពាល។ មេធាវីដៀងភ្នែកសម្លឹងម្ដាយធំហើយងាកទៅលើកចិញ្ចើមស៊ីញ៉ូសក្ខណា ជាសញ្ញាសួរថាហេតុអ្វីថ្ងៃនេះជំទាវអញ្ជើញភ្ញៀវច្រើនម្ល៉ឹង?
គ្មានចម្លើយសក្ខណាញាក់ស្មាមកវិញជាសញ្ញាថាគ្មានយោបល់ ចំណែកជំទាវនិយាយស្ដីតាមឫកពានឹងនរបស់គាត់៖
«សក្ខណា ម៉ាក់ទៅខាងមុខទទួលភ្ញៀវហើយ ណោះ! យកទឹកមួយកែវនេះទៅស្ងួនច្បារ»

គាត់ចាក់ភេសជ្ជៈមួយកែវហុចឲ្យនាងមានទាំងចានទ្រត្រឹមត្រូវហើយ រុញនាងឲ្យដើរចេញទៅរកសួនច្បារតាមផ្លូវក្រោយទាំងនាងនៅង៉េមង៉ាម ព្រោះមិនយល់។
សំឡេងម្ដាយនោះលាន់មកម៉ាត់ៗតែស្រាលៗ៖
«បំណងចុងក្រោយរបស់ប៉ានិងម៉ាក់ធំ គឺចង់ឲ្យកូនៗបានរៀបការជាមួយអ្នកខ្ពង់ខ្ពស់ណាម្នាក់!ពិសេសប៉ា កូន គឺមុនពេលគាត់ចេញទៅរតនគិរីធ្វើគម្រោងការរតនៈសោភ័ណ»
ពៅបញ្ញាភ័យបុកបោះព្រោះ ភ្លាមនោះនាងនឹកដល់យុត្តនា។

តាំងពីដំបូងមកនាងដឹងថាស្នេហានាងនិងបុរសនោះគឺពិបាកបន្តិច ដោយសារគេជាអ្នករៀនបានតិចជាងនាងស្រាប់ ឯជំទាវម្នាក់នេះទៀតសោតគឺមិនពេញចិត្តនាយតាំងពីដើមមក។ កុំថាឡើយនាយសម្ដីយ៉ាប់អាកប្បកិរិយាមិនដឹងក្បួនទម្លាប់ ទោះបីសុភាពបុរសមកពីគ្រួសារអភិជនល្មមៗក៏មិនសមថាស្ត្រីម្នាក់ នេះមើលទៅពេញភ្នែកដែរ។ ថ្ងៃនេះគាត់មកល្អនឹងនាងហៅនាងមកទាំងពីព្រលឹមហើយយំស្រក់ ទឹកភ្នែកមិនធ្លាប់មាននេះព្រោះតែគាត់ត្រូវការលើកនាងឲ្យទៅអ្នក មានណាម្នាក់មែនឬយ៉ាងណា?។
នាងភ័យហើយពិបាកចិត្ត។ មិនទាន់មានឱកាសឆ្លើយថាយ៉ាងណាផងស្រាប់តែគាត់វាចាបន្ថែមទៀតទៅហើយ៖
«សក្ខណា គេនោះមកដល់ហើយ! នៅចាំនៅក្នុងសួនទៅគួរសមជាមួយគេបន្តិចទៅ កុំឲ្យបាក់មុខម្ដាយ!»
នារីនិស្សិតរវេភ្នែកចុះឡើងទាំងបារម្ភ។ ចំណែកពៅបញ្ញាក៏ក្ដុកក្ដាក់ក្នុងចិត្តជំនួសសក្ខណាដែរ។ តើគេនោះជាអ្នកណាបានជាស្ត្រីនេះយល់មុខគេដល់ម្លឹង?
មេធាវីតូចច្រឡឹងគិតបណ្ដើរ ចិត្តធ្ងន់ពាប់ដោយវិបត្តិបណ្ដើរ។ នាងសួរខ្លួនឯង៖
«គាត់ប្រាកដជាមិនទទួលយកបងរិទ្ធិបានជាប្រញាប់រកប្ដីឲ្យសក្ខណាយ៉ាងនេះ?»
មេធាវីរវេភ្នែកទៅរកបងស្រីតូច ដែលកន្លងមកមានចរិតលក្ខណៈត្រូវគ្នាមិនទាស់ជាមួយនាងទាំងនាងមិន ដឹងទេថានាងក៏ជាគូកូនភ្លោះរបស់ស្ត្រីនេះ។
«គេជាអ្នកណា? ម៉ាក់ឲ្យកូនទៅធ្វើអី? ចុះអ្នកបម្រើ...»
«ធ្វើតាមម៉ាក់ទៅ! បើមិនចង់ឲ្យម៉ាក់ខឹងនៅថ្ងៃនេះ...»
ថាចប់ស្ត្រីអភិជនដើរចេញវឹងទុកឲ្យសក្ខណាឈរទ្រើងសម្លឹងកែវភេសជ្ជៈស្ទើរយំស្ទើរពេបម្នាក់ឯង។

ពៅបញ្ញាឃើញម្ដាយធំនាងចេញផុតក៏សសៀរមកក្បែរសក្ខណា៖
«មានរឿងអី? គាត់ដូចចង់លើកឯងឲ្យអ្នកណាម្នាក់!? ចុះបងរិទ្ធិ??»
«គាត់ស្មានថាអាចបង្ខំខ្ញុំបាន?» សក្ខណារអ៊ូ។
«ចុះទឹកនេះ?» ពៅបញ្ញាសួរ។
«ឯងយកទៅស្លួនច្បារទៅ!!! បានអត់?»
«ទេ! រឿងផ្សេងជួយបានរឿងនេះជួយមិនបានទេសក្ខណា!!»
សក្ខណាធ្វើមុខស្អុយ៖
«គ្មានអីស្អុគទាំងអស់ៗ!!! ចាក់វាចោលជាការស្រេច!»
ពៅបញ្ញាលួងលោម៖
«ទៅមើលបន្ដិចសិនក៏មិនជាអីដែរមែនអត់? គេនោះជាអ្នកណាម៉េចក៏ម៉ាក់ធំពេញចិត្តម៉េះ? បណ្ដោយឲ្យកូនស្រីសំណព្វទៅជួបគេពីរនាក់ស្ងាត់ៗក្នុងសួននៅ ពេលអ្នកផងគេជុំគ្នានៅបន្ទប់ធំ???
សក្ខណាក្ដាប់មាត់៖
«បានតើ! ទៅមើលក៏បាន សំខាន់យើងមិនខ្វល់នឹងគេទៅ គឺចប់ទៅហើយ!»
ស្រីតូចសក្ខណាដើរទើមៗចេញទៅព្រោះមិនចង់ខុសនឹងសម្ដីម្ដាយ ឯចិត្តនឹកតែទៅដល់ទេវបុត្តល្អទាំងព្រមរបស់នាង។
«លោកនៅឯណា! ដឹងអត់ថាខ្ញុំកំពុងត្រូវគេធ្វើបាប?» នាងគិតទាំងបញ្ចេញភាពងរង៉ក់ពេញផ្ទៃមុខ។នាងស្រមៃសូម្បីតែសម្ដី របស់គេ«ចង់បាន Password ម៉េចមិនប្រាប់? គេបំពេញកាតព្វកិច្ចជាប្ដីឲ្យប្រពន្ធ បានតើ! តែយើងត្រូវធ្វើជាប្រពន្ធល្អមុនសិន!» «ខ្ញុំមិនមែនជាប្រពន្ធលោកទេ!»
នារីអភិជនគិតក្នុងចិត្តទាំងលន្លង់លន្លោច៖
«ទើបតែដឹងថា ចិត្តយើងបានរៀបការជាមួយគេស្រេចទៅហើយ! ជាតិនេះតើឲ្យយើងភ្លេចគេរបៀបម៉េចទៅ បើឲ្យតែមនុស្សប្រុសផ្សេងបង្ហាញខ្លួនយើងនឹកដល់គេស្ទើររលួយ បេះដូងទៅហើយ???»
ចំណែកពៅបញ្ញាតាមសម្លឹងដំណើរសក្ខណាពីក្រោយទាំងពិបាកចិត្តជួសនាង៖
«តើម្នាក់នោះជាអ្នកណា បើគេបានជំទាវម៉ាក់នេះពេញចិត្តគេប្រាកដជាមហាសុភាពបុរសមានទាំង ទ្រព្យធនទាំងប្រវត្តិសិក្សានិងយសស័ក្តិសង្គមហើយមើលទៅ?»

ជាមួយទឹកមុខក្រៀមស្រពោនសក្ខណាដើរបណ្ដើរបួញមាត់ពិបាកចិត្តនិង មិនពេញចិត្តចំពោះការងារនេះ តែរំពេចនោះ ត្រចៀកនាងឮសូរសំឡេងអ្នកណាម្នាក់ហើយរសាត់មកតាមខ្យល់៖
«មុខជូរម៉េះ? ទឹកក្រូចនេះរកផ្អែមមិនកើតទេមើលទៅ!»
និស្សិតនារីងាករឹងទៅរកបុរសដែលជាម្ចាស់ប្រយោគហើយសម្លឹងមកនាង ដោយទឹកមុខឡូយឆាយ គេគឺជាបុរសដែលនាងនឹកទាំងយប់ថ្ងៃ តែអ្វីដែលស្រីពិបាកចិត្តគឺគេបង្ហាញខ្លួនមិនទំនងពេល។ នាងស្ទុះទៅជិតពោលសួរតិចៗ៖
«ចូលមកបានរបៀបម៉េច?»
«អ្នកយាមបើកទ្វារឲ្យចូលត្រឹមត្រូវណ៎ា»
គេតបទាំងធ្វើមុខងោះមិនដឹងរឿង តែស្រីតូចឯណោះពិបាកចិត្តសឹងប្រេះទ្រូង។ នាងដឹងថានៅក្នុងសួននេះក្រៅពីនាងនិងគេ គឺនៅមានបុរសម្នាក់ទៀតដែលម្ដាយនាងប្រាប់ថាគេបានចូលមកស្ដី ដណ្ដឹងនាង ។ បើឲ្យគេឃើញនាងនៅជាមួយប្រុសកំលោះផ្សេង តើម្ដាយនាងនឹងខូចឈ្មោះយ៉ាងណាទៅ។
«ហួត ខេមរិទ្ធិ! ផ្ទះខ្ញុំមានភ្ញៀវ លោកកុំឲ្យគេឃើញថាមានប្រុសៗលួចចូលមកសេរីអញ្ចឹងបានអត់?!»
បុរសក្ដាប់មាត់ញញឹមសម្លឹងផ្ទៃមុខស្លេីតស្លក់របស់នាងតូចគេជាប់ ចិត្តនឹងផែនថ្ពាល់ក្រហមរលោងដែលឃើញកាលណាចង់តែហាមាត់ខាំត្របាក់ លេបឲ្យបាត់កុំឲ្យបុរសផ្សេងឃើញ តែទីនេះគឺសួនច្បារ ហើយខាងស្រីហាក់មានភាពមិនស្រណុកកាយសប្បាយចិត្តផងគេក៏មិនហ៊ាន លូកលាន់នាង មានតែកញ្ឆក់ទឹកពីដៃនាងមកក្រេបមួយដង្ហើមអស់រលីងធ្វើឲ្យនាង តូចឈរឆ្ងឹងសម្លឹងគេដោយហួសចិត្ត។
គេក្រេបអស់ក៏ងាកមកញញឹមដាក់នាង៖
«ផ្អែមតើ! ស្មានតែជូរដូចមុខអ្នកលើកមក!»
អស់ពីហួសចិត្ត នាងទៅជាអស់សំណើចវិញ៖
«ដាច់ដាបម៉េះ?»
នាងដើរចោលគេបកក្រោយទៅបម្រុងចាក់មកមួយកែវថ្មី ដឹងអីគេស្ទុះមកតាមហើយដៃម្ខាងលូកក្រសោបចង្កេះនាង។ ស្រីតូចរលាស់ចេញដោយភ្ញាក់ព្រោះភ័យខ្លាចមនុស្សពីរនាក់ឃើញទី មួយគឺអ្នកម្ដាយដ៏តឹងរ៉ឹង ទីពីរគឺបុរសចំណូលថ្មីដែលនាងមិនស្គាល់មុខ ។
«សស្លេីតសស្លក់ម៉េះ?»

«មកពីលោកហ្នឹង! មកមិនត្រូវពេល!»
«ខំមកពីព្រលឹមហើយនៅមិនត្រូវទៀត?»
គេនៅតែតាមមក នាងក៏កាន់តែភ័យខ្លាចថាមានអ្នកផ្សេងតាមមើលដូច្នេះស្រីតូច ក៏ឈប់ជើង ហើយងាកមកអង្វរៈ
«ទៅវិញសិនទៅបានអត់! រវល់!!! សុំអង្វរណ៎ា»
រិទ្ធិញញឹមតែចិត្តគេគ្នាញ់នាងណាស់ ពិសេសទឹកមុខឆ្លេឆ្លារបស់នាងៈ
«ប្រញាប់ទៅជួបអ្នកណា? »
«មានភ្ញៀវច្រើនត្រូវទទួល! ទៅវិញសិនទៅ! ទៅធ្វើការរបស់លោក ទៅជួយបងលោកនៅធនាគារក៏បាន! និយាយរួម ទៅវិញសិនទៅ បានអត់?»
«ថ្ងៃនេះសម្រាក! មានការធ្វើនៅផ្ទះនេះដែរបានជាខំមក!!»
«ធ្វើអ្វីនៅទីនេះដែរ?!»
«មកដណ្តឹងកូនគេ!»
«ថាម៉េច???»
«ជំទាវម៉ាក់នាងឲ្យខ្ញុំមកស្តីដណ្តឹងកូនគេ គឺគាត់ឲ្យខ្ញុំចូលមកពេញមុខ មិនមែនខ្ញុំលួចចូលមកទេ អ្នកនាងធំ! គិតអីក្នុងផ្លូវល្អផងបានអត់អ្នកនាង?»
ស្រីស្អាតវេភ្នែកគិត នាងចាប់ផ្តើមភ័យផងអរផង។ «បុរសនេះមែនអត់? ដែលជំទាវម៉ាក់រំលឹកឲ្យនាងចេញមករកគេអម្បាញ់មិញ? នាងគិតផងវេភ្នែកសម្លឹងគេចុះឡើងៗធ្វើឲ្យគេកាន់តែបាន ចិត្តឈរជ្រែងឲ្យនាងគយគន់តែម្តង។
«លោកនេះហ្អី???»
នាងសួរខ្លី។
«ខ្ញុំយ៉ាងម៉េច?»
«គឺ....លោកនេះអ្វី....ដែល....ដែល....»
«ដែលយ៉ាងម៉េច...?»
«គឺជំទាវម៉ាក់.....គឺ»
«យប់មិញប៉ាខ្ញុំបាននិយាយជាមួយប៉ានាងរឿងសុំដណ្តឹងកូនស្រីពីរ នាក់របស់គាត់តែគាត់ថាការងារនេះផ្ទេរមកឲ្យជំទាវម៉ាក់របស់នាង! ហើយក៏មានគេសន្យាថាបើខ្ញុំមកដណ្តឹងបានពីព្រលឹមប្រហែលអាច ដណ្តឹងបានមុនអ្នកផ្សេងខ្ញុំក៏ដាក់នាឡិការោទ៍ក្រោកមកទៅ!»

អ្នកប្រុសទីពីរនិយាយដោយប្រើក្រសែភ្នែកអណ្តែតអណ្តូងសម្លឹងនាង។
«តស៊ូណាស់ហ្ន៎!»ស្រីស្អាតនិយាយទាំងខាំមាត់។
រិទ្ធិរេភ្នែកមើលនាងតូចដែលក្រពាត់ដៃញញឹមងាកមុខចេញព្រោះអៀន នឹងក្រសែភ្នែកនាយ។ គេដឹងថាបេះដូងស្រីតូចគឺមានគេ១០០ភាគរយទៅហើយ។ អ្នកប្រុសដើរមកកាន់តែកៀក ហើយឈ្ងោកមករកនិយាយអ្វី នាងតូចក៏ត្រៀមស្តាប់ព្រោះនឹកថាគេនឹងនិយាយសម្តីល្អៗឲ្យនាង សប្បាយចិត្ត ដឹងអីស្រាប់តែគេសួរបញ្ឆឺះ
«ញញឹមហ្នឹងច្រឡំថា គេមកដណ្តឹងខ្លួនហើយហ្នឹងមើលទៅ!?»
នាងងាកមកវិញសម្លក់នាយហើយប៉ះបបូរមាត់នាយដែលញញឹមសឹងថាគ្រីតខាំនាង នាងក្តាប់មាត់ដាក់វិញ៖
«ជំទាវម៉ាកខ្ញុំក៏មិនលើកកូនឲ្យមនុស្សដូចលោកដែរ! ចូលមកតាមណាបង្អួចណា ចេញទៅវិញតាមនោះខ្លួនឯងទៅ!»
នាងចងចិញ្ចើមហើយដើរចេញទាំងទោមនស្សដែលក្នុងវិនាទីនេះគួរតែធ្វើ ឲ្យនាងសប្បាយចិត្ត ដឹងអីថាគេនៅឆ្លៀតធ្វើឲ្យនាងសៅហ្មងទាល់តែបាន។ នាងដើរបណ្តើរប្រាប់ខ្លួនឯងបណ្តើរថាបើមានឱកាសនាងនឹងធ្វើបាប ចិត្តប្រុសម្នាក់នេះវិញឲ្យបានគ្រប់ចំនួនដែលគេធ្វើមកលើនាង។ សំឡេងបុរសសង្ហាលាន់មកពីក្រោយខ្នងស្រាលៗ៖
«ហើយចុះបើគាត់លើក ហើយខាងប្រុសគេមិនចង់បានវិញ?»
ស្រីតូចតាមថាមិនចង់ខ្វល់នឹងបុរសនេះទៀតទេ ព្រោះគេលេងជ្រុលៗពេកសឹងថានាងចង់ឈប់ស្រលាញ់គេវិញភ្លាមៗតែ សម្តីចុងក្រោយនេះធ្វើឲ្យនាងទប់ចិត្តមិនបានរត់បែរក្រោយមក ក្តិចខ្វាំនាយដែលឈរសើច ទុកឲ្យនាងប្រលែងលើរាងកាយតាមចិត្តហាក់មិនចេះឈឺនិងមិនចេះ ចុះញ៉ម។
នារីក្តិចខ្វាំគេអស់ចិត្តហត់ខ្លួនឯងក៏គំហកតិចៗ៖
«អត់ចេះឈឺទេអ្វី!? មនុស្សយន្ត មនុស្សដែក!»
នាងច្រាននាយចេញហើយតាំងចិត្តថាដើរចោលគេលែងងាកក្រោយ តែនរៈយើងចាប់ដៃនាងជាប់។កម្លាំងដៃនាយបីដូចជាស្ថានភាពនាងដែល កំពុងលបមើលគេគេងក្នុងខ្ទមកម្សត់នាព្រៃជ្រៅ ហើយត្រូវគេដឹងខ្លួនមកទាន់ ចាប់ដៃនាងជាប់។
អនុស្សាវរីយ៍រំលឹកមកវិញធ្វើឲ្យបេះដូងភ្ញាក់ភ្ញាញ់ទៅជារំភើបព្រមគ្នាជាមួយក្រសែភ្នែកដែលសម្លឹងមុខនាយភ្លឹះៗ៖

«ហើយកាលណោះ ព្រមរៀបការជាមួយមនុស្សដែកធ្វើអីអញ្ចឹង?»

ស្រីស្អាតក្រហមមុខងៅនាងមិនរលាស់ដៃចេញ ព្រោះដឹងចិត្តគេហើយថាវាគ្មានបានការអីទេ បើគេចង់ចាប់ នាងរើយ៉ាងណាក៏មិនរួច។ ស្រីស្អាតនិយាយទាំងមិនមើលមុខ៖

«ប្រាប់ហើយ ថាមិនទាន់រៀបការទេ! និយាយមិនចេះស្តាប់គ្នា!»

គេទាញនាងមកក្បែរកាយហើយខ្សឹបៗ៖

«អញ្ចឹងក៏បាន! តែចាំបន្តិចបានអត់? ទម្រាំធ្វើរតនៈសោភ័ណចប់រកត្បូងថ្មខ្មែរ៩០ការ៉ាត់មួយមកធ្វើចិញ្ចៀនឲ្យ! »

សក្ខណាចងចិញ្ចើម៖

«៩០ការ៉ាត់អ្ហែស? ទាល់តែរកដៃដំរីមកពាក់!»

«អត់ទេ! គឺចងប្រពន្ធខ្ញុំជាប់នឹងរ៉ែថ្មកុំឲ្យពូកែរត់ពេក!»

នាងចង់ងរង៉ក់បន្តដែរ តែស្នេហាអ្នកប្រុសសម្តែងចេញធ្វើឲ្យនាងមិនអាចទប់ចិត្តរំភើប បានក៏ងាកទៅញញឹមរកគេដោយរំភើប៖

«ខ្ជិលរត់ណាស់! គង់តែរត់មិនរួចដដែល!»

រិទ្ធិញញឹមក្រសោបរាងកាយនាងតូច ....នាងមិនរើតែនិយាយតិចៗ

«ភ្ញៀវមកច្រើនណាស់ មិនខ្លាចគេឃើញទេ?»

«អត់ខ្វល់!!! ព្រោះចាស់ៗមានរឿងរវល់នៅខាងមុខច្រើនណាស់ គ្មានអ្នកណាមកខ្វល់ជាមួយតួរងដូចយើងទេ!»

នឹកឃើញដល់អ្វីម្យ៉ាង ស្រីតូចសួរវិញភ្លាម៖

«ចុះបងលោកមកទេ? ហួត យុត្តនាណ៎ា»

រិទ្ធិនិយាយតិចៗ៖

«អត់ទេ!»

«ម៉េចអញ្ចឹង??» សក្ខណាសួរមួយៗទាំងចិត្តនឹកគិតទៅដល់ពៅបញ្ញា។

«គេរត់បាត់ហើយទៅសម្លាប់ខ្លួនផងមិនដឹង!»

«ហេតុអ្វី?»

«ត្រូវជំទាវបដិសេធទៅហើយ! គេមានអីត្រូវរស់នៅទៀត?»

«ថាម៉េច?»

«គឺម៉ាក់នាងណ៎ា! គាត់លើកនាងឲ្យខ្ញុំ ព្រោះខ្ញុំមានប៉ានាងគាំទ្រ តែបងខ្ញុំ អត់សំណាងអញ្ចឹង

ទេ! ប៉ានាងក៏មិនគាំទ្រ បានអ្នកណា????......
សក្ខណាវេភ្នែកគិតទាំងខ្វល់ខ្វាយ នាងចាប់ដៃគេចេញពីរាងកាយហើយបែរក្រោយសម្លឹងអ្នកប្រុសដោយខ្សែភ្នែកស្រពោន៖
«ខ្ញុំទៅប្រាប់ពៅបញ្ញាសិន!»

## ជំពូក២៦

កម្ពុហោស៍ ទីសាងស្នេហ៍

.....សង្កាត់ បឹងកេងកងដ៏ត្រកាលនៃបណ្តាអភិជនព្រមទាំងជាសង្កាត់ដែលមានជីវភាព ដ៏ស៊ីវិល័យបង្កប់ទុកនូវអគារ Campu House ខ្ពស់សន្លឹមដែលពៅបញ្ញាខានមកជាយូរមកហើយបន្ទាប់ពីរាត្រីដំបូង ដែលនាងត្រូវបង្ខំចិត្តឡើងមករកបុរសសង្ហាទាំងកណ្តាលរាត្រី។
នារីឈប់ឡានហើយវេភ្នែកទៅរកជណ្តើរយន្តដែលកាលពីពេលណាមួយនោះ នាងបានប្រទាក់សម្តីដោយទោមនស្សជាមួយបុរសមានស្នាមខ្វួចនៅចុង បង្អស់នៃស្នាមញញឹមរបស់គេ។
ពេលនេះមិនមែនជាពេលដែលនាងចង់ដំអក់ក្នុងរថយន្តដកដង្ហើមវែងៗ ទុកពេលសម្រាប់ខ្លួនឯងប្រាំនាទីដូចកាលពីយប់នោះទេ តែជាពេលដែលទ្រូងនាងជង្គក់ជាមួយសំណួរថា «គេទៅណា? គេនៅទីនេះដែរ? គេខូចចិត្តយ៉ាងណាដែលត្រូវចាស់ទុំបដិសេធ ហើយគេជឿទេថាយើងនឹងតស៊ូដើម្បីស្នេហានេះ?»
នាងក្តាប់មាត់បើកគន្លឹះទ្វារហើយដៃឈោងទាញកាបូបចាកចេញពីក្នុងឡាន។
រាងកាយស្គមស្តើងសឹងថាមិនទាន់ឈានលើធរណីកាលណាក៏នឹកស្រមៃដល់ សន្ទឹករថយន្តព្រហើនមួយកាលពីពេលមួយនោះបត់វេវមកចតសឹងថា ក្បែរត្របាក់យកស្បែកជើងកែងចោតរបស់នាង។
នាងងើបមុខសម្លឹងចំណតរថយន្តដែលពេលនេះមិនឃើញមានរថយន្តធំ ជង្គ្រោងពណ៌ខ្មៅស្និលដែលកាលណោះបានចតទទឹងទទែងបង្ហាញភាពព្រហើន រឹងត្អឹងដូចទឹកមុខមហាសែនឌឺដងរបស់ម្ចាស់ឡានដែលព្រហើនហួស បរិយាកាសនោះទេ។
«ខ្ញុំនឹកលោកណាស់! ហ្វួត យុត្តនា»
ពៅបញ្ញាឈានដល់ជណ្តើរហើយចុចយោង។
នាងនឹកស្រមៃដល់រាងកាយធំខ្ពស់របស់គេដែលឈានមកជិតសែនជិតនិង សម្តីកំបុតកំបុយ

គ្មានភាពទន់ភ្លន់របស់គេ«ស្តាប់! ពៅបញ្ញា! ស្រីចរិតប្រុស! ខ្ញុំអត់អ្នករៀនអ្នកសូត្រអីច្រើនដូចនាងទេ! ក៏មិនចាំបាច់យកទ្រឹស្តីសីលធម៌កូនប្រុសទ្រូងប្រាំហត្ថអីមក សូត្រដូចគ្នា! ព្រោះខ្ញុំអត់ចេះខ្វល់ផង! បើខ្ញុំចង់ធ្វើអីគឺធ្វើហ្នឹងហើយ!!! ចាំទុកអ្នកនាងមេធាវី!»
ទ្វារជណ្តើររបើក....ឯទ្វារផ្ទះគេនៅតែចំហដូចពេលដែលនាងធ្លាប់ ស្ទុះចេញចោលគេ ព្រោះខឹង ហើយក្រោយមកក៏សម្រេចចិត្តឡើងទៅរកគេវិញព្រោះទាល់ច្រក....
....ខុសគ្នាត្រង់ថាលើកនេះ នាងមិនបានដើរចូលទៅទាំងទើសទាល់ទេ ប៉ុន្តែគឺចូលដោយអន្ទះសា ....នាងធូរទ្រូងខ្សាកព្រោះក្រសែភ្នែកដំបូងបានប៉ះនឹងខ្នង....បុរសមិន សុភាពដែលនៅអង្គុយលើសាឡុងផ្តោតអារម្មណ៍ទៅលើអេក្រង់ទូរទស្សន៍ ប្រកបដោយទស្សនីយភាពររាំរបស់តារាស្រីបរទេសដ៏សិចស៊ី។
....នាងក្តាប់មាត់ដើរកាត់ពីមុខគេហើយទាញតេឡេមកចុចបិទ....បបូរមាត់ បុរសម្ចាស់បន្ទប់ស្មើធេង តែភ្នែកគេស្រទន់មើលមកនាង....
ស្រីអ្នកច្បាប់បន្ទោសដោយទឹកមុខង៉ក់ងរះ
«ទូរសព្ទក៏បិទ! ផ្ទះជាន់ទីបួនក៏មិនឃើញ!»
«ហើយរកធ្វើអី?»
នារីនៅទ្រឹងទាំងទឹកមុខសៅហ្មងនៅពីមុខធ្វើឲ្យនរៈញញឹម ចុងមាត់លូកដៃទៅទាញកាបូបពីម្រាមដៃស្រីគ្រវែងទៅម្ខាងហើយ។ គេចាប់ទាញរាងកាយស្រីតូចឲ្យធ្លាក់មកលើខ្លួនពេញទំហឹង។
«កាបូបខ្ញុំធ្វើអីលោក! ចាប់បោះបោក!!!»
គេមិនឆ្លើយបែរសួរវិញះ
«អ្នកណាធ្វើឲ្យមេធាវីខឹង?»
«គឺខឹងលោក ហួត យុត្តនា!»
«ពូកែខឹង ខឹងឲ្យអស់ចិត្តទៅ!»
នាងកាន់តែសៅហ្មង....បុរសនេះគ្រាន់តែលួងលោមមនុស្សស្រីបន្តិចក៏មិន ចេះ អ្វីដែលគេស្ទាត់គឺធ្វើឲ្យនាងអន់ចិត្តតែប៉ុណ្ណឹង។
«ប្អូនលោក លោកប៉ាលោក សុទ្ធតែទៅផ្ទះម៉ាក់ធំខ្ញុំ ម៉េចក៏លោកមិនទៅ? លោកមិនដឹងថាខ្ញុំមើលផ្លូវទេ!» នាងចង់សួរសំណួរនេះតែនិយាយមិនចេញ បែរជាសំងំលេបទុក្ខ ធ្វើឲ្យនរៈលូកដៃមកឱបចង្កេះនាង ដែលអង្គុយលើខ្លួនគេ។

«មកធ្វើអី?»
នារីងរង៉ក់៖
«ទៅវិញក៏បាន!»
នាងក្រោកចេញវឹង ដើរតម្រង់រកទ្វារទាំងមិនខ្វីយកកាបូប។ ពីក្រោយខ្នង គេមិនបានងើបមកតាមទេ ម៉្លោះហើយនារីរឹតតែទោមនស្សទ្វេ នាងគិតក្នុងចិត្ត៖
«ហ្នួត យុត្តនា! ខ្ញុំដាក់ខ្លួនមករកលោកហើយ បើលើកនេះលោកមិនតាមមកទេ ខ្ញុំទៅមែនទែនហើយ! ចាំមើលខ្ញុំនឹងឈប់ខ្វល់ជាមួយលោក មនុស្សចរិតយ៉ាប់!»
នាងដើរបណ្ដើរអន់ចិត្តបណ្ដើរព្រោះគេពិតជាមិនរវល់ឃាត់នាងសោះ។ ដៃស្រីដាក់លើគន្លឹះទ្វារស្រាប់តែ សំឡេងគេបានលាន់មកបន្លប់ភាពច្របូកច្របល់របស់នាង៖
«៥នាទី!!! ខ្ញុំចាំនាងនៅក្នុងបន្ទប់!»
នារីឈប់ជើងហើយបែរក្រោយសម្លឹងនាយ សំឡេងគេលាន់បន្ត៖
«តែងខ្លួនឲ្យស្អាតជាងនេះបន្តិចបានអត់! មុខមាត់អាក្រក់ណាស់!!! ខ្ញុំអត់មានអារម្មណ៍ទេមេធាវី!»
នាងតាមថាត្រូវខឹងនឹងសម្ដីគេ លើកនេះទោះគេនិយាយអ្វីក៏ដោយឲ្យតែឃាត់នាងមិនឲ្យទៅ គឺនាងសប្បាយចិត្តទាំងអស់ព្រោះនាងពិតជាមិនចង់ទៅចោលគេឡើយ នាងងាកក្រោយសួរដោយឥតព្រាងទុក៖
«ហេតុអី?»
«នាងគ្មានសិទ្ធិសួរទេមេធាវី! »
អ្នកប្រុសទីមួយឆ្លើយទាំងញញឹមហើយដើរតម្រង់មកនាង ចំណែកបបូរមាត់ស្រីតូចចាប់ផ្ដើមចេញនូវស្នាមញញឹមព្រោះនាងមិន ខ្វល់អ្វីទៀតទេ គឺនាងនឹកឃើញឡើងវិញនូវរាត្រីពណ៌ស៊ីជម្ពូដែលបុរសនេះហួងហែង ប្រចណ្ឌនាងហើយបង្ខំនាំនាងចាកចេញពីក្នុងចំណោមកែវភ្នែកកំលោះៗ បង្ខាំងនាងនៅផ្ទះចាស់ជាន់ទីបួនរបស់គេសម្រាប់មើលនាងតែម្នាក់ ឯង។

គេដើរមកដល់យ៉ាងជិតអាចថាប៉ះគ្នាសូម្បីតែខ្យល់ដកដង្ហើម ធ្វើឲ្យស្រីតូចកាន់តែអៀនកាន់តែឈ្ងោកមិនខ្វីសម្លឹងគេ។
«ក្រែងមកសងបំណុលមែនអ្នេស៎? សួរច្រើនម៉េះ? ត្រៀមតែខ្លួនទៅ?»
ស្រីស្អាតឈ្ងោកមុខទាំងញញឹម នាងចង់និយាយស្ដីឲ្យគេ តែគេនិយាយបានមុន៖

«ខំញញឹមយោងអ្វី? តែងខ្លួនយ៉ាប់ៗអញ្ចឹង ប្រុសណាគេមានអារម្មណ៍ទៅមេធាវី?»
«និយាយមក ? ចង់ត្រូវប៉ុន្មានកំផ្លៀង?»នាងនិយាយទាំងញញឹមសម្លឹងឥដ្ឋ។
«នាងចង់ទះកន្លែងណាខ្លះមេធាវី?»
«ទះមាត់លោក! ហួត យុត្តនា! ប្រុសមាត់ស្រី ប្រុសចរិតស្រី ...»
«តែស្អីផ្សេងទៀតអត់ស្រីទេ! មិនជឿនាងសាកមើលទៅ....»
ដៃគេលូកមកឱបចង្កេះនាង នាងច្រានចេញទាំងស្រដី៖
«មនុស្សយ៉ាប់!»
«មុនមានភស្តុតាងកុំឆាប់វាយតម្លៃគេពេកមេធាវី!»

នាងឈប់ស្រដីព្រោះតែដឹងថានិយាយយ៉ាងណាក៏មិនឈ្នះម្នាក់នេះនាងប្ដូរប្រធានបទ៖
«ជំទាវម៉ាក់ថាឲ្យលោក?»
គេមិនឆ្លើយនាងងើបមុខសម្លឹងគេ។ គេញញឹមស្រទន់ភ្នែកផ្ដោតលើនាង តែគេនៅតែមិននិយាយធ្វើឲ្យនាងអន្ទះសាសួរបន្ថែម៖
«ហួត យុត្តនា! ម៉ាក់ធំស្តីឲ្យលោកយ៉ាងម៉េចខ្លះ?»
«គឺគាត់មិនឲ្យខ្ញុំទៅដណ្ដឹងនាងទេ!«
គេឆ្លើយខ្សឹបៗ។ ស្រីស្អាតធ្វើមុខក្រៀមព្រោះអាណិតចិត្តគេ នាងខំពោលល្បួងលោម៖
«គឺ.....ប្រហែលជា....»
អ្នកប្រុសនិយាយកាត់៖
«ទាំងប៉ានាងទាំងម៉ាក់ធំនាងសុទ្ធតែមើលងាយខ្ញុំ....»
គេប្រើខ្សែភ្នែកស្រទន់សម្លឹងបបូរមាត់ស្រីស្អាតមិនខ្វល់ថាចិត្តនាងកំពុងដាច់ដោច គេញញឹមនិយាយបន្ថែម៖
«គាត់ថាគ្មានផ្លូវព្រមឲ្យខ្ញុំដណ្ដឹងនាងទេ គឺគាត់លើកឲ្យតែម្ដងពៅបញ្ញា!»
ស្រីតូចងើបមុខសម្លឹងនាយ។
ភាពត្រេកអរលេចល្វៃងក្នុងពន្លឺភ្នែកនាង។ ប្រសិនបើជំទាវម៉ាក់នាងសុខៗស្រាប់តែព្រមទទួលស្គាល់បុស្បានារី ទទួលយកអ្នកប្រុសទីពីរ ហួត ខេមរិទ្ធិ និងទទួលយកសូម្បីតែនាងជាកូនម្នាក់របស់គាត់.....តើពិភពលោកនេះមាន ពេលប្ដូរទៅជាល្អគ្រប់រឿងដល់ម្លឹង..?.
អារម្មណ៍រីករាយរបស់នាងមិនអាចលាក់កំបាំងពីភ្នែកបុរសដែលយល់ចិត្តនាងបំផុតម្នាក់នេះ

បានឡើយ។
«សប្បាយចិត្តម៉េះ?»
«អ្នកណា?»
«មិនដឹងអ្នកណា?!..កុំសប្បាយចិត្តពេកមើល៍! ខាងប្រុសគេមិនទាន់ថាព្រមទេ!»
នាងលូកដៃក្ដិចមាត់ គេមួយហើយឈ្ងោកមុខសើចខឹកៗ។ បុរសកាន់តែបានចិត្ត និយាយបន្ត ៖
«ហើយដូរពីទះ មកជាក្ដិចវិញហើយ?»
«ម៉េច? ចូលចិត្តកំផ្លៀងជាង? ត្រូវច្រើនដងពេលទៅជាញៀនហើយអី?»
គេនិយាយមកកាន់ស្រីតូចបន្ត៖
«នៅមានរឿងសប្បាយចិត្តមួយទៀត!»
«និយាយភ្លាមមក!»
គេលូកដៃមកឱបចង្កេះនាងតែនាងច្រានចេញសាជាថ្មី។ អ្នកចចេសចូលមកទៀតទាំងនិយាយប្រាប់ខ្សឹបៗក្បែរត្រចៀកនាង៖
«ភ័យអី? ខ្លាចជំទាវម៉ាក់នាង? ខ្លាចធ្វើអី គាត់គ្មានពេលមកមើលនាងទេ ព្រោះគាត់កំពុងត្រូវគេចូលដណ្ដឹងដូចគ្នា!»
«លោកថាម៉េចយុត្តនា!»
«ប៉ា ហួត ស៊ីវ ទៅផ្ទះនោះ មិនមែនតែដណ្ដឹងប្រពន្ធឲ្យកូនប្រុសអត់គាត់ទាំងពីរឯណា គឺគាត់ទៅដណ្ដឹងឲ្យខ្លួនគាត់ដែរ!»
ពៅបញ្ញាចងចិញ្ចើមព្រោះភ្ញាក់ផ្អើលនរៈយើងបន្លឺបន្ថែម៖
«ប៉ា ប៉ែន ពេជ្រ របស់នាងជាអ្នកធ្វើមេអណ្ដើកឲ្យ! មកជាមួយគ្នាដែរហ្នឹង ជំទាវម៉ាក់នាងលែងកាចទៀតហើយមេធាវី ឈប់ភ័យទៅ!»
នារីបើកភ្នែកធំៗ។ នាងសម្លឹងមុខនាយមិនចេញស្ដីតែសំណួរជាច្រើនលេចចេញជាស្រេចហើយក្នុងន័យថា«ពិតមែន?»
អ្នកប្រុសទីមួយងក់ក្បាលផ្ងក់ៗជាសញ្ញាបញ្ជាក់នឹងនាងថានាងស្ដាប់មិនច្រឡំទេ។
ពៅបញ្ញាញញឹមឯបុរសបានចិត្តសួរផ្ដើន៖
«សួរអស់ចិត្តនៅ? ដល់ពេលគិតគូររឿងយើងបាននៅ?»
«រឿងអី?»

«រឿងជំពាក់គ្នា!»
«អ្នកណាជំពាក់លោក? មានភស្តុតាងសាក្សីអត់?»
«អញ្ចឹងតើបានគេថាមនុស្សស្រីសម័យនេះពិសពុលមិនបាច់!»
«លោកថាម៉េចក៏បាន!»
«ជឿថាខ្ញុំខលទៅប្តឹងប៉ានាងអត់?»
«ស៊ីលដដែលគ្មានពីណាខ្វល់ទេ!»
«មែនហ្អេស៎?»
គេលូកដៃលើកទូរសព្ទ ស្រីតូចសើចទាញវាទុកវិញតែគេមិនលែង៖
«លោកយ៉ាប់ម៉េះយុត្តនា! ចេះខ្មាសគេអត់!»
បុរសញញឹមដៃម្ខាងចង្អុលបបូរមាត់នាយធ្វើឲ្យស្រីតូចក្រហមមុខងាំង ព្រោះនាងនឹកឃើញដល់ពេលមួយក្នុងវិនាទីទាល់ច្រកនាងខំការពារ មិនឲ្យឪពុកដឹងពីស្ថានភាពដ៏អាម៉ាស់របស់ខ្លួន ក៏ដាច់ចិត្តឈោងទៅថើបបបូរមាត់នាយ។ គឺនៅលើផ្ទះតូចរបស់គេដែលមានដើមផ្កាសារិកាជាសក្ខីស្នេហ៍។ ពន្លឺភ្នែកគេក៏បង្ហាញថាគេកំពុងនឹកភ្នកដល់គ្រានោះវិញដូចគ្នា។ ស្រីស្អាតនិយាយតិចៗ៖
«លោកកុំសង្សឹម ហួត យុត្តនា!»
អ្នកប្រុសមិនមាត់ តែគេត្រកងប្រាណស្រីតូចមកក្នុងរង្វង់ដៃ។ ជំនួសឲ្យសម្តីថានាងជាស្រីស្អាតលើសគេសម្រាប់បេះដូងនាយ គេលើកម្រាមដៃនាងម្ខាងមកថើបក្បែរបបូរមាត់។
«ខ្ញុំអាចឱបនាងពេញមួយជីវិតទេ ពៅបញ្ញា ! តែខ្ញុំនឹងប្រើជីវិតដែលនៅសល់ពីពេលនេះទៅដើម្បីឱបនាងហើយការពារនាង !»
គេគិតក្នុងចិត្ត ហើយសន្សឹមៗ ហត្ថដ៏ទន់ភ្លន់ទាំងទ្វេរបស់ស្រីតូចក៏កម្រើកមកថ្នាក់ថ្នមលើរាងកាយអ្នកប្រុសទីមួយវិញ។